ព្រះរាជក្រម

នស/រកម/១២០៦/០២៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានកូមិជាតិសាសនា រក្ខគខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងូរហារាស កម្ពុជឯករាជរដ្ឋចូរណាសន្តិ សុគមច្ចលា សិរីនិបុណា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី១ ទី២ ទី៤ ទី៧ ទី៩ ទី១១ ទី១២ ទី១៣អា ទី១៣បេ ទី១៥ ទី១៦ វិសោធនកម្មមាត្រា១៧ និងពិធីសារទី១ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាងនិងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសាធារណរដ្ឋប្រជាមានិតចិន សាធា-

02.12.06

រណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់មា៉ ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញនិងពលរដ្ឋឆ្លង កាត់ព្រំដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៦ នាសម័យ ប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ១ ទី ២ ទី ៤ ទី ៧ ទី ៩ ទី ១១ ទី ១២ ទី ១៣អា ទី ១៣បេ ទី ១៥ ទី ១៦ វិសោធនកម្មមាត្រា ១៧ និងពិធីសារទី ១ សម្រាប់អនុវត្តកិច្ចព្រមព្រៀង រវាងនិងក្នុង រង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួល ការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

មាត្រា ១.-

អនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ២ ទី ៤ ទី ៧ ទី ១១ ទី ១២ ទី ១៣អា ទី ១៥ វិសោធនកម្មមាត្រា ១៧ និងពិធីសារទី ១ ដែលធ្វើនៅទីក្រុងភ្នំពេញ នាថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ និងឧបសម្ព័ន្ធទី ១ ទី ៩ ទី ១៣បេ ទី ១៦ ដែលធ្វើនៅទីក្រុងវៀងច័ន្ទ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤ សម្រាប់អនុវត្តកិច្ចព្រមព្រៀង រវាងនិងក្នុង រង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ស្តីពីការសម្រួលការពីកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តឧបសម្ព័ន្ធ ពិធីសារ និងវិសោធនកម្មនៃកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជក្រឹត្យសម្តេចព្រះមហាក្សត្រ

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆកា

ង៉ា ស៊ីម

ព.ស.០៦៦២.៥០១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ហត្ថលេខា

ស៊ុន ចាន់ថុល

លេខ : ៤៥០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងសាធារណការ និងដឹកជញ្ជូន

ឱបសម្ពន្ធទី ១,២,៤,៧,៩, ១១,១២, ១៣អា ,១៣បេ,១៥ ,១៦
និងពិធីសារទី១

សំរាប់អនុវត្តកិច្ចព្រមព្រៀង GMS
ស្តីពីការសំរួលការដឹកជញ្ជូនឆ្លងដែន និងប្រជាពលរដ្ឋ ឆ្លងកាត់ព្រំដែន

នាយកដ្ឋានផែនការ

សីហា ឆ្នាំ ២០០៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន
លេខ:...1845.....ស.ក

រាជធានីភ្នំពេញ, ថ្ងៃទី 13 ខែ 9 ឆ្នាំ ២០0.6

សូមគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

កម្មវត្ថុ: សំណើកែសំរួលអត្ថបទសេចក្តីព្រាងច្បាប់ និងសេចក្តីថ្លែងហេតុ ដើម្បីបញ្ជូន និងដាក់ស្នើសុំការផ្តល់សច្ចាប័ន សាជាថ្មីពីសភាជាតិលើឧបសម្ព័ន្ធ *ទី១ ទី២ ទី៤ ទី៧ ទី៩ ទី១១ ទី១២ ទី១៣អា ទី១៣បេ ទី១៥ ទី១៦ វិសោធនកម្មមាត្រា១៧ និងពិធីសារទី១* នៃកិច្ចព្រមព្រៀង GMS ដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។

យោង: ស្មារតីនៃកិច្ចប្រជុំ ជាមួយគណៈកម្មាធិការទី ៥ នៃរដ្ឋសភាជាតិ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយស សូមជំរាបជូន **សម្តេចនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា : កាលពីថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៦ កន្លងទៅ ក្រសួងសាធារណការ និង ដឹកជញ្ជូន បានជួបប្រជុំជាមួយគណៈកម្មការទី៥របស់រដ្ឋសភាជាតិ ដើម្បីពិនិត្យមើលសេចក្តីព្រាងច្បាប់ *ស្តីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធ ទី១ ទី២ ទី៤ ទី៧ ទី៩ ទី១១ ទី១២ ទី១៣អា ទី១៣បេ ទី១៥ ទី១៦ វិសោធនកម្មមាត្រា១៧ និង ពិធីសារទី១ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាង និង ក្នុងរង្វង់រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និង ពលរដ្ឋឆ្លងកាត់ព្រំដែន* ។ ក្នុងឱកាសនោះ គណៈកម្មការទី៥នៃរដ្ឋសភាជាតិ បានស្នើឱ្យក្រសួងសាធារណការ និង ដឹកជញ្ជូន ដែលជាតំណាងរាជរដ្ឋាភិបាល ធ្វើការកែតម្រូវនូវសេចក្តីព្រាងអត្ថបទច្បាប់ និង សេចក្តីថ្លែងហេតុ នៅលើចំណុចដូចខាងក្រោម :

១- ស្នើកែតម្រូវឈ្មោះប្រទេសពី : *សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ* អោយបានត្រឹមត្រូវទៅជា *សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ* ទាំងនៅលើសេចក្តីព្រាងច្បាប់ និង សេចក្តីថ្លែងហេតុ ។

២- ស្នើសុំបន្ថែម និង បំពេញឈ្មោះប្រទេសទាំងអស់ នៃកិច្ចសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គ ទៅក្នុងចំណងជើងនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ទាំងនៅលើសេចក្តីព្រាងច្បាប់ និងសេចក្តីថ្លែងហេតុ ។ ដោយហេតុថា :

- មាត្រា៤ នៃវិសោធនកម្ម នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ បានចែងថា : " មាត្រា ៣៦ស្ងួន ការចូលៈ *កិច្ចព្រមព្រៀងបើកចំហ សំរាប់ការចូល ពីប្រទេសណាមួយនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ។ លិខិតូបករណ៍នៃការចូល ត្រូវតំកល់ទុកនៅរដ្ឋាភិបាលនៃភាគីចុះកិច្ចសន្យាទាំងឡាយ* " ។

កម្ពុជា សាធារណរដ្ឋប្រជាមានិតចិន និង សហភាពមីយ៉ាន់ម៉ា បានតំកល់ទុកលិខិតូបករណ៍នៃការចូលទៅភាគី ចុះកិច្ចសន្យាទាំងអស់ ជាបន្តបន្ទាប់គ្នារួចមកហើយ។

- មាត្រា៥ នៃវិសោធនកម្ម នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ បានចែងថា : *បន្ថែមពីលើការយល់ព្រមចូលពីប្រទេសណាមួយនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ចំណងជើងនៃកិច្ចព្រមព្រៀងក្រមខ័ណ្ឌ នឹងត្រូវធ្វើវិសោធនកម្មដោយស្វ័យប្រវត្តិ ដើម្បីបញ្ចូលឈ្មោះប្រទេស ដែលបានយល់ព្រមចូល* ។

ចំណងជើងពេញលេញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌគឺ : ***កិច្ចព្រមព្រៀងរវាង និង ក្នុងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនចំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន*** ។

ក្រសួងសាធារណការ និង ដឹកជញ្ជូនបានឯកភាព និងបានរៀបចំកែសំរួលខ្លឹមសារអត្ថបទសេចក្តីព្រាងច្បាប់ និង សេចក្តីថ្លែងហេតុ ស្របទៅតាមសំណើរបស់គណៈកម្មាធិការទី៥ នៃរដ្ឋសភាជាតិ ដើម្បីរៀបចំបញ្ជូន និងដាក់ស្នើសុំការផ្តល់សច្ចាប័នសាជាថ្មីពីសភាជាតិ ដូចមានឯកសារជូនភ្ជាប់មកជាមួយនេះ ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើ ខ្ញុំសូមគោរពស្នើសុំ **សម្តេចនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាពកែសំរួលអត្ថបទច្បាប់ និង បញ្ជូនទៅរដ្ឋសភា ដើម្បីស្នើសុំការផ្តល់សច្ចាប័នសាជាថ្មី ពីសភាជាតិ *លើឧបសម្ព័ន្ធ ទី១ ទី២ ទី៤ ទី៧ ទី៩ ទី១១ ទី១២ ទី១៣អា ទី១៣បេ ទី១៥ ទី១៦ វិសោធនកម្មមាត្រា ១៧ និង ពិធីសារទី១* នៃកិច្ចព្រមព្រៀង GMS ដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដោយអនុគ្រោះ។

សូម **សម្តេចនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

ស៊ុន ចាន់ថុល

ទំនង់ជូន
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គ*
- *លេខាធិការដ្ឋានជាតិមហាអនុតំបន់ទន្លេមេគង្គ CDC*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ooooooo

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ : ...1698..... សក. រាជធានីភ្នំពេញ. ថ្ងៃទី ២៤ ខែ ៩ ឆ្នាំ ២០០៦

សូមគោរពជូន
ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កម្មវត្ថុ: សំណើបញ្ជូន និងដាក់ស្នើសុំសារជាថ្មី ការផ្តល់សច្ចាប័នពីសភាជាតិ លើឧបសម្ព័ន្ធទី២ ទី៤ ទី៧ ទី១១ ទី១២ ទី១៣អា ទី១៥ វិសោធនកម្មមាត្រាទី១៧ និងពិធីសារទី១ និងឧបសម្ព័ន្ធទី១ ទី៩ ទី១៣បេ និងទី១៦ នៃកិច្ចព្រមព្រៀង GMS ដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។

យោង: ស្មារតីនៃកិច្ចប្រជុំ ជាមួយគណៈកម្មាធិការទី ៥ នៃរដ្ឋសភាជាតិ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបឯកឧត្តមថា ក្រសួងសាធារណការនិងដឹកជញ្ជូន បានរៀបចំកែសំរួលខ្លឹមសារ ឯកសារមួយចំនួន ទៅតាមសំណើរបស់គណៈកម្មាធិការទី៥ នៃរដ្ឋសភាជាតិ ដើម្បីរៀបចំបញ្ជូន និងដាក់ស្នើសុំសារជាថ្មី ក្នុងការផ្តល់សច្ចាប័នពីសភាជាតិ លើឧបសម្ព័ន្ធទី២ ទី៤ ទី៧ ទី១១ ទី១២ ទី១៣អា ទី១៥ វិសោធនកម្ម មាត្រាទី១៧ និងពិធីសារទី១ និង ឧបសម្ព័ន្ធទី១ ទី៩ ទី១៣បេ និងទី១៦ នៃកិច្ចព្រមព្រៀង GMS ដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដូចមានឯកសារជូនភ្ជាប់មកជាមួយនេះ ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើ ខ្ញុំសូមឯកឧត្តមមេត្តាពិនិត្យលទ្ធភាព បញ្ជូន និងដាក់ស្នើសុំសារជាថ្មី ក្នុងការផ្តល់សច្ចាប័នពីសភាជាតិ លើឧបសម្ព័ន្ធទី២ ទី៤ ទី៧ ទី១១ ទី១២ ទី១៣អា ទី១៥ វិសោធនកម្មមាត្រាទី១៧ និងពិធីសារទី១ និងឧបសម្ព័ន្ធទី១ ទី៩ ទី១៣បេ និងទី១៦នៃកិច្ចព្រមព្រៀងGMSដឹកជញ្ជូនឆ្លងកាត់ព្រំដែនដោយអនុគ្រោះ ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រដ្ឋមន្ត្រី

ស៊ឹង ការ៉ីឌួល

ចំលងជូន
- ឯកឧត្តមអគ្គាធិការ និងជាទាយកឧទ្ទេសកាលីយ
- ឯកសារ កាលប្បវត្តិ

552 19 APR 2004

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...២១០...ស.ច.ន.. *រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០០៤*

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម ត្រាំ អ៊ុនតឹក រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន ដើម្បីចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាល លើឧបសម្ព័ន្ធ និងកិច្ចសារ សំរាប់អនុវត្តកិច្ចព្រមព្រៀង GMS សំរួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែនដូចខាងក្រោម:

១-ឧបសម្ព័ន្ធទី១ : ការចុះបញ្ជីយានយន្តទៅក្នុងចរាចរអន្តរជាតិ

២-ឧបសម្ព័ន្ធទី៤ : ការសំរបសំរួលបែបបទឆ្លងកាត់ព្រំដែន

៣-ឧបសម្ព័ន្ធទី៧ : បទប្បញ្ញត្តិចរាចរ និងផ្លាកសញ្ញាតាមផ្លូវថ្នល់

៤-ឧបសម្ព័ន្ធទី១១ : បទដ្ឋាន ឬមាត្រដ្ឋានស្តង់ដារ និងលក្ខណៈបច្ចេកទេស

៥-ឧបសម្ព័ន្ធទី១២ : សៀវ និងសម្បទា ឬ មធ្យោបាយសំរាប់ការឆ្លងកាត់ និង ការឆ្លងកាត់ព្រំដែន

៦-ឧបសម្ព័ន្ធទី១៣ អា : របបគ្រប់គ្រងទទួលខុសត្រូវ អ្នកដឹកជញ្ជូនពហុរូបភាព

៧-ឧបសម្ព័ន្ធទី១៥ : ប្រពន្ធ័ចាត់ថ្នាក់ទំនិញ

៨-ពិធីសារទី១ : ការកំណត់ផ្លូវ និងផ្លូវរបៀង ព្រមទាំងចំនុចចេញ-ចូលឆ្លងកាត់ព្រំដែន

៩-វិសោធនកម្មទាក្រាទី១៧ កិច្ចព្រមព្រៀង GMS សំរួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ស្តីពីការទទួលស្គាល់បណ្ណើបើកបរទៅវិញទៅមកដែលចេញអោយដោយបណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ

ក្នុងឱកាសនៃកិច្ចប្រជុំលើកដំបូង គណៈកម្មការរួមតំបន់ GMS សំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងកិច្ចប្រជុំពាក់ពន្ធ័ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៧-៣០ ខែមេសា ឆ្នាំ២០០៤ នៅរាជធានីភ្នំពេញខាងមុខនេះ ។

ដើម្បីជាសក្ខីភាពនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើសិទ្ធិប្រទាននេះ ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

552
19 APR 2004

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាលកម្ពុជា
Royal Government of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

No: ២០ D.F.P

Phnom Penh, APRIL 19 2004

DELEGATION OF FULL POWERS

- Having seen the Constitution of the Kingdom of Cambodia.
- Having seen the Royal Decree NS/RTK/1198/72 of November 30, 1998 on the Formation of the Royal Government of Cambodia .
- Having seen the Royal Kram 02/NS/94 of July 20,1994 Promulgating the law on the Organization and Functioning of the Council of Ministers .
- Having seen the Royal Degree No 14 ANKR.BK of March 03,1998 on the Organization and Functioning of the Ministry of Public Works and Transport.
- On the proposal of the Minister of Public Works and Transport

THE ROYAL GOVERNMENT OF CAMBODIA

Delegates herewith to **H.E.Mr. TRAM IV TEK**, Secretary of State, Ministry of Public Works and Transport the full powers to sign, on behalf of the Royal Government of Cambodia, the Annexes and a Protocol for implementing the **GMS Agreement on Cross-Border Transport Facilitation of Goods and People** as follows:

1- Annex 2 : Registration of Vehicles in International Traffic
2- Annex 4 : Facilitation of Frontier Crossing Formalities
3- Annex 7 : Road Traffic Regulation and Signage
4- Annex 11 Road and Bridges Design and Construction Standards and Specifications
5- Annex 12 Border crossing and transit Facilities and Services
6- Annex 13a Multi-modal Carrier liability regime
7- Annex 15 Commodity Classification System
8- Protocol 1 Designation of Corridors, Routes, and Points of Entry and Exit(Border Crossings) ,
9- Amendment to Article 17 of the GMS Agreement on Cross-Border Transport Facilitation of Goods and People ;

on the occasion of the Inception Meeting of The Joint Committee of The GMS Cross-Border Transport Agreement, including signing of Stage 1 Annexes and Negotiation Meeting of Stage 2 Annexes, which will be held on 27-30 April 2004, in Phnom Penh.

In witness whereof, the Prime Minister of the Kingdom of Cambodia, has signed this delegation of full powers.

Prime Minister

HUN SEN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ...៥៤៧...សជប

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៤

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមសំណើរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

ប្រទានសិទ្ធិ ជូនឯកឧត្តម **ង៉ី សាំខេង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជារដ្ឋមន្ត្រី អមមហាអនុតំបន់ទន្លេមេគង្គ ដើម្បីចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា លើឧបសម្ព័ន្ធសំរាប់ អនុវត្តកិច្ចព្រមព្រៀង GMS សំរួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដូចខាងក្រោម :

- ១-ឧបសម្ព័ន្ធទី១ : ស្តីអំពីការដឹកជញ្ជូនទំនិញគ្រោះថ្នាក់
- ២-ឧបសម្ព័ន្ធទី៩ : ស្តីអំពីលក្ខណៈវិនិច្ឆ័យសំរាប់ផ្តល់អាជ្ញាប័ណ្ណ ដល់ប្រតិបត្តិការដឹកជញ្ជូនសំរាប់ប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែន
- ៣-ឧបសម្ព័ន្ធទី១៣បេ : ស្តីអំពីលក្ខណៈវិនិច្ឆ័យសំរាប់ផ្តល់អាជ្ញាប័ណ្ណ ដល់ប្រតិបត្តិការដឹកជញ្ជូនតាមបែបពហុរូបភាព សំរាប់ប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែន
- ៤--ឧបសម្ព័ន្ធទី១៦ : ស្តីអំពីលក្ខណៈវិនិច្ឆ័យសំរាប់ការផ្តល់អាជ្ញាប័ណ្ណបើកបរយានយន្ត

ក្នុងឱកាសនៃកិច្ចប្រជុំលើកទី១៣ ថ្នាក់រដ្ឋមន្ត្រី GMS នៃកិច្ចសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០០៤ ខាងមុខនៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាមានិត ប្រជាធិបតេយ្យឡាវ ។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចាត្រង់ដាក់ហត្ថលេខា លើសិទ្ធិប្រទាននេះ ។

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាលកម្ពុជា
Royal Government of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

No: 58 D.F.P

Phnom Penh, December 06 2004

DELEGATION OF FULL POWERS

- Having seen the Constitution of the Kingdom of Cambodia;
- Having seen the Royal Kram NS/RKM/0704/ dated 13 July 2004, Promulgating the Law on Additional Constitution aiming at normalizing the functioning of the national institutions;
- Having seen the Royal Decree NS/RTK/0704/124 of July 15, 2004 on the Formation of the Royal Government of Cambodia;
- Having seen the Royal Kram 02/NS/94 of July 20,1994 Promulgating the law on the Organization and Functioning of the Council of Ministers;
- Having seen the Royal Degree No 14 ANKR.BK of March 03,1998 on the Organization and Functioning of the Ministry of Public Works and transport;
- On the proposal of the Minister of Public Works and Transport;

THE ROYAL GOVERNMENT OF CAMBODIA

Delegates herewith full power to H.E.Mr. KHY TAINGLIM, Senior Minister-Minister in charge of GMS , the full powers to sign, on behalf of the Royal Government of Cambodia, the Annexes for implementing the GMS Agreement on Cross-Border Transport Facilitation of Goods and Poeple as follows:

1- Annex1 : Carriage of dangerous Goods
2- Annex 9 : Criteria for Licensing of Transport Operators for Cross-Border Transport Operation
3- Annex 13b : Criteria for Licensing of Multimodal Transport Operators for Cross-Border Transport Operation
4- Annex 16 : Criteria for Driving Licensee

on the occasion of the 13th GMS Ministerial Conference to be held on 16 December 2004, in Vientiane ,Lao People Democratic Republic .

In witness whereof the undersigned, the Prime Minister of the Royal Government of Cambodia, has signed this delegation of full powers.

Prime Minister

HUN SEN



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

(សេចក្តីព្រាង) សេចក្តីថ្លែងហេតុ
នៃសេចក្តីព្រាងច្បាប់ ស្តីពី
ការអនុម័តយល់ព្រមលើឯបសម្ព័ន្ធឯបសម្ព័ន្ធទី ១,២,៤,៧,៩, ១១,១២, ១៣អា ,១៣បេ,១៥ ,១៦
និងពិធីសារទី១ សំរាប់អនុវត្តកិច្ចព្រមព្រៀង GMS
ស្តីពីការសំរួលការដឹកជញ្ជូនឆ្លងកាត់ និងប្រចាំតំបន់ ឆ្លងកាត់ព្រំដែន

សេចក្តីផ្តើម

កិច្ចព្រមព្រៀងរវាងនិងក្នុងរង្វង់រដ្ឋាភិបាល សាធារណរដ្ឋប្រជាធិប្បតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋ ឆ្លងកាត់ព្រំដែន បានចុះហត្ថលេខាជាលើកតំបូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅ ទីក្រុងវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១ នៅទីក្រុងយ៉ាងហ្គុន . ដែលបានយល់ព្រមចូលដោយ ព្រះរាជាណាចក្រកម្ពុជានៅទីក្រុងយ៉ាងហ្គុន នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០១ បានយល់ព្រមចូលដោយ សាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅទីក្រុងភ្នំពេញ និងបានយល់ព្រមចូល ដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី ខេត្តយូណាន់ សាធារណរដ្ឋ ប្រជាមានិតចិន។ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងនិងក្នុងរង្វង់រដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិប តេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គម និយមវៀតណាម ស្តីពីការសម្រួលនូវការដឹកជញ្ជូន ទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែនត្រូវបានរដ្ឋសភានៃ ព្រះរាជាណាចក្រ កម្ពុជា បានអនុម័តរួចហើយ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០២ ដែលជាកិច្ចព្រមព្រៀងក្របខ័ណ្ឌ ហើយត្រូវបានប្រកាស រួចហើយដែរ ដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០២ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣។

ក្នុងមាត្រាទី ៣(បេ)និង(អិន)នៃកិច្ចព្រមព្រៀង បានចែងថា ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយ ដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលមានលក្ខណៈពិសេស ទៅតាមទីកន្លែង ហើយ ដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង នឹងមានតំលៃចូលរួមស្មើៗគ្នា។ យោងតាមមាត្រា ទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានគេធ្វើវិសោធនកម្មរួចហើយ បានបញ្ជាក់ថាឧបសម្ព័ន្ធ និងពិធីសារ និមួយៗអាចត្រូវបាន គេចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីគ្នា ដាច់ចេញអំពីកិច្ចព្រមព្រៀង។

ក្នុងឱកាសនៃកិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានិលឡា ក្នុងខែមករា ឆ្នាំ ២០០០. កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ ២០០២ និងកិច្ចប្រជុំ លើកទី១១ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ ២០០២ រដ្ឋមន្ត្រី GMS ទាំងអស់ *បានឯកភាពយល់ព្រមទៅនឹងផែនការការងារមួយ ក្នុងការបង្កើយ-បញ្ចប់កិច្ចព្រមព្រៀង និងឧបសម្ព័ន្ធ-ពិធីសារ របស់វា ព្រមទាំងអនុវត្តឧបសម្ព័ន្ធ-ពិធីសារទាំងនេះ នៅចុងឆ្នាំ ២០០៥*។ ឧបសម្ព័ន្ធ និងពិធីសារទាំងអស់នេះ បានចុះហត្ថលេខា ជាបន្តបន្ទាប់រៀងៗគ្នា ក្នុងឱកាសកិច្ចប្រជុំលើកទី១ គណៈកម្មការរួម GMS សំរួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន កាលពីថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៤ នៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា និងក្នុងឱកាសនៃកិច្ចប្រជុំលើកទី១៣ រដ្ឋមន្ត្រី GMS កាលពីថ្ងៃទី ១៦ខែធ្នូ ឆ្នាំ ២០០៤ នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ។ ផលប្រយោជន៍នៃ ឧបសម្ព័ន្ធ និងពិធីសារទាំងអស់នេះមាន :

- អនុញ្ញាតឱ្យកម្ពុជា ចូលរួមក្នុងការដឹកជញ្ជូន និងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន និងសមាហរណកម្មតំបន់.
- ជួយសំរួល និងជំរុញវិស័យដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងពាណិជ្ជកម្មអន្តរជាតិ ពិសេសនៅពេលដែលកម្ពុជា នៅពុំទាន់មានច្បាប់ដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងពាណិជ្ជកម្មអន្តរជាតិឱ្យបានរឹងមាំ គ្រប់គ្រាន់នៅឡើយ
- បង្កើតការងារ និងបង្កើនការវិនិយោគបន្ថែម សំរាប់ចាកចេញដឹកជញ្ជូនឆ្លងកាត់ ទេសចរ និងពាណិជ្ជកម្មអន្តរជាតិ

១.- ទិសោធនកម្មនៃមាត្រាទី១៧ នៃកិច្ចព្រមព្រៀងខាង និងក្នុងនៅនៃរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរួលនូវការដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងការដ្ឋានកាត់ព្រំដែន

វិសោធនកម្មមាត្រាទី១៧ នៃកិច្ចព្រមព្រៀងខាងលើ មាន៤មាត្រា ពាក់ព័ន្ធទៅនឹងការកែសំរួលមាត្រា១៧ ដែលតំរូវឱ្យភាគីចុះកិច្ចសន្យាត្រូវទទួលស្គាល់ទៅវិញទៅមកនូវប័ណ្ណបើកបរដែលចេញឱ្យដោយអជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដោយអនុលោមទៅតាមឧបសម្ព័ន្ធទី១៦ ដែលត្រូវរៀបចំថ្មីបន្ថែមទៀត។ ការធ្វើវិសោធនកម្មនេះគឺដោយយោងទៅលើមាត្រាទី២ នៃអនុស្សារណៈនៃកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានចុះហត្ថលេខានៅភ្នំពេញនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០២ ដែលសន្យាធ្វើវិសោធនកម្មមាត្រាទី៧(បណ្ណបើកបរ) នៃកិច្ចព្រមព្រៀងដើម្បីអនុញ្ញាតឱ្យសាធារណរដ្ឋប្រជាមានិតចិន(ដែលមិនមែនជាសមាជិកអាស៊ាន)អាចចូលក្នុងកិច្ចព្រមព្រៀងបាន។ក្នុងមាត្រា១៧(ចាស់)នៃកិច្ចព្រមព្រៀងបញ្ជាក់ថាភាគីកិច្ចសន្យាទាំងអស់(ដែលជាសមាជិកអាស៊ាន)ត្រូវទទួលស្គាល់បណ្ណបើកបរទៅវិញទៅមកដោយអនុវត្តនិងអនុលោមទៅតាមកិច្ចព្រមព្រៀងអាស៊ាន ស្តីអំពីការទទួលស្គាល់បណ្ណបើកបរទៅវិញទៅមកដែលចេញឱ្យ ដោយប្រទេសជាសមាជិកអាស៊ាន ដែលបានចុះហត្ថលេខានៅឆ្នាំ ១៩៩៨។ វិសោធនកម្មនេះតំរូវឱ្យបញ្ចូលនៅក្នុងតារាងឧបសម្ព័ន្ធ និងពិធីសារ ដែលភ្ជាប់ជាមួយកិច្ចព្រមព្រៀងនូវឧបសម្ព័ន្ធថ្មីមួយឱ្យបានសម្ព័ន្ធទី១៦:លក្ខណៈវិនិច្ឆ័យ សំរាប់ការផ្តល់បណ្ណបើកបរ។

២- ឧបសម្ព័ន្ធទី ២ :ការចុះបញ្ជីយានយន្ត នៅក្នុងចរាចរអន្តរជាតិ

ឧបសម្ព័ន្ធទី២នេះមាន១៨មាត្រា និងមានឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធទី២: គំនូសដ្យាក្រាមនៃយានយន្តទាំងឡាយ ពាក់ព័ន្ធទៅនឹងលក្ខណៈសំគាល់យានយន្តជាទូទៅ និងមានខ្លឹមសារសំខាន់ៗ ដូចជា :ការកំណត់ប្រភេទយានយន្ត(ឧបសម្ព័ន្ធនេះខុសពីពិធីសារអាស៊ាន ដោយអាស៊ានអនុញ្ញាតត្រឹមតែរថយន្តដឹកទំនិញ ប៉ុន្តែឧបសម្ព័ន្ធ GMS នេះ អនុញ្ញាតទាំងរថយន្តដឹកទំនិញ ដឹកអ្នកដំណើរ និងរថយន្តផ្ទាល់ខ្លួន) ក្នុងនោះមានករណីកិច្ចនៃការចុះបញ្ជី ការប្រើប្រាស់ភាសានិងតួអក្សរជាភាសាអង់គ្លេស និងជាលេខអារ៉ាប់នៅលើផ្ទាកលេខនិងប័ណ្ណចុះបញ្ជី សញ្ញាសំគាល់យានយន្ត(ម៉ាក)ដូចជាឈ្មោះឬ និមិត្តសញ្ញាពាណិជ្ជកម្មនៃរោងចក្រផលិតយានយន្ត លេខផលិតផលរបស់រោងចក្រ ឬលេខស៊េរីរបស់យានយន្តនិងលេខម៉ាស៊ីន។ល។ ព្រមទាំងលក្ខណៈពិសេសៗនៃផ្ទាកលេខចុះបញ្ជី វិញ្ញាបនបំត្រនៃការចុះបញ្ជី (បំណុំចុះបញ្ជី ឬប័ណ្ណសំគាល់យានយន្ត):ដែលមានសុពលភាព និងសញ្ញាសំគាល់លក្ខណៈជាតិ :សំរាប់កម្ពុជា: KH សាធារណរដ្ឋប្រជាមានិតចិន: CHN សាធារណរដ្ឋ ប្រជាមានិតប្រជាធិបតេយ្យឡាវ:LAOមីយ៉ាន់ម៉ា: MYA ថៃឡង់ដ៍ : T វៀតណាម : VN ។

៣-ឧបសំព័ន្ធទី ៤ : ការសំរបសំរួលបែបបទឆ្លងកាត់ព្រំដែន

ឧបសម្ព័ន្ធទី៤នេះមាន ២១មាត្រា (និងមានឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធទី២ : ជាគំនូសបង្ហាញជាគន្លឹះ របស់អង្គការសហប្រជាជាតិ សំរាប់ឯកសារខាងពាណិជ្ជកម្ម(United Nations Layout Key for Trade Documents)) ដែលពាក់ព័ន្ធទៅនឹងរាល់បែបបទនិតិវិធីសំរួលការត្រួតពិនិត្យគយ អន្តោប្រវេសន៍ និងសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀតតាមច្រកព្រំដែន ឱ្យបានឆាប់រហ័ស ងាយស្រួល មានប្រសិទ្ធភាពនិងត្រូវគ្នា ស៊ីចង្វាក់គ្នាជាទូទៅ ទៅលើគ្រប់ចលនាដឹកជញ្ជូនឆ្លងកាត់ព្រំដែននូវមនុស្សម្នា យានយន្ត និងទំនិញតាមផ្លូវគោក ដែលជាផ្នែកមួយនៃការដឹកជញ្ជូនតាមបែបពហុភាគ រាប់ទាំងពេលម៉ោងប្រតិបត្តិការ ប្រភេទសេវាកម្មត្រួតពិនិត្យ (គយ, ភូតគាមអនាម័យ, ការត្រួតពិនិត្យ/ការឆែកឆេរគុណភាព, សុខភាព, អន្តោប្រវេសន៍...) ។ល។ ក្នុងនោះមានការកំណត់ប្រភេទទំនិញ តំរូវការមន្ត្រីប្រចាំការនៅជាអចិន្ត្រៃយ៍ ឬតាមរយៈការស្នើសុំឱ្យមានការបើកព្រំដែននិងការជំរះបែបបទនៅក្រៅម៉ោងធ្វើការការងារធម្មតា ការធ្វើអោយចុះសំរុងគ្នានូវមធ្យោបាយឧបករណ៍ខាងអេឡិចត្រូនិក ឬក៏មធ្យោបាយទំនាក់ទំនងផ្សេងទៀត រួមទាំងគ្រឿងប្រដាប់ដើម្បីកត់ត្រាទិន្នន័យ, និងកម្មវិធីផ្នែកទន់(Software)ជាមួយនឹងប្រពន្ធ័ទាំងឡាយដែលកំពុងប្រើប្រាស់ ឬដែលបានប្តូរផ្តាស់និងកែលំអអោយទាន់សម័យ ។

ផ្សេងពីការអនុវត្តនីក្នុងអាស៊ាន ក្រុមប្រទេសក្នុងតំបន់ GMS បានឯកភាពគ្នាកំណត់ និងអនុវត្តការសំរបសំរួលការត្រួតពិនិត្យតាមច្រកព្រំដែន ដែលមានការកត់សំគាល់ពិសេសដូចខាងក្រោម :

*ការអនុវត្តការត្រួតពិនិត្យរួមគ្នាបន្ទះ(ឬបញ្ជរ)តែមួយគឺ*ជានិតិវិធីក្នុងការឆែកឆេរនិងការត្រួតពិនិត្យក្នុងពេលព្រម ។ គ្នាបង្ហុចតែមួយ(ឬបញ្ជរ) តែមួយ ពីគ្រប់អជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ទៅលើមនុស្សម្នា ទំនិញ និងយានយន្ត។ អជ្ញាធរដទៃទៀតអាចផ្ទេរសមត្ថកិច្ចការងាររបស់ពួកខ្លួន ជូនទៅអជ្ញាធរមួយទៀត ដែលមានវត្តមាន ប្រចាំនៅច្រកព្រំដែន(ឧ. ជូនអជ្ញាធរគយត្រួតពិនិត្យយានយន្ត) ។ល។

ការត្រួតពិនិត្យគយរួមគ្នាតែមួយលើក(ឈប់តែម្តង): គឺជាប្រតិបត្តិការនៃការត្រួតពិនិត្យគយតែមួយលើកគត់ សំរាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន រវាងពីរប្រទេសដែលស្រុះស្រួលគ្នា។ មានការស្នើឡើងនូវបែបផែនជាគំរូ (Suggested Modalities) សំរាប់ការត្រួតពិនិត្យគយរួមគ្នាតែមួយលើក ដូចខាងក្រោម :

១- **ការរៀបចំការត្រួតពិនិត្យរួមគ្នា** : អជ្ញាធរគយជាតិរវាងពីរភាគីដែលស្រុះស្រួលគ្នា ត្រូវអនុវត្តការត្រួតពិនិត្យ និងការឆែកឆេររួមគ្នា និងព្រមពេលដំណាលគ្នា ។

២- **ការរៀបចំដាច់ដោយឡែកពីគ្នា** :អជ្ញាធរគយពីភាគីចុះកិច្ចសន្យាមួយរៀបចំជំនាញពិសេសក្នុងការងារ ពិសេសណាមួយ នៅពេលដែលអជ្ញាធរគយពីភាគីចុះកិច្ចសន្យាមួយផ្សេងទៀត រៀបចំជំនាញពិសេស សំរាប់ការងារផ្សេងណាមួយទៀត ជាឧទាហរណ៍ទៅតាមប្រភេទទិសដៅចរាចរ(ទិសដៅចេញក្រៅ ឬទិសដៅចូលក្នុង) ឬក៏ប្រភេទនៃការដឹកជញ្ជូន (អ្នកដំណើរ ឬទំនិញ) ។

៣- **សកម្មភាពនៅលើទឹកដីប្រទេសដទៃផ្សេងទៀត**:មន្ត្រីគយពីភាគីចុះកិច្ចសន្យាមួយអាចអនុញ្ញាតឱ្យ ធ្វើសកម្មភាពការងាររបស់ពួកគេ នៅលើទឹកដីនៃភាគីចុះ កិច្ចសន្យាផ្សេងទៀត ។

៤- **ការផ្ទេរសិទ្ធិនៃអជ្ញាធរ /ការទទួលស្គាល់ទៅវិញទៅមកនូវការត្រួតពិនិត្យ** : ភាគីចុះកិច្ចសន្យាមួយអាចផ្ទេរសិទ្ធិខាងសមត្ថកិច្ចនៃការត្រួតពិនិត្យនិងការឆែកឆេររបស់ខ្លួនទៅឱ្យមន្ត្រីគយនៃភាគីចុះកិច្ចសន្យា ដែលស្រុះស្រួលគ្នាមួយផ្សេងទៀតដើម្បីធ្វើសកម្មភាពនៅក្នុងនាមរបស់ខ្លួន។ ភាគីចុះកិច្ចសន្យាត្រូវទទួលស្គាល់គ្នាទៅវិញទៅមកការត្រួតពិនិត្យឆែកឆេរ ដោយអជ្ញាធរគយនីមួយៗ នៃភាគីផ្សេងទៀត ។

៥- **ការរួមបញ្ចូលគ្នា**: ការរួមបញ្ចូលគ្នានៃបែបផែនជាគំរូ ដូចរៀបរាប់ខាងលើក៏អាចអនុវត្តបានផងដែរ ។

៦-**ការអនុវត្តន៍ដោយរៀបចំឱ្យមានជាអនុស្សារណៈនៃកិច្ចព្រមព្រៀង(MOU)** លើរាល់បែបផែនជាគំរូពិសេសស្តីពីនិតិវិធីនៃការត្រួតពិនិត្យគយរួមគ្នាតែមួយលើក និងត្រូវព្រមព្រៀងគ្នាដោយភាគីមានព្រំដែនជាប់គ្នា ។

ក្រៅពីនេះមានការធ្វើឱ្យស៊ីចង្វាក់គ្នា ការធ្វើឱ្យដោយស្រលាមភ្លេងក្នុងការប្រើប្រាស់ភាសាលើរាល់ឯកសារទាំងឡាយ ការផ្ទាស់ប្តូរគ្នាពត៌មានអំពីបទបញ្ជត្តិច្បាប់ ទំរង់បែបបទនិតិវិធីនិងការអនុវត្តន៍ និងការផ្ទាស់ប្តូរទំរង់បែបបទឆ្លងកាត់ព្រំដែន ការប្តូរគ្នាជាមុននូវពត៌មាននៃការជំរះបែបបទនៅមុនត្រាមកដល់នៃទំនិញ ការកំណត់លំដាប់អាទិភាពនៃការជំរះបែបបទឆ្លងកាត់ព្រំដែន ការកាត់បន្ថយនូវការអនុវត្តន៍ការត្រួតពិនិត្យរូបវន្ត(ជាក់ស្តែង) អត្ថភាពនិងគំរូវការខាងមធ្យោបាយ និងមន្ត្រី ដែលមានសមត្ថភាព ។ល។ និង ។ល។

៤-ឧបសំព័ន្ធទី ៧ : បទបញ្ជត្តិចរាចរតាមផ្លូវទឹកផ្ទៃ និងផ្លាកសញ្ញា

ឧបសម្ព័ន្ធទី៧នេះមាន១៣មាត្រា(និងមានឯកសារចំនួន០២ភ្ជាប់ទៅនឹងឧបសម្ព័ន្ធទី៧:**ឯកសារភ្ជាប់ទី១: បទបញ្ជាទៅតាមផ្លូវទឹក** និង**ឯកសារភ្ជាប់ទី២: ផ្លាកសញ្ញា និងភ្លើងសញ្ញានានាតាមផ្លូវទឹក** ដែលពាក់ព័ន្ធទៅនឹងការអនុវត្តទៅតាមសិទ្ធិសញ្ញាអន្តរជាតិស្តីអំពី **បទបញ្ជាទៅតាមផ្លូវទឹក** និង**ផ្លាកសញ្ញា និងភ្លើងសញ្ញានានាតាមផ្លូវទឹក**របស់UNESCAP .និងមានខ្លឹមសារ សំខាន់ៗ ផ្សេងទៀតដូចខាងក្រោម ដូចជា:

-**ការកំណត់រយៈពេលអន្តរកាល(បណ្តោះអាសន្ន) មួយ មានរយៈពេល ៤ឆ្នាំ ដែលតំរូវឱ្យមានការផ្ទាស់ប្តូរ** ឬដាក់បន្ថែមនូវផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា និងគំនូសសញ្ញានានានៅតាមដងផ្លូវ និងផ្លូវរបៀងមេ(ដែលបានកំណត់ក្នុងពិធីសារទី១ នៃកិច្ចព្រមព្រៀង) ដែលដូចគ្នាទៅនឹងផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា ឬគំនូស សញ្ញាទាំងឡាយដែលមានបញ្ជាក្តីនៅក្នុងឯកសារភ្ជាប់ទី២នៃឧបសម្ព័ន្ធនេះ ប៉ុន្តែវាមានអត្ថន័យផ្សេងពីគ្នា។

-**ការកំណត់រយៈពេលអន្តរកាល(បណ្តោះអាសន្ន) មួយ មានរយៈពេល១៥ឆ្នាំ** ដែលតំរូវឱ្យមានការផ្ទាស់ប្តូរ ឬដាក់បន្ថែមនូវផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា និងគំនូសសញ្ញានានានៅតាមដងផ្លូវ និងផ្លូវរបៀងនានា ដែលបានកំណត់ក្នុងពិធីសារទី១នៃកិច្ចព្រមព្រៀង ដែលផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា និងគំនូសសញ្ញាដើមទាំងអស់នោះ

មិនមានបញ្ជាក់នៅក្នុងឯកសារភ្ជាប់ទី២នៃឧបសម្ព័ន្ធនេះ។ *ផ្ទាកសញ្ញា និងនិមិត្តសញ្ញាថ្មីទាំងឡាយដូចមានបញ្ជាក្នុង នៅក្នុង ឯកសារភ្ជាប់ទី២នោះ អាចត់ឡើងឱ្យនៅក្បែរ ផ្ទាកសញ្ញា និងនិមិត្តសញ្ញាដើមនានាដែលមានស្រាប់*។

-ការអនុញ្ញាតជាចំហក្នុងការប្រើប្រាស់នូវផ្ទាកសញ្ញា និមិត្តសញ្ញា ឬគំនូសសញ្ញាផ្សេងទៀតដែល មិនមានបញ្ជាក់នៅក្នុងឯកសារភ្ជាប់ទី២ នៃឧបសម្ព័ន ទៅតាមតំរូវការ។

-ឧបសម្ព័ន្ធនេះមិនបានតំរូវឱ្យគេអនុម័តិទទួលយកផ្ទាកសញ្ញានិងគំនូសសញ្ញា ដែលបានបញ្ជាក់ដោយឯកសារភ្ជាប់ទី២ ទាំងអស់នោះទេ។ ផ្ទុយទៅវិញគេអាចកំរិតនូវចំនួន និងប្រភេទនៃផ្ទាកសញ្ញា ឬគំនូសសញ្ញាទាំងឡាយណាដែលពួកគេត្រូវការ និងអនុម័តិយល់ព្រមទទួលយកនូវអ្វីដែល ចាំបាច់ខាងមិនបានតែប៉ុណ្ណោះ។

-ការហាមឃាត់មិនឱ្យមានការសរសេរ ឬដាក់(តំលើង)បន្ថែម ឧបករណ៍ សំភារៈ ការផ្សព្វផ្សាយពាណិជ្ជកម្ម ផ្ទាកជូនដំណឹង គំនូសសញ្ញា ឬឧបករណ៍ដ៏ទៃទៀត ឱ្យស្ថិតនៅជិតឬក្បែរផ្ទាកសញ្ញា ឬឧបករណ៍ត្រួតពិនិត្យចរាចរដែលធ្វើអោយផ្ទាកសញ្ញាទាំងនោះមិនអាចសំគាល់បាន ឬធ្វើអោយយល់ច្រលំនឹងធ្វើឱ្យមានគ្រោះថ្នាក់ ឬធ្វើអោយរំខែងស្មារតីដល់អ្នកប្រើប្រាស់ផ្លូវថ្នល់ ដែលបង្កនិងធ្វើអោយខូច ប្រយោជន៍ ដល់សុវត្ថិភាពចរាចរ ។ល។

- ត្រូវប្រើប្រាស់រូបសញ្ញានានាជំនួសឱ្យបានច្រើនជាង ការប្រើប្រាស់ភាសា(អក្សរ)សរសេរក្នុងផ្ទាកសញ្ញាចរាចរ
- ការប្រើប្រាស់ភាសារអង់គ្លេស/ឡាតាំង លេខអារ៉ាប់ និងភាសាជាតិព្រមគ្នា/ស្របគ្នា ក្នុងការអធិប្បាយផ្ទាកសញ្ញា គំនូសសញ្ញាផ្លូវថ្នល់ ផ្សេងទៀតទាំងឡាយ ។ល។ និង ។ល។

៥. ឧបសម្ព័ន្ធទី១១:បទដ្ឋាន ឬមាត្រដ្ឋាន(ស្តង់ដារ) និងលក្ខណៈបច្ចេកទេស សំរាប់ការគូសបន្ទាត់ និងសាងសង់ផ្លូវ ស្ពាន

ឧបសម្ព័ន្ធទី១១នេះមាន ២១មាត្រា ដែលពាក់ព័ន្ធទៅនឹងការអនុវត្ត ការរៀបចំជាបទដ្ឋាន មាត្រដ្ឋាន ស្តង់ដារ និងលក្ខណៈបច្ចេកទេសសំរាប់ការគូសគំរោងបួងំនិងសាងសង់ផ្លូវ-ស្ពាន នៅលើផ្លូវហាយវែយតំបន់ទាំងអស់ ។ តារាងបទដ្ឋាន-ស្តង់ដារផ្លូវ គឺប្រហាក់ប្រហែលទៅនឹង តារាងបទដ្ឋាន-ស្តង់ដារផ្លូវរបស់ អាស៊ាន ឬរបស់ហាយវែយអាស៊ី(ESCAP)។ ចំណុចខុសគ្នានៅត្រង់ថា ស្តង់ដារផ្លូវនេះអនុលោមទៅតាមស្តង់ដារផ្លូវ-ស្ពាន នៅប្រទេសចិន ដែលទាបជាងស្តង់ដារផ្លូវអាស៊ាននៅចំណុចខ្លះ ដូចជាទទឹងថ្នល់ ទទឹងខ្សែរចរាចរ ឬប្រឡោះលំហ ស្ពានជាដើម ដែលនេះជាការល្អម្យ៉ាងសំរាប់ស្តង់ដារផ្លូវតូច១នៅកម្ពុជា។

ឧបសម្ព័ន្ធត្រូវបានគេកំនត់ផងដែរ នូវនិយមន័យ ការចាត់ថ្នាក់នៃផ្លូវនិងនិងរបៀងកណ្តាល (ឬរបៀងមេ)ទាំងឡាយដែលបានកំណត់ក្នុងពិធីសារទី១នៃកិច្ចព្រមព្រៀង ចំណាត់ថ្នាក់(ដូចជា: ផ្លូវកំរិតចំបង ផ្លូវថ្នាក់ទី១ ផ្លូវថ្នាក់ទី២ ផ្លូវថ្នាក់ទី៣) និងតួនាទីខាងចរាចរ សំរាប់ចំណាត់ថ្នាក់ និងប្រភេទផ្លូវទាំងអស់នេះ។ ឧទាហរណ៍ ផ្លូវកំរិតចំបង ឬផ្លូវដំណំតូវយែត្រូវមានរបងការពារនិងប្រើប្រាស់បានតែរថយន្តគ្រប់ប្រភេទ ហើយផ្លូវចូលទៅផ្លូវម៉ូតូវយែ ផ្លូវឆ្លងកាត់ ផ្លូវរថភ្លើងឆ្លងកាត់ ដែលត្រូវបំបែកឱ្យនៅដាច់ និងមានកំរិតកំពស់ផ្សេងពីគ្នា។ ម៉ូតូ កង់ និងអ្នកថ្មើរជើងនឹងមិនត្រូវបានគេអនុញ្ញាត ឱ្យធ្វើដំណើរជាមួយនឹងផ្លូវរថយន្ត-ម៉ូតូវយែទេ ក្នុងគោលបំណងដើម្បីបានសុវត្ថិភាពចរាចរ និងសុវត្ថិភាពយានយន្ត ដែលមានល្បឿនល្បឿន ហើយទ្រូងផ្លូវត្រូវចែកដាច់ពីគ្នា ដោយមានគំនូសទ្រូងផ្លូវ។ ល។

ភាគីនិមួយ១អាចសាងសង់និងប្រើប្រាស់បាន *ផ្លូវកំរិតទី៣(ដែលជាផ្លូវមានកំរិតស្តង់ដារទាបបំផុតសំរាប់ចរាចរឆ្លងកាត់ព្រំដែន)* នៅពេលដែលមូលនិធិសំរាប់ការសាងសង់ និងដែល/ក៏ដីសំរាប់សាងសង់ផ្លូវមានកំរិត ហើយត្រូវជំរុញការលើកកំពស់ផ្លូវឬកំណាត់ផ្លូវទាំងឡាយណា ដែលនៅក្រោមកំរិតនេះ ឱ្យឡើងដល់បទដ្ឋានកំរិតទី៣ ក្នុងពេលឆាប់ៗនាថ្ងៃអនាគត។

ការរៀបចំនិងបំពាក់នូវគ្រឿងប្រដាប់ឧបករណ៍នៅតាមផ្លូវថ្នល់ទៅតាមកន្លែងសំខាន់ៗ ស្របតាមចំណាត់ថ្នាក់ នៃផ្លូវ Highway ដូចជា: ការតុបតែងភ្លើងបំភ្លឺ គ្រឿងឧបករណ៍ប្រឆាំងនឹងការចាំងពន្លឺ (ដូចជារបាំងដែកមេដ្យានពុះទ្រូងផ្លូវ) របាំង-សំណាញ់សិប្បនិមិត្ត ឬរបងកូនឈើនៅលើគំនូសចែកកណ្តាលផ្លូវ ឬគំនូសចិញ្ចើមផ្លូវដើម្បីបាំងការពារចំណែកផ្លូវ ឬទ្រូងផ្លូវទៅតាមចរាចរបញ្ច្រាសទិសគ្នា ឬពីផ្លូវដែលស្របគ្នា គំនូសសំរាប់បញ្ឈប់យានយន្តពេលមានគ្រោះបន្ទាន់ បន្ទះឬខ្សែរការពារឬបង្គោលទំនប់ នៅតាមបណ្តោយជម្រាល ឬចំណោតភ្នំ របងសុវត្ថិភាពនិងរបាំងការពារពេលមានគ្រោះថ្នាក់ របងការពារពីការឆ្លងកាត់របស់សត្វពាហនៈ បន្ទប់ឬបញ្ជារទូរស័ព្ទទំនាក់ទំនងបន្ទាន់ មធ្យោបាយសម្បទា សេវាកម្មបំរើ និង កន្លែងឈប់

សំរាកទាំងឡាយផ្សេងទៀតដូចជាទីធ្លា ចំណតរថយន្ត ស្ថានីយប្រេង និងស្ថានីយជួសជុលថែទាំយានយន្ត មជ្ឈមណ្ឌលទូរគមនាគមន៍ បរិក្ខារអនាម័យ (បង្គន់) សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន) នៅតាមដងផ្លូវ ។ ល ។

៦- ខ្ទបសម្ពន្ធ៍ទី១២ : មធ្យោបាយសម្បទា និងសេវាបំរើ សំរាប់ការឆ្លងកាត់ និងការឆ្លងព្រំដែន

ឧបសម្ព័ន្ធទី១២នេះមាន ១៣មាត្រា ពាក់ព័ន្ធទៅនឹងអត្ថិភាព និងតំរូវការ ជាមធ្យោបាយសម្បទា សេវាបំរើ បរិធាន ឬឧបករណ៍ ឬមធ្យោបាយនិងសម្បទាផ្សេងទៀត នៅចំណុចប៉ុស្តិ៍ឆ្លងកាត់ព្រំដែន សំរាប់បំរើដល់យានយន្ត ទំនិញ អ្នកបើកបរ អ្នកធ្វើដំណើរ ក្នុងការឈប់សំចត ការរង់ចាំ ឬការបំពេញបែបបទសំរាប់ការដឹកជញ្ជូន និងការឆ្លងកាត់ព្រំដែន និងមានខ្លឹមសារសំខាន់ៗ ដូចជា: សេវាជួសជុល និងថែទាំយានយន្ត ស្ថានីយប្រេងឥន្ធនៈ ទីចំណតយានយន្ត ឬទីលានដែលមានកំរាលឥង (កំរាលបេតុង) និងមធ្យោបាយ-សម្បទាផ្សេងទៀតសំរាប់ជួយសំរួលការលាងសំអាតយានយន្ត តំបូលគ្របការពារក្នុងពេលផ្លាស់ប្តូរអាកាសធាតុ ពេលផ្ទុក-ផ្ទេរ លើកដាក់ទំនិញ ពេលវេចខ្ចប់និងបញ្ជូនទំនិញ និងពេលត្រួតពិនិត្យទំនិញ ។ល។ ឃ្លាំង ឬបន្ទប់ស្តុកទុកនិងរក្សាទំនិញ (រាប់ទាំងទីកន្លែងដែលមានបំពាក់ម៉ាស៊ីនត្រជាក់) ស្ថានីយកុងតឺណឺ (និងមធ្យោបាយផ្សេងទៀតសំរាប់ស្តុកទុកទំនិញ ក្នុងពេលរង់ចាំ ឬកកស្ទះ ពេលរបើក ឬការបើកឡើង សំរាប់ ការត្រួតពិនិត្យខាងអនាម័យ និងបសុពេទ្យ ឬភូតគាមានាម័យ ឬការដាក់ឱ្យនៅដាច់ពីគេ) ។ល។ ឃ្លាំងគយ . មធ្យោបាយ ឧបករណ៍សំភារៈ ឬសម្បទា សំរាប់ការដាក់ឱ្យនៅដាច់ពីគេ (ភូតគាមអនាម័យ) រុក្ខជាតិ ការលាងជំរះសំអាតមេរោគ និងចំណុចឈប់ឬកន្លែងសំចតជាដំណាក់ៗទាំងឡាយ ដែលអនុញ្ញាតឱ្យមានការសំរាក ការផ្គត់ផ្គង់ចំណីអាហារនិងទឹក ការដាក់ចុះ ការរៀបចំទីកន្លែងប្រគល់ទំនិញដែលជាសត្វរស់ និងមធ្យោបាយ-សម្បទា សំរាប់ការដាក់ឱ្យនៅ ដាច់ពីគេនូវសត្វរស់ ។ល។

ត្រូវបង្កើតឡើងឱ្យមានសេវាបំរើ មធ្យោបាយ-សម្បទា ឧបករណ៍សំភារៈ: សំរាប់ការស្រាវជ្រាវ (ឆែក) រកមើលពត៌មាន អ្នកធ្វើដំណើរ កន្លែងសំរាកកាយ ឧបករណ៍អនាម័យ(បង្គន់) និងថ្នាំជំនួយសុខភាពតំបូង មជ្ឈមណ្ឌលទំនាក់ទំនង (ប៉ុស្តិ៍ប្រៃសណីយ៍និងទូរគមនាគមន៍) បញ្ជារផ្ទៀវសំបុត្រនិងសេវាប្រៃសណីយ៍ (ទូរស័ព្ទ ទូរពុម្ព ទូរសារ អ៊ីនធើណែត) មជ្ឈមណ្ឌលពត៌មាន ការិយាល័យធនាគារនិងការប្តូរប្រាក់ កំឡាំងប៉ូលីសនិងកំលាំងផ្សេងទៀត ដើម្បីធានាសុវត្ថិភាព និងសន្តិសុខដល់អ្នកបើកបរ អ្នកដំណើរ រថយន្ត និងទំនិញបរទេស នៅក្នុងពេលឈប់ ឬសំចត នៅប៉ុស្តិ៍ឬស្ថានីយឆ្លងកាត់ព្រំដែន ស្ថានីយថ្លឹងទំងន់រថយន្ត ស្ថានីយឬទីឈប់សំចត ឬចំណត ដែលកំណត់ឡើងដោយប្រទេសសាមី និងអត្ថិភាព និងតំរូវការមន្ត្រីបុគ្គលិកដែល មានគុណភាព-សមត្ថភាព (ដែលមានចំណេះខាងភាសា អង់គ្លេស) ។ល។

ត្រូវសាងសង់ផងដែរ នូវចំណែកជ្រុងសំរាប់ប្តូរទិសប្រកាន់(ឆ្វេង-ស្តាំ)នៃចរាចរ នៅទីណាដែលមានតំរូវការ ។

រក្សានិងបន្តការប្រើប្រាស់ ការអភិវឌ្ឍន៍បច្ចេកវិទ្យា និងការអនុវត្តន៍បច្ចេកទេសទំនើប និងជឿនលឿន ដូចជាម៉ាស៊ីនត្រួតពិនិត្យរឺអានលិខិតឆ្លងដែន ម៉ាស៊ីនប្រើកាំរស្មីអ៊ិចសំរាប់ត្រួតពិនិត្យទំនិញនិងកុងតឺណឺ ម៉ាស៊ីនស្វ័យប្រវត្តិសំរាប់ បញ្ជាក់លក្ខណៈយានយន្ត(ម៉ាស៊ីនសំរាប់អាននិងត្រួតពិនិត្យផ្ទាកលេខចុះបញ្ជី) និងម៉ាស៊ីនសំរាប់អានរឺត្រួតពិនិត្យបាកូដX-ray ។ល។

៧- ខ្ទបសម័ន្ធទី ១៣អា : របបគ្រប់គ្រងការទទួលខុសត្រូវអ្នកដឹកជញ្ជូនពហុភាគ

ឧបសម្ព័ន្ធទី១៣អានេះមាន ១០មាត្រា ពាក់ព័ន្ធទៅនឹង ច្បាប់ និតិវិធីនិងរបបគ្រប់ ការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូនពហុភាព និងមានខ្លឹមសារដូចខ្លឹមសារនៃឯកសារភ្ជាប់នៃឧបសម្ព័ន្ធនេះ " របបទទួលខុសត្រូវអ្នកដឹកជញ្ជូនពហុភាព " ។

៨- ខ្ទបសម្ពន្ធទី ១៤ : ច្រកព័ន្ធចាត់ថ្នាក់ទំនិញ

ឧបសម្ព័ន្ធទី១៤នេះមាន ១៤មាត្រា(និងមាន ឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធទី១៤ : អនុសញ្ញាអន្តរជាតិ ប្រព័ន្ធចុះសំរុងគ្នានៃការពណ៌នានូវមុខទំនិញ (នាមការទំនិញ) និងប្រព័ន្ធលេខកូដ(ហ្សូលិខ) (ទីក្រុងប្រុសែល ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ១៩៨៣ ដែលបានធ្វើវិសោធនកម្ម តាមរយៈពិធីសារស្តីអំពីវិសោធនកម្មលើអនុសញ្ញាអន្តរជាតិ ស្តីអំពីប្រព័ន្ធចុះសំរុងគ្នានៃការពណ៌នានូវមុខទំនិញ (នាមការទំនិញ) និងប្រព័ន្ធលេខកូដ (ហ្សូលិខ) នៅថ្ងៃ ២៤ ខែ មិថុនា ឆ្នាំ ១៩៨៦) ដែលពាក់ព័ន្ធទៅនឹងនិតិវិធី និង ការទទួលអនុវត្តតាមប្រព័ន្ធចុះសំរុងគ្នា(H.S) ការប្រើប្រាស់ តារាងអាត្រា និងនាមការបញ្ជីពន្ធគយ ប្រព័ន្ធមុខទំនិញ និងប្រព័ន្ធលេខកូដទំនិញ និងមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម ដូចជា : ការប្រើប្រាស់លេខកូដទំនិញលើសពី ៦ខ្ទង់ ការទទួលយកអនុវត្តប្រព័ន្ធចុះសំរុងគ្នា (H.S) នៅតាមការធ្វើសេចក្តីសម្រេច និងការធ្វើវិសោធនកម្ម

ទាំងឡាយ ដែលធ្វើឡើងដោយក្រុមប្រឹក្សាអង្គការគយពិភពលោក ។ការចុះនាមការ(សារបានឬបញ្ជីរាយឈ្មោះទំនិញ)នៃប្រពន្ធ័ចុះសំរុងគ្នា ។ ល ។

៩. ពិធីសារទី ១ :ការកំណត់ដួង និងផ្លូវរបៀង ព្រមទាំងចំណុចចេញ-ចូល(ឆ្លងកាត់ព្រំដែន)

ពិធីសារទី១នេះមាន ១២មាត្រា(និងមានឯកសារភ្ជាប់ : បញ្ជីនៃផ្លូវរបៀង.ផ្លូវថ្នល់និងច្រកឆ្លងកាត់ ព្រំដែន និងផែនទីភ្ជាប់ ទំហំ A4 (A4-format) ដែលពាក់ព័ន្ធទៅនឹង ការកំណត់ផ្លូវថ្នល់ និងផ្លូវមែ ព្រមទាំងចំណុចចេញ-ចូល និងប៉ុស្តិ ត្រួតពិនិត្យច្រកព្រំដែន និងមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម ដូចជា :

ការបើកបន្ថែម ច្រកឆ្លងកាត់ព្រំដែន និងផ្លូវនៅក្នុងតែតំ : អាចធ្វើឡើងតាមរយៈអនុស្សារណៈនៃការយោគយល់គ្នា រវាងនិងក្នុងរវាងភាគីចុះកិច្ចសន្យាមួយក្រុម ។ ការបើកបន្ថែមច្រកឆ្លងកាត់ព្រំដែន ឬផ្លូវទាំងឡាយបែបនេះ ត្រូវបានគេទទួលស្គាល់ដូចគ្នា ដូចច្រកឆ្លងកាត់ព្រំដែន ឬផ្លូវទាំងឡាយ ដែលបានលើកឡើង ជាលើកដំបូងនៅក្នុងពិធីសារនេះ និងត្រូវជូនដំណឹងទៅគណៈកម្មាធិការរួម អំពីការបើកបន្ថែម ហើយនឹងដាក់បញ្ចូលនៅក្នុងមាត្រា ១ នៃពិធីសារនេះ តាមរយៈការធ្វើវិសោធនកម្ម ។ល

១០. ឧបសម្ព័ន្ធទី ១ : ការដឹកជញ្ជូនឧទ្ធិញគ្រោះថ្នាក់

ឧបសម្ព័ន្ធទី១នេះមាន ១២មាត្រា ពាក់ព័ន្ធទៅនឹងការចាត់ថ្នាក់ ប្រភេទទំនិញគ្រោះថ្នាក់ និយាមការ(ស្តង់ដារ) ជាការណែនាំចលនាឆ្លងកាត់ព្រំដែន នូវទំនិញគ្រោះថ្នាក់ ដែលស្របតាមឯកសារអាដេអឺរ និង/ឬ បទប្បញ្ញត្តិជាមួដែលអង្គការសហប្រជាជាតិ ជាពិសេសទាក់ទងទៅនឹង :ការវេចខ្ចប់ និងការដាក់ផ្លាកសញ្ញាសំគាល់ទំនិញគ្រោះថ្នាក់. ការលាបពណ៌យានយន្ត ការលើកដាក់ រក្សាទុក និងការចងភ្ជាប់. ឯកសារ ដឹកជញ្ជូន និងសេចក្តីប្រកាស. ការហ្វឹកហាត់បណ្តុះបណ្តាលនាវិក និងការព្រមានប្រឆាំងទល់នឹងភ្លើងឆេះ និង/ ឬក៏ការ ជ្រុកទាំងឡាយ ។ ល ។

១១. ឧបសម្ព័ន្ធទី ៩ :លក្ខណៈវិនិច្ឆ័យសំរាប់ផ្តល់ចំណូលអនុញ្ញាតដល់ប្រតិបត្តិករដឹកជញ្ជូន សំរាប់ប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

ឧបសម្ព័ន្ធទី៩ នេះមាន ១៥មាត្រា ពាក់ព័ន្ធទៅនឹង សកម្មភាព លក្ខខ័ណ និងតំរូវការទាំងឡាយ ដែលត្រូវបំពេញដោយប្រតិបត្តិករដឹកជញ្ជូន ដើម្បីធ្វើសកម្មភាពប្រតិបត្តិការដឹកជញ្ជូន ដូចជាមូលដ្ឋាននៃការជ្រើសរើស ការផ្តល់អជ្ញាប័ណ្ណ ការគ្រប់គ្រងនិងប្រសិទ្ធភាពនៃសហគ្រាស ការដកហូតអជ្ញាប័ណ្ណ លក្ខខ័ណ្ឌជាមូលដ្ឋានសិទ្ធជាពលរដ្ឋនៃសហគ្រាស ប្រតិបត្តិការដឹកជញ្ជូន តំរូវការកាន់កាប់ភាគហ៊ុនចំនួនច្រើនជាង៥០% និងដឹកនាំដោយពលរដ្ឋភាគច្រើននៃប្រទេសដើមភាពអាចជឿទុកចិត្តបាន ការមិនធ្លាប់មានទទួលទោសទ័ណ្ឌចូន់ជូរណាមួយ ការដកហូតចេញពីឯកទេសជំនាញក្នុងការអនុវត្តន៍ការងារជាអ្នកដឹកជញ្ជូន ក៏ដូចជាការការដាក់ទណ្ឌកម្មក្នុងការប្រព្រឹត្តខុស ទៅនឹងការអនុវត្តច្បាប់ឬបទបញ្ញត្តិនៅក្នុងវិស័យដឹកជញ្ជូន ការប្រកាសអំពីការក្សីយធន សមត្ថភាពអនុវត្តឯកសិទ្ធិ ឬក៏ការដោះស្រាយថវិកា នៃប្រតិបត្តិករដឹកជញ្ជូន ការធ្វើនិតិសម្បទាឡើងវិញ ។ល។ ការចានាផ្សេងផ្គាត់សមត្ថភាពរបស់ប្រតិបត្តិករដឹកជញ្ជូន ឱ្យស្របទៅតាម គោលការណ៍គ្រប់គ្រងសេដ្ឋកិច្ច ការផ្តត់ផ្តង់សេវាប្រកបដោយគុណភាព ការប្រកួតប្រជែងដោយគុណភាព តំលាភាព និងប្រតិបត្តិការដោយសុវត្ថិភាពនៃសហគ្រាសដឹកជញ្ជូន ជំនាញនិងបំណិនប្រសប់ នៅក្នុងវិស័យដូចជាចំណេះដឹងខាងផ្លូវច្បាប់ ការគ្រប់គ្រងប្រតិបត្តិការដឹកជញ្ជូន ដែលពាក់ព័ន្ធទៅដល់ការធ្វើដំនូញខាងដឹកជញ្ជូន និតិវិធីខាងហិរញ្ញវត្ថុ បទបញ្ញត្តិនៃតំលៃ ការចានារ៉ាប់រង អជ្ញាកណ្តាលនៃការដឹកជញ្ជូន បច្ចេកទេសគ្រប់គ្រងនិងការរកទីផ្សារ លក្ខខ័ណ្ឌនិងតំរូវការ លើការចូលទៅរកទីផ្សារ ការយល់ដឹងអំពីជំនាញ ឯកសារដឹកជញ្ជូន ការប្រយុទ្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ វិធានការបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការដឹកជញ្ជូន ឧ. ទំហំ និងទំងន់នៃយានយន្ត ជំរើសយានយន្ត ការថែទាំយានយន្ត ការផ្ទុកលើកដាក់ និងផ្ទេរយានយន្ត. ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ និងទំនិញងាយខូចរលួយ គោលការណ៍នៃការការពារបរិស្ថាន សុវត្ថិភាពចរាចការព្រមាន និងការសំរាលគ្រោះថ្នាក់ចរាចរ ។ល។ សមត្ថភាពផ្នែកហិរញ្ញវត្ថុដូចជាប្រសិទ្ធភាពនិងការបំពេញតារាងតុល្យភាព តារាងទ្រព្យសម្បត្តិ ឥណទាន គណនីពីធនាគារ- សមត្ថភាពទទួលបានឥណទានកំចី- លិខិតចានារ៉ាប់រងពីធនាគារ- ការចានារ៉ាប់រង លើការទទួលខុសត្រូវ និងត្រូវមានការចានារ៉ាប់រងនៃប្រតិបត្តិករលើកិច្ចសន្យា ។

១២- ឧបសម្ព័ន្ធទី ១៣បេ: លក្ខណៈវិនិច្ឆ័យសំរាប់ផ្តល់អត្ថប្រយោជន៍ឬប្រតិបត្តិការដឹកជញ្ជូនពហុរូបភាព សំរាប់ប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

ឧបសម្ព័ន្ធទី ១៣បេនេះមាន ១៥មាត្រា ពាក់ព័ន្ធទៅនឹងសកម្មភាព លក្ខខ័ណ្ឌ តំរូវការ និងការអនុវត្តន៍លើការដឹកជញ្ជូនពហុភាពជាអន្តរជាតិដូចជា: សិទ្ធិ(ច្បាប់)ជាមូលដ្ឋាន ក្នុងការទទួលឬដកហូតអជ្ញាប័ណ្ណ និង/ឬការចុះបញ្ជី លក្ខខ័ណ្ឌច្បាប់និងបទបញ្ញត្តិជាតំរូវការទាំងឡាយផ្សេងទៀត ដោយគោរពទៅតាមសមត្ថភាពជំនាញ ប្រសិទ្ធភាព និងទំនុកចិត្តក្នុងវិជ្ជាជីវៈ ឬអាជីវកម្ម ការប្រកាសខ្លួនមិនធ្លាប់មានទទួលទោសទ័ណ្ឌធ្ងន់ធ្ងរណាមួយ ការដកហូតចេញពីឯកទេសជំនាញ ការដាក់ទណ្ឌកម្មក្នុងការប្រព្រឹត្តខុសទៅនឹងការអនុវត្តច្បាប់ ឬបទបញ្ញត្តិនៅក្នុងវិស័យដឹកជញ្ជូនផ្លូវគោក ការប្រកាសអំពីការក្ស័យធន សមត្ថភាពអនុវត្ត ឯកសិទ្ធិ ឬកំការដោះស្រាយថវិកា ការធ្វើនីតិសម្បទា ឡើងវិញ។ល។ សមត្ថភាពជំនាញក្នុងការយល់ដឹងគោលការណ៍គ្រប់គ្រងសេដ្ឋកិច្ចការផ្តត់ផ្តង់សេវាប្រកបដោយគុណភាព ការប្រកួតប្រជែងដោយតំលាភាព ប្រតិបត្តិការដោយសុវត្ថិភាពនៃសហគ្រាសដឹកជញ្ជូន ជំនាញបុិនប្រសប់នៅក្នុងវិស័យ ចំណេះដឹងខាងផ្លូវច្បាប់ (ឧ.កិច្ចសន្យាដឹកជញ្ជូន និងការទទួលខុសត្រូវ(ធានារ៉ាប់រង)របស់អ្នកដឹកជញ្ជូន កិច្ចសន្យាដឹកជញ្ជូនពហុភាព ច្បាប់សហគ្រាស ច្បាប់គណនេយ្យ ច្បាប់ពលកម្ម ច្បាប់សារពើពន្ធ ។ល។)ការគ្រប់គ្រងប្រតិបត្តិការ ដឹកជញ្ជូន(ឧ.ការគណនាតំលៃ និងថ្លៃដឹក ជញ្ជូន ការបង់ចំណាយ និងនីតិវិធីខាងហិរញ្ញវត្ថុ ការកែសំរួលតំលៃ ការធានារ៉ាប់រង អជ្ញាកណ្តាលនៃការដឹកជញ្ជូន បច្ចេកទេស គ្រប់គ្រង និងការរកទីផ្សារ) លក្ខខ័ណ្ឌ និងតំរូវការ លើការចូលទៅរកទីផ្សារ (ឧ. ការយល់ដឹងអំពីជំនាញឯកសារដឹកជញ្ជូន ការប្រកួតប្រជែងដោយល្អស្មោះត្រង់ ការប្រយុទ្ធប្រឆាំងនឹងការលក់បង្ហូចថ្លៃ វិធានការបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការដឹកជញ្ជូន (ឧ. ទំហំ និងទំងន់នៃយានយន្ត ឬនាវា ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ និងទំនិញងាយខូចរលួយ គោលការណ៍នៃការការពារបរិស្ថាន សំរាប់ការដឹកជញ្ជូន វិធានការសំរាប់សុវត្ថិភាព និងសន្តិសុខ ។ល។ សមត្ថភាពផ្នែកហិរញ្ញវត្ថុ ប្រសិទ្ធភាពនិងការចំពេញ តារាងតុល្យភាពរបស់ប្រតិបត្តិករដឹកជញ្ជូន តារាងទ្រព្យសម្បត្តិ ឥណទាន គណនីពីធនាគារ សមត្ថភាពទទួលបានឥណទានកំចី លិខិតធានារ៉ាប់រងពីធនាគារ ការធានារ៉ាប់រង លើការទទួលខុសត្រូវ និងត្រូវមានការធានារ៉ាប់រងនៃប្រតិបត្តិករលើកិច្ចសន្យា ។ប្រតិបត្តិការដឹកជញ្ជូនពហុភាព ត្រូវរក្សាទុកទ្រព្យសម្បត្តិអប្បរមា ដែលមានតំលៃស្មើនឹង៨0 000អែសដេអ៊ែរ (Special Drawing Right) ឬផ្តល់ការធានារ៉ាប់រងណាមួយដែលមានតំលៃស្មើ។


១៣- ឧបសម្ព័ន្ធទី ១៦ :លក្ខណៈវិនិច្ឆ័យសំរាប់ការផ្តល់ចំណូរបើកបរ

ឧបសម្ព័ន្ធទី១៦ នេះមាន ១៣មាត្រា ពាក់ព័ន្ធទៅនឹងតំរូវការ លិក្ខខ័ណ្ឌ និងការអនុវត្តន៍ក្នុងការទទួលស្គាល់ទៅវិញទៅមកនូវប័ណ្ណបើកបរក្នុងស្រុក រវាងភាគីចុះកិច្ចសន្យា សុពលភាព និងអត្ថិភាពប័ណ្ណបើកបរ ការភ្ជាប់ការបកប្រែបញ្ជាក់អំពីប័ណ្ណបើកបរ ចំណុចពិសេសនៃប័ណ្ណបើកបរ ទំនាក់ទំនងនិងការជូនដំណឹងគ្នាទៅវិញទៅមក ទៅកាន់អជ្ញាធរ ដែលចេញប័ណ្ណបើកបររវ៉ែងៗខ្លួន នូវអ្វីដែលមានការផ្លាស់ប្តូរ លើប័ណ្ណ។ល។

មានមាត្រាចាំបាច់មួយចំនួន ដែលស្ថិតនៅក្នុងអន្តរបញ្ញត្តិសំរាប់អនុវត្ត រាល់ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយខាងលើ(*ឧបសម្ព័ន្ធ១ ២.៤.៧.៩. ១១.១២. ១៣អា .១៣ប.១៥ .១៦ និងពិធីសារទី១*) ដូចជា : ការធ្វើវិសោធនកម្ម ការផ្តល់សច្ចាប័ន និងការយល់ព្រម ការចូលជាភាគី ការកែសំរួលច្បាប់ជាតិ ការដាក់លក្ខខ័ណ្ឌ ការព្យួរទុកនៃឧបសម្ព័ន្ធ ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងមេ តំលៃឬទំនាក់ទំនង រវាងឬជាមួយឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធ ការដោះស្រាយជំលោះ ការប្រកាសបដិសេធ ។ល។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងសាធារណការ និងដឹកជញ្ជូន

ឧបសម្ព័ន្ធ និងពិធីសារ

១-ឧបសម្ព័ន្ធទី១ :ការដឹកជញ្ជូនទំនិញព្រំដែនផ្ទាល់

២-ឧបសម្ព័ន្ធទី២ :ការចុះបញ្ជីយានយន្ត ទៅក្នុងចរាចរអន្តរជាតិ

៣-ឧបសម្ព័ន្ធទី៤ :ការសំរបសំរួលបែបបទឆ្លងកាត់ព្រំដែន

៤-ឧបសម្ព័ន្ធទី៧ :បទបញ្ជត្តិចរាចរតាមផ្លូវថ្នល់ និងផ្ទាំកសញ្ញា

៥-ឧបសម្ព័ន្ធទី៩ :លក្ខណៈវិនិច្ឆ័យសំរាប់ការចេញអាជ្ញាប័ណ្ណឱ្យប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

៦-ឧបសម្ព័ន្ធទី១១:បទដ្ឋាន ឬមាត្រដ្ឋាន(ស្តង់ដារ) និងលក្ខណៈបច្ចេកទេស

៧-ឧបសម្ព័ន្ធទី១២:សៀវ៉ា និងសម្បទា(ឬមច្ឆាបាយ) សំរាប់ការឆ្លងកាត់ និងការឆ្លងព្រំដែន

៨-ឧបសម្ព័ន្ធទី១៣អា:របបត្រួតត្រាការទទួលខុសត្រូវ អ្នកដឹកជញ្ជូនពហុភាគ

៩-ឧបសម្ព័ន្ធទី១៣បេ: លក្ខណៈវិនិច្ឆ័យសំរាប់ការចេញអាជ្ញាប័ណ្ណឱ្យប្រតិបត្តិការដឹកជញ្ជូនពហុភាគ

១០-ឧបសម្ព័ន្ធទី១៥: ប្រព័ន្ធចាត់ថ្នាក់ទំនិញ

១១-ឧបសម្ព័ន្ធទី១៦: លក្ខណៈវិនិច្ឆ័យសំរាប់ការចេញប័ណ្ណបើកបរ

១២-ពិធីសារទី១:ការកំណត់ផ្លូវ និងផ្លូវរបៀង ព្រមទាំងចំណុចចេញ-ចូល(ការឆ្លងកាត់ព្រំដែន)

១៣-វិសោធនកម្មមាត្រាទី១៧ នៃកិច្ចព្រមព្រៀង GMS សំរួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

សំរាប់អនុវត្តកិច្ចព្រមព្រៀង GMS

ស្តីពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

នាយកដ្ឋានផែនការ

សីហា ឆ្នាំ ២០០៦

ឧបសម្ព័ន្ធទី ១
ការដឹកជញ្ជូនឆ្លងព្រំដែន
ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត្យឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍
និងសាធារណរដ្ឋសង្គមនិយមវៀតណាម
ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនចំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន
(តទៅហៅកាតថា ឧបសម្ព័ន្ធ)

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាព មីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋ សង្គមនិយមវៀតណាម (តទៅហៅកាត់ថា" ភាគីចុះកិច្ចសន្យា")

ដោយយោងទៅលើ កិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនចំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាកំបូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០១ នៅយ៉ាងហ្គូន . ដែលបានយល់ព្រមចូលដោយព្រះរាជាណាចក្រកម្ពុជា នៅយ៉ាងហ្គូន នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០១ បានយល់ព្រមចូលដោយសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូល ដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី ហើយបានធ្វើវិសោធនកម្មនៅភ្នំពេញថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៤តទៅហៅកាត់ថា" កិច្ចព្រមព្រៀង"

ដោយយោងទៅលើមាត្រាទី ៣(បេ) និង(អិន) នៃកិច្ចព្រមព្រៀង ដែលបានចែងថា ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយ ដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលកំណត់លក្ខណៈពិសេស ទៅតាមទីកន្លែង ហើយដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង និងមានតំណែចូលរួមស្មើៗគ្នា

ដោយយោងទៅលើ មាត្រាទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានធ្វើវិសោធនកម្មរួចហើយ ដែលឧបសម្ព័ន្ធ និងពិធីសារនិមួយៗអាចត្រូវបានគេចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីគ្នា ដាច់ចេញអំពីកិច្ចព្រមព្រៀង

ដោយយោងទៅលើ កិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានីលឡា ក្នុងខែមករា ឆ្នាំ ២០០០. កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តិទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ ២០០២ និងកិច្ចប្រជុំលើកទី១១ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ ២០០២ ដែលរដ្ឋមន្ត្រី GMS ទាំងអស់បានឯកភាពយល់ព្រមទៅនឹងផែនការការងារមួយ ក្នុងការបង្ហើយបញ្ចប់កិច្ចព្រមព្រៀង និងឧបសម្ព័ន្ធ ពិធីសារ របស់វា ក្នុងឆ្នាំ ២០០៥ និង

ដោយយោងទៅលើ អាត្រាទី៣(អ៊ី) និង១០(អា) នៃកិច្ចព្រមព្រៀង ដែលបានស្នើឱ្យផ្តល់តាមរយៈឧបសម្ព័ន្ធនេះ នូវការរៀបចំលំអិត ខាងបច្ចេកទេស

បានព្រមព្រៀងគ្នាដូចខាងក្រោម :

មាត្រា ១ .- និយមន័យ

ពាក្យថា " ទំនិញគ្រោះថ្នាក់ " មានន័យថា សារធាតុ និង វត្ថុធាតុទាំងឡាយ ដែលមានឥទ្ធពលទៅលើ បរិស្ថាន សុខភាព សុវត្ថិភាព និងសន្តិសុខជាតិ។

មាត្រា ២ .- ការចាត់ថ្នាក់នូវទំនិញគ្រោះថ្នាក់

ក-ទំនិញគ្រោះថ្នាក់ទាំងឡាយ ត្រូវបានគេបែងចែកទៅតាមចំណាត់ថ្នាក់ ឬផ្នែកដូចខាងក្រោម :

ចំណាត់ថ្នាក់ទី ១ : គ្រឿងផ្ទុះ (Explosives)

ចំណាត់ថ្នាក់ទី ២ : ឧស្ម័ន (Gases)

ផ្នែកទី ២-១ : ឧស្ម័នអាចឆេះ (Flammable Gases)

ផ្នែកទី ២-២ : ឧស្ម័នដែលមិនអាចឆេះ-មិនមានជាតិពុល (Non-flammable, Non-toxic gases)

ផ្នែកទី ២-៣ : ឧស្ម័នពុល (Toxic gases)

ចំណាត់ថ្នាក់ទី ៣ : វត្ថុរាវអាចឆេះ និងវត្ថុរាវដែលងាយទឹងផ្ទុះ (Flammable Liquids and desensitized explosives)

ចំណាត់ថ្នាក់ទី ៤ : ផ្នែកទី ៤-១ : វត្ថុរឹងអាចឆេះ, សារធាតុដែលបញ្ចេញវិទ្យុសកម្មដោយឯកឯង និងវត្ថុធាតុរឹងដែលងាយបង្កឱ្យផ្ទុះ (Flammable Solids self-reactive substances and solid desensitized explosive)

ផ្នែកទី ៤-២ : សារធាតុដែលអាចមានចំហេះដោយឯកឯង (Substances liable to spontaneous combustion)

ផ្នែកទី ៤-៣ : សារធាតុទាំងឡាយដែលមានប្រតិកម្មជាមួយទឹកអាចបញ្ចេញឧស្ម័នឆេះ (Substances which in contact with water emit flammable gases)

ចំណាត់ថ្នាក់ទី ៥ : ផ្នែកទី ៥-១ : សារធាតុឱអុកស៊ីត (Oxidizing substances)

ផ្នែកទី ៥-២ : សរីរាង្គពីរ៉ុកស៊ីដ (Organic peroxide)

ចំណាត់ថ្នាក់ទី ៦ : ផ្នែកទី ៦-១ : សារធាតុពុល (Toxic substances)

ផ្នែកទី ៦-២ : សារធាតុឆ្លង (Infectious substances)

ចំណាត់ថ្នាក់ទី ៧ : គ្រឿងវិទ្យុសកម្ម (Radioactive material)

ចំណាត់ថ្នាក់ទី ៨ : សារធាតុដែលស៊ី ឬ កាត់ (អាស៊ីត) (Corrosive substances)

ចំណាត់ថ្នាក់ទី ៩ : សារធាតុ និងអង្គធាតុគ្រោះថ្នាក់ផ្សេងទៀត (Miscellaneous dangerous substances and articles)

ខ- ការចាត់ថ្នាក់ទំនិញគ្រោះថ្នាក់ ទៅតាមប្រភេទចំណាត់ថ្នាក់ និងផ្នែកដូចខាងលើ ត្រូវធ្វើឡើងស្របទៅតាមផ្នែកទី ២ នៃអនុសាន៍របស់អង្គការសហប្រជាជាតិ ស្តីអំពីការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ ឬក៏ម៉ូដែល បទប្បញ្ញត្តិ (ម៉ូដែលជាបទ ប្បញ្ញត្តិអង្គការសហប្រជាជាតិ) និង ឬ កិច្ចព្រមព្រៀងអឺរុប ពាក់ព័ន្ធទៅនឹងការ ដឹកជញ្ជូនទំនិញគ្រោះថ្នាក់ នៅតាមផ្លូវថ្នល់ (អាដេអឺរ) ដែលចុះហត្ថលេខានៅទីក្រុងហ្សឺណែវ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ១៩៥៧ រាប់ទាំង ការធ្វើវិសោធនកម្មក្រោយៗមក និងទៅខាងមុខ ជងដែរ ។

មាត្រា ៣ .- បទដ្ឋាន(ស្តង់ដារ) ជាការណែនាំ ចលនាឆ្លងកាត់ព្រំដែន នូវទំនិញគ្រោះថ្នាក់

ប្រសិនបើ ភាគីចុះសន្យា អនុញ្ញាត ទៅតាមមូលដ្ឋាន ពីមួយករណីទៅមួយករណី ការធ្វើចរាចរឆ្លងកាត់ ព្រំដែន នូវទំនិញដូចបានកំណត់ខាងលើ ទាមទារការអនុវត្តយ៉ាងពេញលេញនូវវិធានការទាំងឡាយ ដែលស្ថិតនៅក្រោម អាវេអ៊ែរ និង/ឬ បទប្បញ្ញត្តិជាមូដែលអង្គការសហប្រជាជាតិ ជាពិសេសទាក់ទងទៅនឹង :

ក- ការវេចខ្ចប់ និងការដាក់ផ្លាកសញ្ញាសំគាល់ទំនិញគ្រោះថ្នាក់

ខ- ការលាបពណ៌យានយន្ត ការលើកដាក់ រក្សាទុក និងការចងភ្ជាប់

គ- ឯកសារដឹកជញ្ជូន និងសេចក្តីប្រកាស

ឃ- ការហ្វឹកហាត់បណ្តុះបណ្តាលនាវិក

ង- ការព្រមានប្រឆាំងទល់នឹងភ្លើងឆេះ និង/ ឬក៏ការផ្ទុកទាំងឡាយ

មាត្រា ៤.- ការធ្វើវិសោធនកម្ម

ភាគីចុះកិច្ចសន្យាណាមួយក៏ដោយ អាចស្នើធ្វើវិសោធនកម្ម លើឧបសម្ព័ន្ធ តាមរយៈគណៈកម្មាធិការរួម។ ការធ្វើវិសោធនកម្មនោះ ត្រូវតែជាកម្មវត្ថុនៃការឯកភាពគ្នាជាឯកច្ឆន ពីភាគីចុះកិច្ចសន្យាទាំងអស់។

មាត្រា ៥.- ការផ្តល់សច្ចាប័ន និងការយល់ព្រម

ឧបសម្ព័ន្ធនេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រម នៃរដ្ឋាភិបាលទាំងឡាយដែលជាភាគីចុះកិច្ចសន្យា។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន។

មាត្រា ៦.- ការចូលជាធរមាន

ឧបសម្ព័ន្ធ នឹងត្រូវចូលជាធរមាន នៅថ្ងៃដែល ០២ភាគីចុះកិច្ចសន្យាយ៉ាងតិច បានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់វា នឹងត្រូវមានប្រសិទ្ធភាពត្រឹមតែក្នុងរង្វង់ភាគីចុះកិច្ចសន្យា ដែលបានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់ឧបសម្ព័ន្ធ។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន។

មាត្រា ៧.- ការកែសំរួលច្បាប់ជាតិ

នៅចំណុចណាដែលចាំបាច់ ភាគីចុះកិច្ចសន្យា ត្រូវបានធ្វើការកែសំរួលច្បាប់ជាតិដែលពាក់ព័ន្ធ ឱ្យស្រប ទៅតាមខ្លឹមសារនៃឧបសម្ព័ន្ធ។

មាត្រា ៨.- ការដាក់លក្ខខ័ណ្ឌ

ការដាក់លក្ខខ័ណ្ឌ ទៅលើឧបសម្ព័ន្ធ មិនត្រូវបានគេអនុញ្ញាតិឡើយ ។

មាត្រា ៩.- ការព្យួរទុកនៃឧបសម្ព័ន្ធ

ភាគីចុះកិច្ចសន្យានិមួយ។អាចព្យួរទុក ជាបណ្តោះអាសន្ន-នូវការអនុវត្តន៍ឧបសម្ព័ន្ធទាំងស្រុង ឬក៏មួយចំណែក ដែលមានប្រសិទ្ធិភាពភ្លាម។ នៅក្នុងករណីមានការរីកវាលជាអាសន្ន ដែលប៉ះពាល់ដល់សុវត្ថិភាពរបស់ជាតិខ្លួន។ ភាគីចុះកិច្ចសន្យា នឹងជូនពត៌មានទៅភាគីចុះកិច្ចសន្យាផ្សេងទៀត ភ្លាម តាមតែអាចធ្វើទៅបាន អំពីការព្យួរទុកនេះ និងការបញ្ចប់ការព្យួរទុកនេះ ឱ្យបានឆាប់បំផុត នៅពេលណា ដែលសភាពការណ៍ វិលត្រឡប់ទៅរកស្ថានភាពជាធម្មតាឡើងវិញ។

មាត្រា ១០.- ទំនាក់ទំនង ជាមួយកិច្ចព្រមព្រៀង

ដោយសារតែវាជាវិធានការមួយក្នុងការអនុវត្តន៍គោលការណ៍ទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ឧបសម្ព័ន្ធនេះមិនអាចផ្តាច់ចេញ ឬក៏ក្លាយជាជំនួសទៅនឹងគោលការណ៍ទាំងនោះ ។ នៅក្នុងករណីដែល វិសមិត(មិនចុះសំរុងគ្នា-មិនស៊ីគ្នា) រវាងឧបសម្ព័ន្ធ និងកិច្ចព្រមព្រៀង នោះកិច្ចព្រមព្រៀងត្រូវយក

ជាបានការ។ នៅក្នុងករណីដែលវិសមិត(មិនចុះសំរុងគ្នា-មិនស៊ីគ្នា) រវាងឧបសម្ព័ន្ធ និងឧបសម្ព័ន្ធ ឬ ពិធីសារផ្សេងទៀតនោះ វិសមិតភាពនេះ ត្រូវយកទៅបកស្រាយជាមួយគ្នា នឹងកិច្ចព្រមព្រៀង។

មាត្រា ១១.- ការដោះស្រាយបំណោះ

ជំលោះរវាងភាគី០២ ឬច្រើន នៃភាគីចុះកិច្ចសន្យា នៅលើការបកស្រាយ ឬការអនុវត្តន៍ឧបសម្ព័ន្ធ ត្រូវរុះស្រួលគ្នា លើកយកមកដោះស្រាយដោយផ្ទាល់ ឬដោយការចរចារតាមគោលការណ៍សន្តិវិធី តាមរយៈគណៈកម្មាធិការរួម។

មាត្រា ១២.- ការប្រកាសបដិសេធ

នៅពេលណាដែលចូលជាជាមាន ឧបសម្ព័ន្ធមិនអាចឱ្យគេប្រកាសបដិសេធដាច់ដោយឡែក ចេញអំពី កិច្ចព្រមព្រៀងបានទេ។

ដើម្បីជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដែលបានទទួលការអនុញ្ញាតពីអជ្ញាធររៀងៗខ្លួន បានចុះហត្ថលេខាលើឧបសម្ព័ន្ធនេះ ។

ធ្វើនៅ វៀងចន្ទ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤ ជាច្បាប់ដើម ជាភាសាអង់គ្លេស ។

ហត្ថលេខា :

តំណាងរាជរដ្ឋាភិបាលកម្ពុជា

ឯកឧត្តម **ឃី តាំងលីម** ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីទទួលបន្ទុកសហប្រតិបត្តិការមហាអនុតំបន់មេគង្គ

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

ឯកឧត្តម **លាវ សាវយន់** អនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ង- ប្រវែងកាំនៃកំណោងផ្តេក ឬស្របនៃផ្លូវដែលជាលំនាំគំរូ ឬជាអានុសាសន៍ នៅក្នុងតំបន់ទីប្រជុំជន មានដូចខាងក្រោម :

ផ្លូវកិរិតចំបង	២៣០ម
ផ្លូវកិរិតទី១	១២០ម
ផ្លូវកិរិតទី២	៧៥ម
ផ្លូវកិរិតទី៣	៥០ម

មាត្រា ៧.- កំណោងបញ្ឆរ ឬកែងនៃផ្លូវ (ទៅនឹងផែនដី)

ក- កំណោងបញ្ឆរ ឬកែងនៃផ្លូវ Highway ណាមួយក៏ដោយ ត្រូវមានភាពរលូន ដូចគ្នាទៅនឹងលទ្ធភាពសេដ្ឋកិច្ចរបស់វា ដែលត្រូវឱ្យមានតុល្យភាពមួយ នៃការច្សៃ ឬចិត និងការចាក់បំពេញ ដើម្បីបំបាត់ឬសំរួល ដីជំរាលខ្ពង់រាបឡើងចុះ តាមធម្មជាតិរបស់សណ្ឋានភាពដី។ ក្នុងការប្រើប្រាស់ ជំរាលបញ្ឆរ ឬកែង (ទៅនឹង ផែនដី) អតិបរមា អ្នកលើកគំរោងប្លង់ត្រូវចងចាំក្នុងចិត្តច្បាស់លាស់ថា នៅពេលគេធ្វើការសាងសង់ ទៅតាម កិរិតបញ្ឆរ ឬកែងដែលគេផ្តល់ឱ្យណាមួយ ផ្លូវផ្តល់មិនអាចឱ្យគេលើកកិរិត អន់ជាងជំរាលមួយដោយមិន មានឃាត់បង់នូវការផ្តួចផ្តើមការវិនិយោគទាំងមូល។ ជំរាលកែងឬបញ្ឆរ (ទៅនឹងផែនដី) អតិបរិមាដែល មាននៅក្នុងតារាងទី១ មាត្រាទី១ ត្រូវបានគេទទួលយកទៅប្រើប្រាស់។ ប្រវែងខ្សែរកំណោងបញ្ឆរ ឬកែង (ទៅនឹងផែនដី) អប្បបរមានៃផ្លូវ ត្រូវបានគេគណនាដោយផ្អែកទៅលើ កិរិតពិជគណិតខុសគ្នាល្បឿនគ្រោង ទុក និងរយៈចំងាយតំរូវការអប្បរមាសំរាប់បញ្ឈប់យាន ដែលអាចមើលឃើញបាន ។

ខ- ប្រវែងចាំបាច់របស់ផ្នែកនៃជំរាល សំរាប់ជាការផ្តល់ឱ្យចំនែកផ្លូវឡើងជំរាលមួយ ត្រូវបានគេណែនាំជាអានុសាសន៍ ចំពោះចំណាត់ថ្នាក់ផ្លូវថ្នាក់ចំបង និងផ្លូវកិរិតទី១ ដូចមានបង្ហាញក្នុងតារាងទី៥។ វាតំរូវឱ្យមានការផ្តល់ ចំនែកផ្លូវឡើងជំរាលមួយ ទៅលើផ្លូវផ្តល់ដែលមានចំណោតឡើង ទៅតាមចរាចរយានយន្តដឹកទំនិញធុនធ្ងន់ ដែលប្រវែងនៃជំរាល ឬចំណោតនោះ វែងលើសតំលៃខាងលើ។

តារាងទី៥

ប្រវែងសំខាន់ៗនៃផ្នែកដម្រាលសំរាប់គណនា ចំណែកប្រេះឆ្មាះផ្លូវចំណោតមួយ

ចំណាត់ថ្នាក់តាមលក្ខណៈភូមិសាស្ត្រដី	ផ្លូវកិរិតចំបង	ផ្លូវកិរិតទី១	សំគាល់
ដីរាបស្មើ ឬ Level (L)	៣%-៨០០ ម	៣%-៥០០ ម	បទដ្ឋាន ឬស្តង់ដារជាតិអាចត្រូវបានគេយល់ព្រម. ឧទាហរណ៍ អាស្រ័យទៅលើទំហំ។
	៤%-៥០០ ម	៤%-៧០០ ម	
ដីខ្ពង់រាប-ឡើងចុះ ទីជំរាលឬ Rooling (R)	៤%-៧០០ ម	៤%-៨០០ ម	
	៥%-៥០០ ម	៥%-៦០០ ម	
ដីតំបន់ភ្នំ ឬ Mountain (M)	៥%-៦០០ ម	៥%-៧០០ ម	
	៦%-៤០០ ម	៧%-៤០០ ម	

មាត្រា ៨.- គំរាលថ្នល់

ក- ទ្រុងផ្លូវត្រូវបានគេក្រាលដោយចាក់បេតុងអាមេរ ឬអ៊ុតបេតុងកៅស៊ូ។ មានករណីតែមួយប៉ុណ្ណោះគឺនៅពេលដែលបរិមាណចរាចរ ដែលគេប្រមើលមើលជាមុនមានចំនួនតិចពេកនោះ គេបានឯកភាពឱ្យប្រើប្រាស់ការចាក់កៅស៊ូជាគំរាលថ្នែលើវិញ។ មានគំរូណែនាំ ឬអនុសាសន៍ផងដែរថា គំរាលចិញ្ចើមថ្នល់ ត្រូវក្រាលដោយ បេតុងអាមេរ ឬបេតុង កៅស៊ូ ឬក៏ក្រាលគ្របថ្នែលើដោយសំភារៈកៅស៊ូ ឬចាក់កៅស៊ូ ។

ខ- គំរាលថ្នល់ ត្រូវបានគេលើកគ្រោងឡើង ដោយគិតគូរពិចារណា អំពី : (i) បន្ទុកលើកង់អតិបរិមា ដែលត្រូវមានមូលដ្ឋានទៅលើ បទដ្ឋាន ឬស្តង់ដារបស់រថយន្តដឹកទំនិញ (ii) បរិមាណចរាចរ (iii) អាយុកាលគ្រោងទុកនៃថ្នល់ និង(iv) គុណភាពសំភារៈសំណង់ដែលត្រូវប្រើប្រាស់ ។

មាត្រា ៩.- ស្ពាន និងលូបង្ហូរទឹក

ស្ពាន និងលូបង្ហូរទឹកគួរតែត្រូវបានគេសាងសង់ ជារចនាសំព័ន្ធមានលក្ខណៈអចិន្ត្រៃយ៍ ។ ចំពោះស្ពានតូច១ ដែលខ្ពើជាង៥០ម ត្រូវសាងសង់ឡើងដោយឱ្យទទឹងផ្លូវ ពេញស្មើនឹងទទឹងស្ពានស្ពានទាំងមូល ដោយគិតសរុបទាំងទទឹងចិញ្ចើមផងដែរ ។ សំរាប់ស្ពានធំ១ ដែលមាន ប្រវែងវែងជាង ៥០ម នោះ ទទឹងស្ពានអប្បរមា ដែលស្ថិតនៅចន្លោះរវាងតែមទាំងសងខាង ត្រូវមានទទឹងប្រវែង ១.៥ម ធំជាងកំរាលផ្លូវ នៃផ្លូវចូលស្ពាននោះ ។ផ្លូវដើរដែលមានទទឹងប្រវែង១ម ត្រូវបានគេផ្តល់ជាអនុសាសន៍ ឱ្យមានឡើងសំរាប់ស្ពានទាំងអស់ ប៉ុន្តែសំរាប់ ចំណែកស្ពានដែលវែង ផ្លូវដើរនេះអាចត្រូវបានគេកំរិតឱ្យស្ថិតនៅត្រឹមតែមួយចំហៀងស្ពាន តែម្យ៉ាងគត់ ។

មាត្រា ១០.- ចនាសម្ព័ន្ធនៃបន្ទុក

ក- ការកើនឡើងចរាចរធុនធ្ងន់ ជាពិសេសចរាចរដឹកកុងតឺណ៊ែ ត្រូវការគូសគ្រោងសមត្ថភាពបន្ទុកយ៉ាងត្រឹមត្រូវ (បន្ទុកនៃភ្លៅ ឬអ័ក្សអតិបរិមា) ។ ក្នុងគោលបំណងដើម្បីព្រមានទុកជាមុន និងការពារការខូចខាតដ៏ធ្ងន់ធ្ងរចំពោះរចនា សម្ព័ន្ធនៃផ្លូវថ្នល់ និងដើម្បីកាត់បន្ថយផងដែរនូវការចំនាយក្នុងការថែរទាំនោះ ផ្លូវដឹកជញ្ជូនិងផ្លូវរបៀងទាំងឡាយ ដែលបានកំណត់ក្នុងពិធីសារទី១ នៃកិច្ចព្រមព្រៀង ដែលជាបណ្តាញផ្លូវថ្នល់អន្តរជាតិនោះ ត្រូវមានសមត្ថភាពផ្ទុកគ្រោងទុកខ្ពស់ ។

ខ- បន្ទុកគ្រោងទុកអប្បបរមា នៃ HS20-44 ដែលរ៉ាជាបទដ្ឋាន ឬស្តង់ដារអន្តរជាតិ ឆ្លើយតបទៅនឹង បន្ទុកនៃយានសណ្តោងពេញទំហំ ត្រូវបានគេប្រើប្រាស់សំរាប់ លើកតំរោងរចនាសម្ព័ន្ធផ្លូវថ្នល់ ។ បទដ្ឋាន ឬស្តង់ដារជាតិក៏អាចត្រូវបានគេយកមកប្រើប្រាស់ផងដែរ ។

មាត្រា ១១.- កំពស់ លំហឬច្រកលោះ (បញ្ឈរ)សុវត្ថិភាពបំរុងទុក សំរាប់ស្ពាន

លំហបញ្ឈរសុវត្ថិភាពបំរុងទុកអប្បរមាត្រូវមានប្រវែង៤.៥០ម ដែលជាតំរូវការសំរាប់ ដំនើរឆ្លងកាត់នៃយានយន្តដោយសុវត្ថិភាព ចំពោះកុងតឺណ៊ែដែលមានស្តង់ដារ ISO ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីដែល លំហបញ្ឈរសុវត្ថិភាពបំរុងទុកគ្រប់គ្រាន់ មិនអាចរកបាន ឬធ្វើបាន ដោយសារតែតំលៃខ្ពស់ក្នុងការកសាងឡើងវិញនូវរចនាសម្ព័ន្ធដែលមានស្រាប់ទាំងឡាយនោះ ដូចជាស្ពាន. យានសណ្តោងដែលមានទំរង់ជាកញ្ចាន់ ទាំងឡាយ ដែលមានកំរិតកំពស់បំរុងនៃទ្រុង ឬពោះយានទាប។ អាចត្រូវបានគេប្រើប្រាស់ ។

ជាទូទៅកំពស់ប្រឡោះបញ្ឈរបំរុងទុកនៃយាន តំរូវមានកំរិតត្រឹម ៥មជាពិសេសនៅលើផ្លូវកំរិតចំបងនៅតាមបណ្តោយ ផ្លូវដឹកជញ្ជូន និងផ្លូវរបៀងទាំងឡាយ ដែលបានកំណត់ក្នុងពិធីសារទី១ នៃកិច្ចព្រមព្រៀងដែលនឹងត្រូវបានគេសាងសង់ និងធ្វើឱ្យប្រសើរឡើងនាពេលខាងមុខ។

មាត្រា ១២.- គ្រឿងប្រដាប់ចំណាត់នៅតាមផ្លូវថ្នល់ ដែលជាការណែនាំ-ជាអនុសាសន៍

ភាគីចុះកិច្ចសន្យានឹងពិចារណាក្នុងការរៀបចំ និងបំពាក់នូវ គ្រឿងប្រដាប់បំពាក់នៅតាមផ្លូវថ្នល់ តាមការណែនាំ-ជាអនុសាសន៍ ដូចខាងក្រោម ដែលជាតំរូវការដើម្បីសុវត្ថិភាពនិងយោងទៅតាមចំណាត់ថ្នាក់នៃផ្លូវ Highway មានដូចតទៅ :

ក-ការតុបតែងភ្លើងបំភ្លឺ

(i) នៅក្នុងតំបន់ពិសេសមួយចំនួនដូចជាប៉ុស្តិ៍ត្រួតពិនិត្យច្រកព្រំដែន ផ្លូវរួង ឬស្ពានវែងៗតំបន់ដែលជាប់ៗគ្នាទាំងឡាយ ហើយនិងផ្លូវកាត់ខ្វែងគ្នាជាមួយផ្លូវផ្សេងៗទៀត ។

(ii) ផ្នែកផ្សេងៗទៀតទាំងឡាយផងដែរនៃផ្លូវ ដែលអាចតំរូវឱ្យមានការបំពាក់ភ្លើងបំភ្លឺ ជាប់ស្មើគ្នា ។

ខ-គ្រឿងឧបករណ៍ប្រឆាំងនឹងការចាំងពន្លឺ :

នៅផ្នែកខាងក្រៅ នៃទ្រុងមេដ្យានតូច-ចង្អៀតនៃផ្លូវដែលត្រូវមានការតុបតែងគ្រឿងឧបករណ៍ប្រឆាំងនឹងការចាំងពន្លឺ ការដាក់របាំង-សំណាញ់សិប្បនិមិត្ត ឬរបងកូនឈើ នៅលើតំនូសចែកកណ្តាលផ្លូវ ឬតំនូសចិញ្ចើម ដើម្បីបាំងការពារភ្លឺ រវើង ២គ្នា ចេញពីទ្រុងផ្លូវ បញ្ច្រាសទិសគ្នា ឬពីផ្លូវដែលស្របគ្នាមួយ

គ-ចំណែកផ្លូវដែលត្រូវពង្រីកបន្ថែម ឬ បង្រួមបញ្ចូល

ចំណែកផ្លូវទាំងឡាយដែលរីក-បែកចេញ ឬរួមចូល សំរាប់ការចូលទៅ ឬចេញពី ម៉ូតូវេយ ឬ អ៊ិចប្រេសវេយ ។

ឃ-តំនូសសំរាប់បញ្ឈប់យានយន្តបន្ទាន់ (ចិញ្ចើមផ្តល់ដែលមានល័ខ័ន)

នៅលើផ្លូវ Highway ក៏រឹតចំបង និងក៏រឹតទី១ នូវតំនូសជាប់ៗបន្តគ្នាមានថិរភាពមានល័ខ័ន និងមានកំរាលចាក់កៅស៊ូ នៅលើចិញ្ចើមផ្តល់ សំរាប់បញ្ឈប់យានយន្តពេលមានគ្រោះបន្ទាន់ ។

ង-បន្ទះការពារ ឬបង្គោលទំនប់

ក្នុងគោលបំណងដើម្បីធានានូវសុវត្ថិភាពចំពោះឡានដឹកទំនិញធំៗនៅតាមបណ្តោយជម្រាលចំណោតភ្នំ ហើយចំងាយ ឆ្ងាយ ដែលនៅទីនោះពុំមានវិធានផ្សេងទៀតអាចធ្វើបាននោះ មានការណែនាំ ជាអានុសាសន៍ ក្នុងការសាងសង់ បន្ទះការពារ ឬបង្គោលទំនប់ សំរាប់ចំណែកផ្លូវចុះភ្នំ ។

ច-របងសុវត្ថិភាព និងរបាំងការពារ

របាំងកែកការពារ របាំងពេលមានគ្រោះថ្នាក់ របាំងការពារសុវត្ថិភាព និងរបង ដែលត្រូវបានតេតំឡើងសំរាប់ព្រមានទុកជាមុន នូវយានយន្តទាំងឡាយ ឱ្យដាច់ចេញពី ការរក្សាទុកទ្រុងផ្លូវដែលមានគ្រោះថ្នាក់ ឬការទាញអារម្មណ៍ ភ័យខ្លាច ។

ឆ-ចំនុចប្រសព្វនៃផ្លូវអោយស្ម័យយាន

នៅតាមកំរិតថ្នាក់ដែលខុសគ្នា (ស្ពាន ឬផ្លូវរួង-ខ្ពុម្ពង់ និងផ្លូវក្រោមដី) ផ្លូវម៉ូតូវេយ ផ្លូវអ៊ិចប្រេសវេយ និងហាយវេយ ដោយមានបរិមាណចរាចរ និងរទេះភ្លើងខ្ពស់ ។

ជ-កិច្ចការពារពីការឆ្លងកាត់របស់សត្វពាហនៈ

(1) របងចរាចរគួរតែតំឡើងនៅតាមកន្លែងណា ដែលជាកន្លែងប្រថុយប្រថានិងគ្រោះថ្នាក់ ដោយការឆ្លងកាត់ របស់សត្វពាហនៈ ។

(2) វាមានលក្ខណៈសមស្របផងដែរ ដែលសត្វទាំងអស់គួរតែត្រូវបានផ្តល់អោយនូវការឆ្លងកាត់នៅពីខាងលើ រឺ ពីខាងក្រោម ។

ឈ-ប្រពន្ធ័ទំនាក់ទំនងជាបន្ទាន់

បន្ទប់ ឬបញ្ជារទូរស័ព្ទបន្ទាន់ ត្រូវបំពាក់នៅតាមបណ្តោយផ្លូវ និងតភ្ជាប់ទៅនឹងការីប្រតិបត្តិទូរស័ព្ទកណ្តាលមួយ ក្នុងរយៈពេលពេញមួយថ្ងៃលើមួយថ្ងៃ (២៤ម៉ោង) ជាពិសេសនៅលើកផ្លូវកំរិតចំបង ។

ញ-បរិធាន បរិការ-ឬមធ្យោបាយផ្តល់សេវាកម្ម និងកន្លែងឈប់សំរាកទាំងឡាយ

កន្លែងឈប់សំរាក ដែលមានបំរើបរិធាន-មធ្យោបាយសេវាកម្មផ្សេងៗ (ដូចជា ទីធ្លាចំណតរថយន្ត ស្ថានីយប្រេង និងស្ថានីយជួសជុលថែទាំយានយន្ត មជ្ឈមណ្ឌលទូរគមនាគមន៍ បរិក្ខារអនាម័យ (បង្គន់) សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន) ត្រូវសាងសង់ឡើង ស្របពេលនឹងការសាងសង់ផ្លូវ ។

មាត្រា ១៣.- ការធ្វើវិសោធនកម្ម ឬ ការកែប្រែ

ភាគីចុះកិច្ចសន្យាណាមួយក៏ដោយ អាចស្នើធ្វើវិសោធនកម្ម លើឧបសម្ព័ន្ធ តាមរយៈគណៈកម្មាធិការរួម។ ការធ្វើវិសោធនកម្មនោះ ត្រូវតែជាកម្មវត្ថុនៃការឯកភាពគ្នាជាឯកច្ឆ័ន ពីភាគីចុះកិច្ចសន្យាទាំងអស់។

មាត្រា ១៤.- ការផ្តល់សច្ចាប័ន និងការយល់ព្រម

ឧបសម្ព័ន្ធនេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រម នៃរដ្ឋាភិបាលទាំងឡាយដែលជាភាគីចុះកិច្ចសន្យា។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន។

មាត្រា ១៥.- ការចូលជាធរមាន

ឧបសម្ព័ន្ធ នឹងត្រូវចូលជាធរមាន នៅថ្ងៃដែល ០២ភាគីចុះកិច្ចសន្យាយ៉ាងតិច បានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់វា នឹងត្រូវមានប្រសិទ្ធភាពត្រឹមតែក្នុងរង្វង់ភាគីចុះកិច្ចសន្យា ដែលបានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់ឧបសម្ព័ន្ធ។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន។

មាត្រា ១៦.- ការកែសំរួលច្បាប់ជាតិ

នៅចំណុចណាដែលចាំបាច់ ភាគីចុះកិច្ចសន្យា ត្រូវធានាធ្វើការកែសំរួលច្បាប់ជាតិដែលពាក់ព័ន្ធ ឱ្យស្របទៅតាមខ្លឹមសារនៃឧបសម្ព័ន្ធ។

មាត្រា ១៧ .- ការដាក់លក្ខខ័ណ្ឌ

ការដាក់លក្ខខ័ណ្ឌ ទៅលើឧបសម្ព័ន្ធ មិនត្រូវបានគេអនុញ្ញាតិឡើយ ។

មាត្រា ១៨.- ការព្យួរទុកនៃឧបសម្ព័ន្ធ

ភាគីចុះកិច្ចសន្យានិមួយៗអាចព្យួរទុក ជាបណ្តោះអាសន្ន នូវការអនុវត្តន៍ឧបសម្ព័ន្ធទាំងស្រុង ឬក៏មួយចំណែក ដែលមានប្រសិទ្ធិភាពភ្លាមៗ នៅក្នុងករណីមានការរឹតត្បិតជាអាសន្ន ដែលប៉ះពាល់ដល់សុវត្ថិភាព របស់ជាតិខ្លួន។ ភាគីចុះកិច្ចសន្យា នឹងជូនពត៌មានទៅភាគីចុះកិច្ចសន្យាផ្សេងទៀតភ្លាម តាមតែអាចធ្វើទៅបាន អំពីការព្យួរទុកនេះ និងការបញ្ចប់ការព្យួរទុកនេះ ឱ្យបានឆាប់បំផុត នៅពេលណាដែលសភាពការណ៍ វិលត្រឡប់ទៅរកស្ថានភាពជាធម្មតាឡើងវិញ។

មាត្រា ១៩ : ទំនាក់ទំនង ជាមួយគិច្ចព្រមព្រៀង

ដោយសារតែវាជាវិធានការមួយក្នុងការអនុវត្តន៍គោលការណ៍ទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ឧបសម្ព័ន្ធនេះមិនអាចផ្តាច់ចេញ ឬក៏ក្លាយជាផ្ទុយទៅនឹងគោលការណ៍ទាំងនោះទេ ។ នៅក្នុងករណីដែលវិសមិត (មិនចុះសំរុងគ្នា-មិនស៊ីគ្នា) រវាងឧបសម្ព័ន្ធ និងកិច្ចព្រមព្រៀងនោះ កិច្ចព្រមព្រៀងត្រូវយកជាបានការ។ នៅក្នុងករណីដែលវិសមិត(មិនចុះសំរុងគ្នា-មិនស៊ីគ្នា) រវាងឧបសម្ព័ន្ធ និងឧបសម្ព័ន្ធ ឬ ពិធីសារផ្សេងទៀតនោះ វិសិមិតភាពនេះ ត្រូវយកទៅបកស្រាយជាមួយគ្នា និងកិច្ចព្រមព្រៀង។

មាត្រា ២០ : ការជំរះស្រាយវិវាទ

ជំលោះ ឬទំនាស់រវាងភាគី០២ ឬច្រើន នៃភាគីចុះកិច្ចសន្យា នៅលើការបកស្រាយ ឬការអនុវត្តន៍ឧបសម្ព័ន្ធ ត្រូវស្រុះស្រួលគ្នា លើកយកមកដោះស្រាយដោយផ្ទាល់ ឬដោយការចរចារតាមគោល ការណ៍សន្តិវិធីតាមរយៈគណៈកម្មាធិការរួម។

មាត្រា ២១ : ការប្រកាសបដិសេធ

នៅពេលណាដែលចូលជាធរមាន ឧបសម្ព័ន្ធមិនអាចឱ្យគេប្រកាសបដិសេធ ដាច់ដោយឡែកចេញអំពីកិច្ចព្រមព្រៀងបានទេ ។

ដើម្បីជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដែលបានទទួលសិទ្ធិប្រទានពេញលេញការអនុញ្ញាតពីអជ្ញាធរវៀងខ្លួន
បានចុះហត្ថលេខាលើឧបសម្ព័ន្ធនេះ ។

ធ្វើនៅ ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ ជា០៦ ច្បាប់ដើម ជាភាសាអង់គ្លេស ។

ហត្ថលេខា :

តំណាងរាជរដ្ឋាភិបាលកម្ពុជា
ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
ឯកឧត្តម ហ៊ូ ស៊ីហ៊ូ អនុរដ្ឋមន្ត្រី គមនាគមន៍

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
ឯកឧត្តម សឹមម៉ាដ ផុលសេនា អនុរដ្ឋមន្ត្រីគមនាគមន៍ ដឹកជញ្ជូន ប៉ុស្តិ និងសំណង់

តំណាងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា
ឯកឧត្តម ចូ ថង់ខីន អនុរដ្ឋមន្ត្រី ដឹកជញ្ជូនផ្លូវដែក

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍
ឯកឧត្តម នីកន ចំណុច អនុរដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
ឯកឧត្តម ដាំ ថេមិញ្ញ អនុរដ្ឋមន្ត្រីដឹកជញ្ជូន

ANNEX 11: ROAD AND BRIDGE DESIGN AND CONSTRUCTION STANDARDS AND SPECIFICATIONS

To the Agreement between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People (hereinafter referred to as "the Annex")

The Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam (hereinafter referred to as "the Contracting Parties"),

Referring to the Agreement between and among the Governments of the Lao People's Democratic Republic, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People, originally signed on 26 November 1999 at Vientiane, amended at Yangon on 29 November 2001, acceded to by the Kingdom of Cambodia at Yangon on 29 November 2001, acceded to by the People's Republic of China on 3 November 2002 at Phnom Penh, and acceded to by the Union of Myanmar on 19 September 2003 at Dali City (hereinafter referred to as "the Agreement"),

Referring to Articles 3(b) and (n) of the Agreement to the effect that Annexes and Protocols contain technical details or time- and/or site-specific variable elements and that they form an integral part of the Agreement and are equally binding,

Referring to Article 36 of the Agreement, as amended, per which the Agreement may be signed and ratified or accepted and enter into force separately from the Annexes and Protocols,

Referring to the Ninth GMS Ministerial Conference held in Manila in January 2000, the Seventh Meeting of the Subregional Transport Forum held in Ho Chi Minh City in August 2002, and the 11th GMS Ministerial Conference held in Phnom Penh in September 2002, where the Governments agreed to a work program to finalize the Agreement and its Annexes and Protocols by 2005, and

Referring to Article 25 of the Agreement, calling for this Annex to provide technical details,

HAVE AGREED AS FOLLOWS:

Article 1: Overview of Standards

An overview of the road design and construction standards is provided in Table 1.

Table 1
Highway Standards

Highway classification		Primary (4 or more lanes) (control access)			Class I (4 or more lanes)		
Terrain classification		L	R	M	L	R	M
Design speed (km/h)		100-120	80-100	60-80	80-110	60-80	50-70
Width (m)	Right of way	(50-70) ((40-60))			(50-70) ((40-60))		
	Lane	3.75		3.50-3.75	3.50-3.75		
	Shoulder	1.50-3.00		2.50	1.50-3.00		1.50-2.50
Min. horizontal curve radius (m)		390	230	120	220	120	80
Type of pavement		Asphalt/cement concrete			Asphalt/cement concrete		
Max. superelevation (%)		(7) ((6-7))			(8) ((6-8))		
Max. vertical grade (%)		4	5	6	5	6	7
Min. vertical clearance (m)		4.50 [5.00]			4.50 [5.00]		
Structure loading (minimum)		HS20-44			HS20-44		

Highway classification		Class II (2 lanes)			Class III (2 lanes)		
Terrain classification		L	R	M	L	R	M
Design speed (km/h)		80-100	60-80	40-60	60-80	50-70	30-60
Width (m)	Right of way	(40-60) ((30-40))			30-40		
	Lane	3.50-3.75			3.00[3.25]		
	Shoulder	1.50-2.50		1.50-2.00	1.50[2]		1.0-1.5[1.5]
Min. horizontal curve radius (m)		200	110	50	110	75	50
Type of pavement		Asphalt/cement concrete			Double bituminous treatment		
Max. superelevation (%)		(10) ((6))			(10) ((6))		
Max. vertical grade(%)		6	7	8	6	7	8
Min. vertical clearance (m)		4.50			4.50		
Structure loading (minimum)		HS20-44			HS20-44		

Notes:

1. Abbreviations:

L = Level Terrain M = Mountainous Terrain R = Rolling Terrain

2. ( ) = Rural (( )) = Urban

3. [ ] = Desirable Values

4. The right-of-way width, lane width, shoulder width and maximum superelevation rate can be varied if necessary to conform with the Contracting Parties' design standards.

5. National standards for structure loads may be applied.

Article 2: Classification

(a) Routes and corridors designated in Protocol 1 of the Agreement shall be classified as shown in Table 2:

Table 2
Classification
(Based on Asian Highway Standards by UNESCAP 1995)

Classification	Description	Pavement Type
Primary	Access-controlled motorway	Asphalt or cement concrete
Class I	4 or more lanes highway	Asphalt or cement concrete
Class II	2 lanes	Asphalt or cement concrete
Class III	2 lanes (narrow)	Double bituminous treatment

(b) "Primary" class refers to access-controlled motorways. Access-controlled motorways shall be used exclusively by automobiles. Access to motorways shall be at grade-separated interchanges only. Motorcycles, bicycles, and pedestrians shall not be allowed to enter motorways in order to ensure traffic safety and the high running speed of automobiles except when allowed by domestic legislation and regulations. At-grade intersections shall not be designed on motorways, and the carriageway shall be divided by a median strip. This class was included in the classification in view of the recent development of motorways in GMS countries.

(c) Class III can be used only when the funding for the construction and/or land for the road is limited. The type of pavement should be upgraded to asphalt concrete or cement concrete as soon as possible in the future. Since Class III is also regarded as the minimum desirable standard, upgrading of any road sections below Class III to comply with the Class III standard should be encouraged.

(d) Future traffic volume projected for 20 years after completion of road construction/improvement (called projected daily traffic volume hereinafter) should be used to determine the class of road as described below.

(e) It is recognized internationally that the presence of heavy vehicles and slow-moving vehicles greatly influences the design of a highway. Therefore, in this classification system, it is proposed to use the "Passenger Car Unit (pcu)" approach, which is widely used for design purposes in Asian countries.

(f) The traffic volume of light vehicles does not need to be taken into account if exclusive lanes for light vehicles are provided. Flow coefficients for heavy vehicles can be increased if the road is located in a mountainous area.

(g) Class of road is determined as follows using "pcu" as an index representing traffic volume:

(i) Determine "PDT" or "projected daily traffic volume (pcu/day)" using projected traffic volume by vehicle type (vehicles/day) and flow coefficients.

(ii) Determine "K value", which is the ratio of the 30th highest hourly traffic volume over one year (pcu/hour) to annual average daily traffic (pcu/day). Traffic count data on a road section, which has similar characteristics as the planned road, can be used. The K value is usually around 0.10.

(iii) Determine "D value", which is the ratio of heavy directional peak hour (30th highest) traffic volume (pcu/hour) to both directions peak hour (30th highest) traffic volume (pcu/hour). The D value usually ranges from 0.55 to 0.60, although it could reach 0.80.

(iv) Calculate "PPHT" or "planning peak hour traffic volume (pcu/hour)" using the formula PPHT = PDT x K x D. PPHT represents projected heavy directional 30th highest hourly traffic volume (pcu/hour).

(v) Divide PPHT (pcu/hour) by 1,800 (pcu/hour), which is widely recognized as the standard capacity per one lane, and round up the calculated value to determine the number of lanes in one direction. Multiplying by 2 gives the required number of lanes (both directions).

(vi) Determine the class according to the required number of lanes determined in step (v). "Primary" class can be used if the development of an access-controlled motorway is needed.

Article 3: Terrain Classification

The terrain classifications shown in Table 3 shall be used.

Table 3
Terrain Classification

Terrain classification	Cross Slope
Level (L)	0 to 9.9%.
Rolling (R)	10 to 24.9%
Mountainous (M)	25% or higher

Article 4: Design Speed

The relation between design speed, highway classification, and terrain classification is shown in Table 1 in Article 1. A design speed of 120 km/h shall be used only for Primary class (access-controlled motorways) roads that have median strips and grade-separated interchanges. Recommended design speeds for **urban areas** are as follows:

Class Primary	*80 - 100*	*km/h*
Class I	*60 - 80*	*km/h*
Class II	*50 - 60*	*km/h*
Class III	*30 - 50*	*km/h*

Article 5: Cross Section

(a) The dimensions, such as right-of-way width, lane width, and shoulder width, are shown in Table 1 in Article 1 for each highway classification.

(b) It is highly recommended that pedestrians, bicycles, and animal-drawn carts be separated from through traffic by provision, where practical, of frontage roads and/or sidewalks for the sections where smooth traffic is impeded by the existence of this local traffic.

Article 6: Horizontal Alignment

(a) Horizontal alignment shall be consistent with the topography of the terrain and should provide for safe and continuous operation at a uniform design speed. Horizontal alignment must afford at least the minimum stopping sight distance for this design speed.

(b) In the design of highway curves it is necessary to establish the proper relation between design speed and curvature and also their joint relations with superelevation and side friction. Radius of curvature may be calculated from:

$$R = \frac{v^2}{127.5\,(e + f)}$$

where
- v = Design speed (km/h)
- e = Rate of roadway superelevation m/m
- f = Side friction factor
- R = Radius of curve (m)

The recommended side friction factor is shown in Table 4.

Table 4
Recommended Side Friction Factor

Design speed (km/h)	40	50	60	70	80	90	100	110	120
Side friction factor	0.16	0.16	0.15	0.15	0.14	0.13	0.13	0.12	0.11

(c) The minimum curve radius is the limiting value of curvature for a given design speed and is determined from the formula in (c) above using the maximum suggested superelevation rate and the related side friction factor. Minimum curve radius shall be applied only when necessary and shall be used in conjunction with transition curve, which is also recommended for longer curves; larger values by up to 100 percent should be considered as the design normal curve radius.

(d) Widening along the horizontal curves should be provided based on the design speed, the pavement width, the radius of curve, and the dimension of the standard truck.

(e) The recommended minimum horizontal curve radius in **urban areas** is as follows:

Class Primary	*230*	*m*
Class I	*120*	*m*
Class II	*75*	*m*
Class III	*50*	*m*

Article 7: Vertical Alignment

(a) The vertical alignment of any highway shall be as smooth as is economically possible, that is, there shall be a balance of cutting and filling to eliminate the rolling nature of the land. In the use of the maximum vertical gradient, it shall be kept clear in the mind of the designer that, once constructed to a given vertical grade, the highway cannot be upgraded to a lesser gradient without the loss of the entire initial investment. The maximum vertical grade shown in Table 1 in Article 1 shall be used. The minimum vertical curve length shall be based on the algebraic difference in grades, the design speed, and the minimum stopping sight distance.

(b) The critical length of gradient section for the provision of a climbing lane is recommended to highway classifications Primary and Class 1, as shown in Table 5. It is desirable to provide a climbing lane to the up-gradient highways with heavy truck traffic where the length of gradient exceeds the above values.

Table 5
Critical Length of Gradient Section for the Provision of a Climbing Lane

Terrain Classification	Primary	Class I	Remarks
Level (L)	3% - 800 m	3% - 900 m	National standards may also be adopted, e.g., based on volume.
	4% - 500 m	4% - 700 m	
Rolling (R)	4% - 700 m	4% - 800 m	
	5% - 500 m	5% - 600 m	
Mountainous (M)	5% - 600 m	5% - 700 m	
	6% - 400 m	7% - 400 m	

Article 8: Pavement

(a) Carriageways should be paved with cement or asphalt concrete. Only in cases where the anticipated traffic volume is quite low will bituminous treatment be adopted as surfacing. It is also recommended that the shoulders be paved with cement or asphalt concrete or be surfaced with bituminous materials.

(b) Road pavement is designed taking into account (i) maximum wheel load which should be based on the standard trucks, (ii) traffic volume, (iii) design life, and (iv) qualities of materials to be used.

Article 9: Bridges and Culverts

Bridges and culverts should be built as permanent structures. For minor bridges shorter than 50 m, the full roadway width should be carried through including the width of shoulders. The minimum width between curbs for a major bridge longer than 50 m should be one half meter greater than the width of the pavement approaching it. A 1-m wide walkway should be provided but for long spans it can be limited to one side of the bridge only.

Article 10: Structure Loading

(a) Increasing heavy traffic, particularly container traffic, requires properly designed load capacity (maximum axle load). In order to prevent serious damage to road structures, and also to reduce maintenance costs, the routes and corridors designated in Protocol 1 of the Agreement, as an international road network, should have high design load capacity.

(b) The minimum design loading of HS20-44, which is the international standard corresponding to full-size trailer loading, shall therefore be used for design of structures. National standards may also be applied.

Article 11: Vertical Clearance

Minimum vertical clearance shall be 4.50 m, which is the requirement for safe passage of standard ISO containers. However, in cases where sufficient clearance cannot be secured because of the high cost of rebuilding existing structures such as bridges, goose-neck trailers with low vehicle bed clearance could be used. Generally the desirable vertical clearance should be 5.00 m, especially on Primary roads along routes and corridors designated in Protocol 1 of the Agreement, which will be constructed or improved.

Article 12: Recommended Roadside Equipment

The Contracting Parties will consider installing the following recommended roadside equipment, as required for safety and in accordance with the highway classification:

(a) **Illumination**

(i) In special areas, such as frontier posts, long tunnels and bridges, adjoining areas, and interchanges with other roads.

(ii) Also certain other sections of the road may require homogeneous lighting.

(b) **Anti-Glare Devices**

Outside illuminated sections with narrow medians, an artificial screen or hedge on the central (median) strip or shoulder strip in order to shield it respectively from the opposite carriageway or from a parallel road.

(c) **Acceleration and Deceleration Lanes**

Acceleration and deceleration lanes for access to or exit from the motor or expressway.

(d) **Emergency Stopping Strip (Stabilized Shoulder)**

On Primary and Class I highways a continuous stabilized and paved emergency stopping strip on the shoulder.

(e) **Arrester Beds**

In order to assure the safety of trucks on long steep gradients, where no other measure is possible, arrester beds built alongside the downhill lane.

(f) **Safety Fences and Barriers**

Guard rails, crash barriers, safety barriers, and fences, designed to prevent vehicles from accidentally leaving the carriageway or in order to absorb the shock.

(g) **Railway Intersections**

At different levels (bridge or tunnel) for motorways, expressways, and highways with high volume of traffic and trains.

(h) **Protection from Animal Crossing**

(i) Fences installed wherever there is a risk of animals crossing the road.

(ii) Also suitable over- or under-passes for animals.

(i) **Emergency Communication Systems**

Emergency call-points installed along the road and linked to a call-center operating around the clock, especially on Primary class highways.

(j) **Service Facilities and Rest Areas**

Rest areas combined with service facilities (parking lot, fuel and vehicle maintenance station, communication center, sanitary equipment (toilets), hotel, restaurant) integrated in the road construction.

Article 13: Amendment

Any Contracting Party may propose amendments to the Annex via the Joint Committee. Such amendments shall be subject to the unanimous consent of the Contracting Parties.

Article 14: Ratification or Acceptance

The Annex is subject to ratification or acceptance of the Governments of the Contracting Parties. The same applies to an amendment to the Annex, if any.

Article 15: Entry into Force

The Annex will enter into force on the day that at least two Contracting Parties have ratified or accepted it, and will become effective only among the Contracting Parties that have ratified or accepted it. The same applies to an amendment to the Annex, if any.

Article 16: Conforming National Law

Where necessary, the Contracting Parties undertake to conform their relevant national legislation with the contents of the Annex.

Article 17: Reservations

No reservation to the Annex shall be permitted.

Article 18: Suspension of the Annex

Each Contracting Party may temporarily suspend wholly or partly the application of the Annex with immediate effect in the case of emergencies affecting its national safety. The Contracting Party will inform the other Contracting Parties as soon as possible of such suspension, which will end as soon as the situation returns to normal.

Article 19: Relationship with the Agreement

As a measure to implement the principles laid down in the Agreement, the Annex cannot depart from or be contrary to these principles. In case of incompatibility between the Annex and the Agreement, the latter shall prevail. In case of incompatibility between the Annex and another annex or protocol, such incompatibility shall be interpreted in light of the Agreement.

Article 20: Dispute Settlement

Any dispute between or among two or more Contracting Parties on the interpretation or application of the Annex shall be settled directly or by amicable negotiation in the Joint Committee.

Article 21: Denunciation

Once entered into force, the Annex cannot be denounced separately from the Agreement.

In witness whereof, the undersigned, being duly authorized, have signed this Annex.

Done at Phnom Penh on 30 April 2004 in six originals in the English language.

Signed:

For the Royal Government of Cambodia

(SGD) His Excellency Tram Iv Tek
Secretary of State, Ministry of Public Works and Transport

For the Government of the People's Republic of China

(SGD) His Excellency Hu Xijie
Vice Minister of Communications

For the Government of the Lao People's Democratic Republic

(SGD) His Excellency Sommad Pholsena
Vice Minister of Communication, Transport, Post and Construction

For the Government of the Union of Myanmar

(SGD) His Excellency Thura Thaung Lwin
Deputy Minister of Rail Transportation

For the Government of the Kingdom of Thailand

(SGD) His Excellency Nikorn Chamnong
Deputy Minister of Transport

For the Government of the Socialist Republic of Viet Nam

(SGD) His Excellency Pham The Minh
Vice Minister of Transport

ANNEX 11: ROAD AND BRIDGE DESIGN AND CONSTRUCTION STANDARDS AND SPECIFICATIONS

To the Agreement between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People (hereinafter referred to as "the Annex")

The Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam (hereinafter referred to as "the Contracting Parties"),

Referring to the Agreement between and among the Governments of the Lao People's Democratic Republic, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People, originally signed on 26 November 1999 at Vientiane, amended at Yangon on 29 November 2001, acceded to by the Kingdom of Cambodia at Yangon on 29 November 2001, acceded to by the People's Republic of China on 3 November 2002 at Phnom Penh, and acceded to by the Union of Myanmar on 19 September 2003 at Dali City (hereinafter referred to as "the Agreement"),

Referring to Articles 3(b) and (n) of the Agreement to the effect that Annexes and Protocols contain technical details or time- and/or site-specific variable elements and that they form an integral part of the Agreement and are equally binding,

Referring to Article 36 of the Agreement, as amended, per which the Agreement may be signed and ratified or accepted and enter into force separately from the Annexes and Protocols,

Referring to the Ninth GMS Ministerial Conference held in Manila in January 2000, the Seventh Meeting of the Subregional Transport Forum held in Ho Chi Minh City in August 2002, and the 11th GMS Ministerial Conference held in Phnom Penh in September 2002, where the Governments agreed to a work program to finalize the Agreement and its Annexes and Protocols by 2005, and

Referring to Article 25 of the Agreement, calling for this Annex to provide technical details,

GMS-Annex13a_kh-01 Sep 2006 1/19/2001

ឧបសម័ន្ធទី ១៣អា

របបគ្រប់គ្រងការទទួលខុសត្រូវអ្នកដឹកជញ្ជូនពាណិជ្ជកម្ម

ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនចំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

(តទៅហៅកាតថា " ឧបសម័ន្ធ ")

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋ សង្គមនិយមវៀតណាម (តទៅហៅកាត់ថា" ភាគីចុះកិច្ចសន្យា")

ដោយយោងទៅលើ កិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនចំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាតំបូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០១ នៅយ៉ាងហ្គូន ; ដែលបានយល់ព្រមចូលដោយព្រះរាជាណាចក្រកម្ពុជា នៅយ៉ាងហ្គូន នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១ បានយល់ព្រមចូលដោយសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូលដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី តទៅហៅកាត់ថា" កិច្ចព្រមព្រៀង"

ដោយយោងទៅលើ មាត្រាទី ៣(បេ)និង(អិន)នៃកិច្ចព្រមព្រៀង ដែលបានចែងថា ឧបសម័ន្ធ និងពិធីសារទាំងឡាយដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលមានលក្ខណៈពិសេស ទៅតាមទីកន្លែង ហើយដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង នឹងមានតំលៃចូលរួមស្មើៗគ្នា

ដោយយោងទៅលើ មាត្រាទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានធ្វើវិសោធនកម្មរួចហើយ ដែលឧបសម័ន្ធ និងពិធីសារនិមួយៗអាចត្រូវបានគេចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីគ្នា ដាច់ចេញអំពីកិច្ចព្រមព្រៀង

ដោយយោងទៅលើ កិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានិលឡា ក្នុងខែមករា ឆ្នាំ ២០០០. កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តិទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ ២០០២ និងកិច្ចប្រជុំលើកទី១១ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ ២០០២ ដែលរដ្ឋមន្ត្រី GMS ទាំងអស់ បានឯកភាពយល់ព្រមទៅនឹងផែនការការងារមួយ ក្នុងការបង្កើយបញ្ចប់កិច្ចព្រមព្រៀង និងឧបសម័ន្ធ-ពិធីសារ របស់វា ក្នុងឆ្នាំ ២០០៥ និង

ដោយយោងទៅលើ មាត្រា៣៤(អា) នៃកិច្ចព្រមព្រៀង ដែលបានស្នើឱ្យផ្តល់តាមរយៈឧបសម័ន្ធនេះ នូវការរៀបចំលំអិតខាងបច្ចេកទេស

បានព្រមព្រៀងគ្នាដូចខាងក្រោម :

GMS-Annex13a_kh-01 Sep 2006 1/19/2001

មាត្រា ១.- របបគ្រប់គ្រងការទទួលខុសត្រូវអ្នកដឹកជញ្ជូនពហុរូបភាព

របបគ្រប់គ្រងការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូនពហុរូបភាព ត្រូវបានគេបកស្រាយ នៅក្នុងឯកសារភ្ជាប់នៃឧបសម្ព័ន្ធ នេះ" **របបទទួលខុសត្រូវអ្នកដឹកជញ្ជូនពហុរូបភាព** " ។

មាត្រា ២.- ការធ្វើវិសោធនកម្ម

ភាគីនៃកិច្ចសន្យាអាចស្នើសុំការធ្វើវិសោធនកម្មទៅលើពិធីសារនេះ តាមរយៈគណៈកម្មាធិការរួម ។ ការធ្វើវិសោធនកម្មបែបនេះនឹងត្រូវជាកម្មវត្ថុនៃការយល់ព្រមជាឯកឆន្ទៈនៃភាគីនៃកិច្ចសន្យាទាំងអស់ ។

មាត្រា ៣.- ការផ្តល់សច្ចាប័ន ឬការយល់ព្រមទទួលយក

ពិធីសារនេះ គឺជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រមទទួលយករបស់រដ្ឋាភិបាលនៃភាគីកិច្ចសន្យា ។ ការអនុវត្តន៍ដូច១ក្តានេះ ត្រូវបានគេអនុវត្តចំពោះការធ្វើវិសោធនកម្មទៅលើពិធីសារ ប្រសិនបើមាន ។

មាត្រា ៤.- ការចូលជាធរមាន

ពិធីសារនឹងចូលជាធរមាននៅថ្ងៃដែលមានភាគីនៃកិច្ចសន្យាចំនួនពីរយ៉ាងតិច បានផ្តល់សច្ចាប័នឬការយល់ព្រមទទួលយក ហើយនឹងត្រូវមានប្រសិទ្ធិភាពនៅត្រឹមតែក្នុងចំណោមភាគីនៃកិច្ចសន្យាដែលបានផ្តល់សច្ចាប័ន ឬការយល់ព្រមទទួលយក ពិធីសារនេះប៉ុណ្ណោះ ។ ការអនុវត្តដូច១ក្តា ត្រូវបានគេអនុវត្តចំពោះការធ្វើវិសោធនកម្មទៅលើពិធីសារ ប្រសិនបើមាន។

មាត្រា ៥. ការកែសំរួលច្បាប់ជាតិ

នៅចំណុចណាដែលចាំបាច់ ភាគីចុះកិច្ចសន្យា ត្រូវធានាធ្វើការកែសំរួលច្បាប់ជាតិដែលពាក់ព័ន្ធ ឱ្យស្របទៅតាមខ្លឹមសារនៃពិធីសារ ។

មាត្រា ៦.- ការដាក់លក្ខខ័ណ្ឌ

ការដាក់លក្ខខ័ណ្ឌ ទៅលើឧបសម្ព័ន្ធ មិនត្រូវបានគេអនុញ្ញាតិឡើយ ។

មាត្រា ៧.- ការព្យួរទុកនូវពិធីសារ

ភាគីចុះកិច្ចសន្យានិមួយ១អាចព្យួរទុក ជាបណ្តោះអាសន្ន នូវការអនុវត្តន៍ពិធីសារទាំងស្រុង ឬក៏មួយចំណែក ដែលមានប្រសិទ្ធិភាពភ្លាម១ នៅក្នុងករណីមានការរីកវាវជាអាសន្ន ដែលប៉ះពាល់ដល់សុវត្ថិភាពរបស់ជាតិខ្លួន។ ភាគីចុះកិច្ចសន្យា ត្រូវជូនពត៌មានទៅភាគីចុះកិច្ចសន្យាផ្សេងទៀតភ្លាម១តាមតែអាចធ្វើទៅបាន អំពីការព្យួរទុក និងការបញ្ចប់ការព្យួរទុកនេះឱ្យបានឆាប់បំផុត នៅពេលណាដែលសភាពការណ៏វិលត្រឡប់ ទៅរកស្ថានភាពជាធម្មតាឡើងវិញ។

មាត្រា ៨.- សម្ព័ន្ធភាពជាមួយនឹងកិច្ចព្រមព្រៀង

ដោយសារតែវាជាវិធានការមួយក្នុងការអនុវត្តន៍គោលការណ៏ទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ពិធីសារនេះមិនអាចផ្តាច់ចេញ ឬក៏ក្លាយជាផ្ទុយទៅនឹងគោលការណ៏ទាំងនេះបានទេ។ នៅក្នុងករណីដែលវិសមិត (មិនចុះសំរុងគ្នា) រវាងពិធីសារ និងកិច្ចព្រមព្រៀង នោះកិច្ចព្រមព្រៀងត្រូវយកជាបានការ។ នៅក្នុងករណីដែលវិសមិត(មិនចុះសំរុងគ្នា)រវាងពិធីសារ និងឧបសម្ព័ន្ធ ឬពិធីសារផ្សេងទៀតនោះ វិសិមិតភាពនេះ ត្រូវយកទៅបកស្រាយជាមួយគ្នា និងកិច្ចព្រមព្រៀង។

មាត្រា ៩.- ការដោះស្រាយជំលោះ

ជំលោះណាមួយរវាងឬក្នុងភាគី០២ ឬច្រើននៃភាគីចុះកិច្ចសន្យា ទៅលើការបកស្រាយ ឬការអនុវត្តន៍ពិធីសារ ត្រូវស្រុះស្រួលគ្នា លើកយកមកដោះស្រាយដោយផ្ទាល់ ឬដោយការចរចារតាមគោលការណ៏សន្តិវិធីតាមរយៈគណៈកម្មាធិការរួម។

GMS-Annex13a_kh-01 Sep 2006 1/19/2001

មាត្រា ១០.- ការប្រកាសបដិសេធ

នៅពេលចូលជាធរមាន ពិធីសារមិនអាចត្រូវបានត្រួបកាសបដិសេធ ដាច់ដោយឡែកចេញពីកិច្ចព្រមព្រៀងបានទេ ។

ឧសារយោងនៃឧបសម្ព័ន្ធទី១៣: របបគ្រប់គ្រង់ទទួលខុសត្រូវអ្នកដឹកជញ្ជូនពហុភាគ

ដើម្បីជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដោយមានការផ្តល់សិទ្ធិប្រទានយ៉ាងពេញលេញពីអជ្ញាធររៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារនេះ ។

ធ្វើនៅ ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ ជា០៦ ច្បាប់ដើម ជាភាសាអង់គ្លេស ។

ហត្ថលេខា :

តំណាងរាជរដ្ឋាភិបាលកម្ពុជា
ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
ឯកឧត្តម ហ៊ូ ស៊ីហ៊ុ អនុរដ្ឋមន្ត្រី គមនាគមន៍

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
ឯកឧត្តម សឹមាំង ផុលសេនា អនុរដ្ឋមន្ត្រីគមនាគមន៍ ដឹកជញ្ជូន ប៉ុស្តិ៍ និងសំណង់

តំណាងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា
ឯកឧត្តម ចូ ថាន់ឆិន អនុរដ្ឋមន្ត្រី ដឹកជញ្ជូនផ្លូវដែក

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់
ឯកឧត្តម នីភន ចំណុច អនុរដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
ឯកឧត្តម ង៉ា ថេមិញ្ញា អនុរដ្ឋមន្ត្រីដឹកជញ្ជូន

GMS-Annex13a_kh-01 Sep 2006- Attachement 1/19/2001

ឯកសារភ្ជាប់ : និតិវិធីនៃការធានូលខុសត្រូវការដឹកជញ្ជូនពហុរូបភាព

ជំពូកទី ១

និយមន័យ

មាត្រា ១

សំរាប់គោលបំណងនៃឯកសារភ្ជាប់នេះ :

" **អ្នកដឹកជញ្ជូន** " មានន័យថា បុគ្គលដែលអនុវត្ត ឬទទួលរ៉ាប់រងក្នុងការអនុវត្តន៍ការដឹកជញ្ជូន ឬ ក៏ផ្នែកណាមួយនៃការដឹកជញ្ជូននោះ ទោះជាបុគ្គលនោះគឺជា (ដូចគ្នាសុទ្ធសាធទៅនឹង) ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពឬក៏មិនមែនក៏ដោយ ។

" **អង្គភាពជាតិមានសមត្ថកិច្ច** " មានន័យថាមន្ត្រី ឬអង្គភាពដែលជ្រើសរើសដោយប្រទេសសមាជិកនិមួយៗ ។

" **អ្នកទទួលទំនិញ** " មានន័យថាបុគ្គលដែលមានសិទ្ធិទទួលទំនិញពីប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ។

" **អ្នកផ្តល់ទំនិញ** " មានន័យថា ជាបុគ្គលដែលបានសំរេចចិត្តចុះហត្ថលេខាលើកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពជាមួយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ។

" **អ្នកប្រគល់** " **ការប្រគល់** " **ឬ បែងចែក** មានន័យថា :

ក- ការប្រគល់ទំនិញទាំងឡាយទៅអោយអ្នកទទួលទំនិញ ឬ

ខ- ការផ្ទេរដាក់ទំនិញអោយនៅចំកន្លែងទៅតាមបំណងប្រាថ្នារបស់អ្នកទទួលទំនិញ ដោយអនុលោមទៅតាមកិច្ចសន្យាដឹកជញ្ជូនពហុរូបភាព ឬំ ទៅតាមច្បាប់ ឬ ទម្លាប់ប្រើប្រាស់ការធ្វើពាណិជ្ជកម្មជាពិសេសដោយឡែកដែលអាចអនុវត្តបាននៅទីកន្លែងប្រគល់ទំនិញ ។ ឬ

គ- ការប្រគល់ទំនិញទៅអោយអាជ្ញាធរណាមួយ ឬភាគីទី ៣ ណាមួយផ្សេងទៀតជាបុគ្គលកំណត់ ដែលទំនិញត្រូវបានគេប្រគល់ទៅអោយ ដោយអនុលោមទៅតាមច្បាប់ ឬ បទប្បញ្ញត្តិនានាដែលអាចអនុវត្តបាននៅកន្លែងប្រគល់នោះ ។

" **ទំនិញ** " មានន័យថា ជាទ្រព្យសម្បត្តិណាមួយ ក៏ដូចជាកុងតែន័រ ប៉ាលែត (ទំនិញជាប៉ាលែត) ឬ ផ្ទាគហ្វម ឬ វត្ថុដឹកជញ្ជូនទាំងឡាយប្រហាក់ប្រហែល ឬ ការវេចខ្ចប់កញ្ចប់ទាំងឡាយ ដែលមិនមែនផ្តល់ដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពដោយមិនគិតថាមធ្យោបាយ ឬទ្រព្យសម្បត្តិទាំងនេះត្រូវបានគេដឹកជញ្ជូន ឬ ដាក់ទំនិញដឹកជញ្ជូនពីលើ ឬ ពីក្រោមវាយ៉ាងណានោះទេ ។

" **ជាលាយលក្ខអក្សរ** " រាប់បញ្ចូលទាំងទូរលេខ ទូរសារ ទូរពុម្ព ឬ មធ្យោបាយទាំងឡាយផ្សេងទៀត ដែលបោះពុម្ព ថត ឬ កត់បញ្ចូល ឬ ត្រាប់ឡើងវិញ ឬបញ្ជូនសារដោយឧបករណ៍ ឬបរិធានមេកានិច ឬអេឡិកត្រូនិក ឬ ដោយឧបករណ៍ ឬ បរិធានទាំងឡាយផ្សេងទៀតបង្កើតឡើងសំរាប់បំរើគោលដៅ ដូចខាងលើនេះ ។

"**ដឹកជញ្ជូនពហុរូបភាពអន្តរជាតិ** " មានន័យថាការដឹកនាំទំនិញ ដោយមធ្យោបាយដឹកជញ្ជូនយ៉ាងតិច ពីរបែបខុសគ្នាលើមូលដ្ឋានកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពមួយ ពីកន្លែងមួយរបស់ប្រទេសមួយ ដែលនៅទីនោះទំនិញត្រូវបានប្រគល់ទៅអោយ ឬ ទទួលយកដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពទៅកាន់កន្លែងមួយទៀត ដែលបានកំណត់សំរាប់ប្រគល់បែងចែកទំនិញដែលស្ថិតនៅក្នុងប្រទេសដ៏ទៃមួយផ្សេងទៀត ។

ប្រតិបត្តិការទាំងឡាយក្នុងការលើកផ្ទុកទំនិញ និងការបែងចែកទំនិញដែលបានធ្វើឡើងក្រៅពីសកម្មភាពនៃកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពមួយដូចដែលបានកំណត់ក្នុងកិច្ចសន្យាខាងលើ និងមិនត្រូវចាត់ទុកថាជាការដឹកជញ្ជូនពហុរូបភាពអន្តរជាតិទេ ។

GMS-Annex13a_kh-01 Sep 2006- Attachement 1/19/2001

" **ច្បាប់ចាំបាច់** " មានន័យថា ច្បាប់ ឬ អនុសញ្ញាអន្តរជាតិណាក៏ដោយ ដែលបង្កើតជាផ្នែក នៃច្បាប់របស់ជាតិពាក់ព័ន្ធ ដល់ការដឹកជញ្ជូនទំនិញ ដែលមាត្រាទាំងឡាយបទប្បញ្ញត្តិនៃច្បាប់ទាំងនេះមិនអាច ផ្តាច់ចេញដោយសារបដិញ្ញត្តិ នៃកិច្ចសន្យា (ការចែងក្នុងកិច្ចសន្យា) ដែលបណ្តាលអោយខូចខាតប្រយោជន៍ដល់អ្នកដឹកជញ្ជូន ឬ អ្នកផ្ញើទំនិញទេ ។

" **ប្រទេសសមាជិក** " មានន័យថា ជាប្រទេសមួយនៃបណ្តាប្រទេសអាស៊ាន ។

" **កិច្ចសន្យាដឹកជញ្ជូនពហុរូបភាព** " មានន័យថា ជាកិច្ចសន្យាមួយដែលតាមរយៈនេះ ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព មួយទទួលរ៉ាប់រងទៅនឹងការទូទាត់សោប៊ុយដឹកជញ្ជូនទំនិញ ដើម្បីអនុវត្ត ឬ ទទួលអនុវត្តនូវសកម្មភាពនៃការដឹកជញ្ជូន ពហុរូបភាពជាអន្តរជាតិ ។

" **ឯកសារដឹកជញ្ជូនពហុរូបភាព** " មានន័យថា ឯកសារមួយដែលជាភ័ស្តុតាងបញ្ជាក់ពីកិច្ចសន្យាដឹកជញ្ជូនពហុរូបភាព មួយដែលទទួលផ្តុំកនូវទំនិញដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព និងការទទួលរ៉ាប់រងដោយបុគ្គលនោះក្នុងការប្រគល់ ទំនិញដោយអនុលោមតាមលក្ខខ័ណ្ឌនៃកិច្ចសន្យា ។

" **ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព** " មានន័យថា បុគ្គលណាក៏ដោយក្នុងនាមខ្លួនផ្ទាល់ ឬតាមរយៈបុគ្គលដទៃទៀត ដែលធ្វើសកម្មភាពក្នុងនាមរបស់បុគ្គលនោះ សំរេចចិត្តចុះកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពមួយ និងអ្នកដែលធ្វើសកម្មភាព ជាសំខាន់នាំមុខគេ (Principle) ដែលពុំមែនជាភ្នាក់ងារណាមួយ នៃ ឬ ក្នុងនាមនៃអ្នកបញ្ជូនទំនិញ ឬ នៃអ្នកដឹកជញ្ជូន ទាំងឡាយដែលចូលរួមក្នុងប្រតិបត្តិការដឹកជញ្ជូនពហុរូបភាព និងជាអ្នកដែលសន្មត់ថាជាអ្នកទទួលខុសត្រូវលើសកម្មភាព អនុវត្តនៃកិច្ចសន្យា ។

" **វិញ្ញាបនប័ត្រចុះបញ្ជីការ** " មានន័យថា ឯកសារចេញដោយមន្ត្រី/អង្គភាពជាតិមានសមត្ថកិច្ចដែលបញ្ជាក់ថា ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពត្រូវបានសំរេចបញ្ចូលក្នុងបញ្ជី នៃអ្នកប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពទាំងឡាយ និង កំពុងត្រូវបានអនុញ្ញាតអោយធ្វើសកម្មភាពដូចខាងលើនេះ ។

" **សិទ្ធិដកប្រាក់ពិសេស** (SDR) " មានន័យថា ឯកតាគណនី ដូចបានកំណត់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ។

" **ទទួលផ្តុំកទំនិញ ឬទទួលទំនិញអោយនៅក្រោមការទទួលខុសត្រូវរបស់នណាម្នាក់ ឬការទទួលបន្ទុក** " មានន័យថា ទំនិញត្រូវបានប្រគល់ទៅអោយ និងយល់ព្រមដឹកជញ្ជូនដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ។

ជំពូកទី ២
ទំហំនៃការអនុវត្តន៍
មាត្រា ២

ឯកសារគ្រោងនេះនឹងអនុវត្តន៍ទៅលើ :

ក- រាល់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពទាំងអស់ ដែលនៅក្រោមការចុះបញ្ជីការរបស់អង្គភាពជាតិមានសមត្ថកិច្ច និមួយៗ និង

ខ- រាល់កិច្ចសន្យាដឹកជញ្ជូនពហុរូបភាពទាំងអស់ សំរាប់បំរើគោលបំណងក្នុងការរៀបចំបណ្តឹងស៊ីវិលប្រសិនបើ :

(១) ទីកន្លែងសំរាប់ទទួលផ្តុំកទំនិញ ដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ដូចមានចែងក្នុងកិច្ចសន្យាដឹក ជញ្ជូនពហុរូបភាពស្ថិតនៅក្នុងប្រទេសសមាជិកណាមួយ ឬ

(២) - ទីកន្លែងប្រគល់ទំនិញដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ដូចមានចែងក្នុងកិច្ចសន្យាដឹកជញ្ជូនពហុ រូបភាព គឺស្ថិតនៅក្នុងប្រទេសជាសមាជិកមួយ ។

GMS-Annex13a_kh-01 Sep 2006- Attachement 1/19/2001

មាត្រា ៣

ទោះជាពេលណាក៏ដោយ នៅក្នុងកិច្ចព្រមព្រៀងនេះ និងនៅក្នុងឃ្លាក្តីដែលបានអនុម័តសំរាប់គោលបំណង នៃការអនុវត្តន៍កិច្ចព្រមព្រៀងនេះ វាក្យខ័ណ្ឌណាមួយក្នុងចំណោមវាក្យខ័ណ្ឌដូចខាងក្រោម គឺត្រូវបានប្រើសំរាប់អនុវត្តកិច្ចព្រមព្រៀងនេះ " ដឹកជញ្ជូនពហុរូបភាព " "ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព" "កិច្ចសន្យាដឹកជញ្ជូនពហុរូបភាព" ឬ " ឯកសារដឹកជញ្ជូនពហុរូបភាព " ត្រូវបានគេទទួលស្គាល់ជាធម្មតាដូចគ្នានឹងពាក្យថា " អន្តរជាតិ " ដែរ ។

ជំពូកទី ៣

ឯកសារដឹកជញ្ជូនពហុរូបភាព

មាត្រា ៤

១- នៅពេលទំនិញត្រូវទទួលផ្ទុកដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ប្រតិបត្តិករនោះត្រូវមានឯកសារដឹកជញ្ជូនពហុរូបភាពមួយ ដែលមានទំរង់អាចចរចាបាន ឬ ពុំអាចចរចាបានទៅតាមការជ្រើសរើសរបស់ម្ចាស់ទំនិញ ។

២- ឯកសារដឹកជញ្ជូនពហុរូបភាពនឹងត្រូវចុះហត្ថលេខាដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ឬ ដោយបុគ្គលដែលបានទទួលសិទ្ធិអំណាចពីប្រតិបត្តិករនោះ ។

៣- ហត្ថលេខានៅលើឯកសារដឹកជញ្ជូនពហុរូបភាព អាចជាហត្ថលេខាដោយដៃ ចោះពុម្ពក្នុងទូរពុម្ព ចោះប្រហោង ចោះត្រា ជាសញ្ញា ឬជាមធ្យោបាយមេកានិក ឬអេឡិចត្រូនិកផ្សេងទៀត ប្រសិនបើមិនជំទាស់ទៅនឹងច្បាប់នៃប្រទេសប្រទេស ដែលនៅទីនោះឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានគេចេញអោយ ។

មាត្រា ៥

១- ឯកសារដឹកជញ្ជូនពហុរូបភាពនឹងត្រូវមានចំណុចពិសេសដូចតទៅ :

ក- ប្រភេទជាធម្មតាទូទៅនៃទំនិញ និមិត្តសញ្ញាចាំបាច់សំរាប់សំគាល់ទំនិញ និងការបញ្ជាក់ជាក់លាក់ដូចជាលក្ខណៈងាយខូច ឬលក្ខណៈគ្រោះថ្នាក់នៃទំនិញ ប្រសិនបើជាអាចអនុវត្តបាន ឬរិមាណកញ្ចប់ ឬ បំណែកទំងន់ទាំងសបក នៃទំនិញ ឬ បរិមាណរបស់ទំនិញដែលមានការបញ្ជាក់ផ្សេងពីនេះ និងរាល់ចំណុចពិសេសតាមការផ្តល់ពីអ្នកបញ្ជូនទំនិញ

ខ- ទិដ្ឋភាពខាងក្រៅនៃទំនិញ

គ- ឈ្មោះ និងទីកន្លែងធ្វើការរស់ខាន់ៗរបស់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព

ឃ- ឈ្មោះនៃអ្នកផ្តល់ទំនិញ

ង- អ្នកទទួលទំនិញ ប្រសិនបើបានកំណត់ឈ្មោះដោយអ្នកផ្តល់ទំនិញ

ច- ទីកន្លែង និង កាលបរិច្ឆេទនៃការទទួលផ្ទុកទំនិញដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព

ឆ- ទីកន្លែងប្រគល់ទំនិញ

ជ- កាលបរិច្ឆេទ ឬរយៈពេលប្រគល់ទំនិញនៅទីកន្លែងប្រគល់ទំនិញ ប្រសិនបើបានព្រមព្រៀងគ្នាជាក់លាក់រវាងគូរភាគី

ឈ- បញ្ជាក់ថា តើឯកសារដឹកជញ្ជូនពហុរូបភាពអាចចរចាបាន ឬ មិនអាចចរចាបាន

ញ- ទីកន្លែង និង កាលបរិច្ឆេទការចេញឯកសារដឹកជញ្ជូនពហុរូបភាព

ដ- ហត្ថលេខានៃប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ឬបុគ្គលដែលទទួលអំណាចពីប្រតិបត្តិករនោះ

ឋ- បរិមាណទំនិញសំរាប់បែបដឹកជញ្ជូននិមួយៗ ប្រសិនបើឯកភាពគ្នាជាក់លាក់រវាងគូរភាគី ឬបរិមាណទំនិញរាប់បញ្ចូលទាំងរូបិយវត្ថុរបស់ខ្លួនក្នុងកិរិតអាចទូទាត់បានដោយអ្នកទទួលទំនិញ ឬ តំរុយ (ឬ សុចនាករ) ផ្សេងទៀតដែលសោហ៊ុយដឹកជញ្ជូនអាចទូទាត់បានដោយអ្នកទទួលទំនិញ

ខ- ផ្លូវដែលត្រូវប្រកាន់យកបែបនៃការដឹកជញ្ជូន និងទីកន្លែងផ្ទេរទំនិញ ប្រសិនបើអាចដឹងបាននៅពេលដែលឯកសារដឹកជញ្ជូនពហុរូបភាព ត្រូវបានគេចេញអោយ

ឈ- ចំណុចពិសេសផ្សេងទៀតណាមួយ ដែលបណ្តាភាគីអាចព្រមព្រៀងដាក់បញ្ចូលទៅក្នុងឯកសារពហុដឹកជញ្ជូន ប្រសិនបើមិនប្រឆាំងជាមួយនឹងច្បាប់នៃប្រទេសដែលឯកសារត្រូវបានគេចេញអោយ ។

២- អវត្តមានចេញពីឯកសារដឹកជញ្ជូនពហុរូបភាពនូវចំណុចមួយ ឬ ចំណុចច្រើននៅក្នុងចំណោមចំណុចពិសេសនានាយោងតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ និងមិនប៉ះពាល់ដល់លក្ខណៈស្របច្បាប់ នៃឯកសារដែលជាឯកសារដឹកជញ្ជូនពហុរូបភាព ។

មាត្រា ៦

១- ឯកសារដឹកជញ្ជូនពហុរូបភាព នឹងត្រូវចាត់ទុកជាភ័ស្តុតាង ***តំហូរបំផុត*** ក្នុងការទទួលផ្ទុកទំនិញធ្វើឡើងដោយប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព នូវទំនិញទាំងឡាយដែលបានរៀបរាប់ក្នុងឯកសារនោះ លើកលែងតែតំរុយផ្ទុយពីនេះដូចជា "ទំងន់សរុបទំងន់បន្ទុក និងចំនួននៃបន្ទុក" "Shipper's weight, load and count" "សំបកកញ្ចប់កុងតែន័រសំរាប់ផ្ទុក" "Shipper- Packet container" ឬ សេចក្តីបញ្ជាក់ប្រហាក់ប្រហែលដែលគេរៀបចំឡើង ដើម្បីដាក់ចូលទៅក្នុងអត្ថបទបោះពុម្ព ឬ ប្រថាប់នៅលើឯកសារនោះ ។

២- ភ័ស្តុតាងដែលផ្ទុយពីនេះ មិនអាចទទួលយកបានឡើយ កាលណាឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានផ្ទេរ ឬ ក៍សារប្តូរទិន្នន័យអេឡិចត្រូនិក មានតំលៃដូចគ្នាត្រូវបានបញ្ជូន និងបានទទួលដោយអ្នកទទួលទំនិញ ដែលជាអ្នកទទួលទំនិញដោយក្តីស្មោះត្រង់ បានពីងផ្អែក និងចាត់ចែងសកម្មភាពជាបន្តបន្ទាប់ទៀត ។

ជំពូកទី ៤
ការទទួលខុសត្រូវរបស់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព
មាត្រា ៧

ការទទួលខុសត្រូវរបស់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ចំពោះទំនិញក្រោមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះមានរយៈពេលចាប់ពីថ្ងៃប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពបានទទួលយកទំនិញអោយមកស្ថិតនៅក្នុងបន្ទុករបស់ខ្លួន រហូតដល់ពេលប្រគល់ទំនិញទាំងនោះ ។

មាត្រា ៨

ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ត្រូវទទួលខុសត្រូវចំពោះសកម្មភាព និងការខ្វះខាតនៃអ្នកបំរើរសេវា ឬ ភ្នាក់ងាររបស់គេ នៅពេលណាអ្នកបំរើរសេវា ឬ ភ្នាក់ងារទាំងនោះធ្វើសកម្មភាពក្នុងក្របខ័ណ្ឌនៃកិច្ចការរបស់គេ ឬ នៃបុគ្គលផ្សេងណាមួយទៀត ដែលជាអ្នកធ្វើសេវានេះ ហើយដែលគាត់ប្រើដើម្បីសកម្មភាព នៃកិច្ចសន្យានេះ ប្រសិនបើសកម្មភាព និងការខ្វះខាតទាំងនេះគឺជាសកម្មភាពរបស់គាត់ ។

មាត្រា ៩

ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព ត្រូវទទួលរាប់រងអនុវត្ត ឬ ប្រគល់ការអនុវត្តន៍រាល់សកម្មភាពចាំបាច់ ដើម្បីធានានូវការប្រគល់ទំនិញ :

GMS-Annex13a_kh-01 Sep 2006- Attachement 1/19/2001

ក- នៅពេលណាដែលឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានផ្តល់ក្នុងទំរង់អាចចរចាបាន ទៅអោយ "អ្នកកាន់" ដែលបុគ្គលមានកាន់ឯកសារដើម ១ ច្បាប់ ឬ

ខ- នៅពេលណាឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានផ្តល់ក្នុងទំរង់អាចចរចាបាន "តាមការបញ្ជា" ទៅអោយបុគ្គលដែលមានឯកសារដើមមួយច្បាប់ ដោយមានចំណារឯកភាពត្រឹមត្រូវតាមច្បាប់ ឬ

គ- នៅពេលណាដែលឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានផ្តល់ ឬ (ចេញអោយ) ក្នុងទំរង់អាចចរចាបាន ទៅអោយបុគ្គលដែលមានឈ្មោះកំណត់ណាមួយ ដែលជាបុគ្គលមានភ័ស្តុតាងបញ្ជាក់ពីអត្តសញ្ញាណរបស់គាត់ និងមានកាន់ជាប់ឯកសារដើម ០១ ច្បាប់ ។ ប្រសិនបើឯកសារបែបនេះត្រូវបានផ្ទេរ "តាមការបញ្ជា" ឬប្រសិនបើទុកចំហ នោះបទប្បញ្ញត្តិនៃចំណុច " ខ " ខាងលើត្រូវបានគេយកមកអនុវត្ត ឬ

ឃ- នៅពេលណាដែលឯកសារដឹកជញ្ជូនពហុរូបភាពត្រូវបានផ្តល់ ក្នុងទំរង់មិនអាចចរចាបានទៅអោយបុគ្គលកំណត់ឈ្មោះថា ជាអ្នកទទួលទំនិញនៅក្នុងឯកសារដោយមានភ័ស្តុតាងបញ្ជាក់អត្តសញ្ញាណរបស់គាត់ ឬ

ង- នៅពេលណាដែលគ្មានឯកសារណាមួយត្រូវបានផ្តល់ទៅអោយបុគ្គល ដូចបានណែនាំដោយអ្នកប្រគល់ទំនិញ ឬ ដោយបុគ្គលដែលបានទទួលសិទ្ធិពីអ្នកប្រគល់ទំនិញ ឬ អ្នកទទួលទំនិញ ដែលស្ថិតនៅក្រោមកិច្ចសន្យាដឹកជញ្ជូនពហុរូបភាពក្នុងការផ្តល់ការណែនាំដូចនោះ ។

មាត្រា ១០

១- ប្រតិបត្តិការដឹកជញ្ជូនពហុរូបភាព ត្រូវទទួលខុសត្រូវលើការបាត់បង់បណ្តាលមកពីការបាត់បង់ទំនិញព្រមទាំងការបាត់បង់បណ្តាលមកពីការយឺតយ៉ាវក្នុងការចែកចាយទំនិញ ប្រសិនបើដាហេតុការណ៍ដែលបណ្តាលអោយមានការខូចខាត បាត់បង់ ឬ យឺតយ៉ាវក្នុងការប្រគល់ទំនិញបានកើតឡើង នៅពេលដែលទំនិញនៅក្នុងបន្ទុកទទួលខុសត្រូវរបស់ប្រតិបត្តិករ ដូចបានរំចែងក្នុងមាត្រា ៧ លើកលែងតែប្រតិបត្តិករដឹកជញ្ជូនពហុរូបភាពមានភ័ស្តុតាងបញ្ជាក់ថាខ្លួនគាត់ជាឬអ្នកបំពើរបស់គាត់ ភ្នាក់ងាររបស់គាត់ ឬ របស់បុគ្គលផ្សេងណាមួយ ដូចបានចែងក្នុងមាត្រា ៨ ដែលបានចាត់វិធានការទាំងអស់ ដែលអាចជាតំរូវការដ៏សមហេតុផលរបស់គាត់ ដើម្បីបញ្ឈៀសឧបត្តិហេតុដែលបានកើតឡើង និងផលវិបាករបស់វា ។

The Annex is subject to ratification or acceptance of the Governments of the Contracting Parties. The same applies to an amendment to the Annex, if any.

Article 7: Entry into Force

The Annex will enter into force on the day that at least two Contracting Parties have ratified or accepted it, and will become effective only among the Contracting Parties that have ratified or accepted it. The same applies to an amendment to the Annex, if any.

Article 8: Conforming National Law

Where necessary, the Contracting Parties undertake to conform their relevant national legislation with the contents of the Annex.

Article 9: Reservations

No reservation to the Annex shall be permitted.

Article 10: Suspension of the Annex

Each Contracting Party may temporarily suspend wholly or partly the application of the Annex with immediate effect in the case of emergencies affecting its national safety. The Contracting Party will inform the other Contracting Parties as soon as possible of such suspension, which will end as soon as the situation returns to normal.

Article 11: Relationship with the Agreement

As a measure to implement the principles laid down in the Agreement, the Annex cannot depart from or be contrary to these principles. In case of incompatibility between the Annex and the Agreement, the latter shall prevail. In case of incompatibility between the Annex and another annex or protocol, such incompatibility shall be interpreted in light of the Agreement.

Article 12: Dispute Settlement

Any dispute between or among two or more Contracting Parties on the interpretation or application of the Annex shall be settled directly or by amicable negotiation in the Joint Committee.

Article 13: Denunciation

Once entered into force, the Annex cannot be denounced separately from the Agreement.

In witness whereof, the undersigned, being duly authorized, have signed this Annex.

Done at Vientiane on 16 December 2004 in six originals in the English language.

Signed:

For the Royal Government of Cambodia

(SGD) His Excellency Khy Taing Lim
Senior Minister to the Prime Minister's Office

For the Government of the People's Republic of China

(SGD) His Excellency Liao Xiaojun
Vice Minister of Finance

For the Government of the Lao People's Democratic Republic

(SGD) His Excellency Sommad Pholsena
Vice Minister of Communication, Transport, Post and Construction

For the Government of the Union of Myanmar

(SGD) His Excellency Soe Tha
Minister for National Planning and Economic Development

For the Government of the Kingdom of Thailand

(SGD) His Excellency Nikorn Chamnong
Deputy Minister of Transport

For the Government of the Socialist Republic of Viet Nam

(SGD) His Excellency Tran Dinh Khien
Vice Minister of Planning and Investment

ពិធីសារទី ១

ការកំណត់ផ្លូវរបៀង និងតំរាយផ្លូវ ព្រមទាំងចំណុចចេញ-ចូល(ការឆ្លងកាត់ព្រំដែន)

ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

(តទៅហៅកាត់ថា " ពិធីសារទី១ ")

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋ សង្គមនិយមវៀតណាម (តទៅហៅកាត់ថា ភាគីចុះកិច្ចសន្យា)

ដោយយោងទៅលើ កិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាតំបូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០១ នៅយ៉ាងហ្គុន ដែលបានឯកភាពយល់ព្រមចូលដោយព្រះរាជាណាចក្រកម្ពុជា នៅយ៉ាងហ្គុន នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១ បានយល់ព្រមចូលដោយសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូលដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី តទៅហៅកាត់ថា" កិច្ចព្រមព្រៀង"

ដោយយោងទៅលើមាត្រាទី ៣(ប៊េ)និង(អ៊ិន)នៃកិច្ចព្រមព្រៀង ដែលបានចែងថា ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលាមានលក្ខណៈពិសេស ទៅតាមទីកន្លែង ហើយដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង នឹងមានតំលៃចូលរួមស្មើៗគ្នា

ដោយយោងទៅលើ មាត្រាទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានធ្វើវិសោធនកម្មរួចហើយ ដែលឧបសម្ព័ន្ធ និងពិធីសារនិមួយៗអាចត្រូវបានគេចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីគ្នា ដាច់ចេញអំពីកិច្ចព្រមព្រៀង

ដោយយោងទៅលើ កិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានីលឡា ក្នុងខែមករា ឆ្នាំ ២០០០, កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តិទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ ២០០២ និងកិច្ចប្រជុំលើកទី១១ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ ២០០២ ដែលរដ្ឋមន្ត្រី GMS ទាំងអស់ បានឯកភាពយល់ព្រមទៅនឹងផែនការការងារមួយ ក្នុងការបង្ហើយបញ្ចប់កិច្ចព្រមព្រៀង និងឧបសម្ព័ន្ធ-ពិធីសារបស់វា ក្នុងឆ្នាំ ២០០៥

ដោយយោងទៅលើមាត្រាទី៦ ២០ និង២៥ នៃកិច្ចព្រមព្រៀង ដែលបានស្នើឱ្យរៀបចំពិធីសារនេះ ដើម្បីចែងជាកត្តាផ្សេងៗ

បានព្រមព្រៀងគ្នាដូចខាងក្រោម :

មាត្រា ១.- ផ្លូវរបៀង, ផ្លូវថ្នល់ ហើយនិងច្រកឆ្លងកាត់ព្រំដែន

ផ្លូវរបៀង,ផ្លូវថ្នល់ និងច្រកឆ្លងកាត់ព្រំដែន ដែលអនុវត្តក្នុងកិច្ចកិច្ចព្រមព្រៀង ត្រូវបានគេបញ្ចូលក្នុងឯកសារភ្ជាប់ នៃពិធីសារនេះ បញ្ជីនៃផ្លូវរបៀង, ផ្លូវថ្នល់ និងច្រកឆ្លងកាត់ព្រំដែន និងផែនទីភ្ជាប់ ទំហំ A4 (A4-format) ។

មាត្រា ២.- ការបើកបន្ថែម ច្រកឆ្លងកាត់ព្រំដែន និងផ្លូវផ្សេងទៀត

ភាគីចុះកិច្ចសន្យាមួយក្រុម ត្រូវបានគេផ្តល់សិទ្ធិក្នុងការបើកបន្ថែម ច្រកឆ្លងកាត់ព្រំដែន និងផ្លូវផ្សេងទៀត បន្ថែមទៅលើច្រកឆ្លងកាត់ព្រំដែន និងផ្លូវទាំងឡាយ ដែលត្រូវបានគេលើកឡើងជាលើកដំបូងនៅក្នុងពិធីសារនេះ។ តាមរយៈអនុស្សារណៈនៃការយោគយល់គ្នា រវាង និងក្នុងរង្វង់ពួកគេទាំងនោះ ។ ការបើកបន្ថែម ច្រកឆ្លងកាត់ព្រំដែន ឬផ្លូវទាំងឡាយបែបនេះ ត្រូវបានគេទទួលស្គាល់ដុចគ្នា ដូចស្ថានភាព នៃច្រកឆ្លងកាត់ព្រំដែន ឬផ្លូវទាំងឡាយ ដែលបានលើកឡើងជាលើកដំបូងនៅក្នុងពិធីសារនេះ ។ រាល់ការបើកបន្ថែមណាមួយ ត្រូវបានគេជូនដំណឹងយ៉ាងរហ័សជូនទៅគណៈកម្មាធិការរួម ហើយនឹងដាក់បញ្ចូលនៅក្នុងមាត្រា ១ នៃពិធីសារនេះ តាមរយៈការធ្វើវិសោធនកម្ម ។ ទោះបីជាយ៉ាងណាក៏ដោយ ការបើកបន្ថែមនូវច្រកឆ្លងកាត់ព្រំដែនបែបនេះ អាចបើកឱ្យប្រើប្រាស់បាននៅមុនពេលមានការផ្តល់សច្ចាប័ន ឬការ យល់ព្រមទៅលើការធ្វើវិសោធនកម្មបែបមួយនេះ ហើយដែលផ្តល់ឱ្យពួកគេនូវលក្ខណៈគ្រប់គ្រាន់ និងតំរូវការដូចគ្នា ដូចជាច្រក ឆ្លងកាត់ព្រំដែន ឬផ្លូវទាំងឡាយ ដែលបានលើក ឡើងជាលើកដំបូងនៅក្នុងពិធីសារនេះ ។

មាត្រា ៣.- ការធ្វើវិសោធនកម្ម

ភាគីនៃកិច្ចសន្យាអាចស្នើសុំការធ្វើវិសោធនកម្មទៅលើពិធីសារនេះ តាមរយៈគណៈកម្មាធិការរួម ការធ្វើវិសោធនកម្មបែបនេះនឹងត្រូវជាកម្មវត្ថុនៃការយល់ព្រមជាឯកឆន្ទៈនៃភាគីនៃកិច្ចសន្យាទាំងអស់ ។

មាត្រា ៤.- ការផ្តល់សច្ចាប័ន ឬការយល់ព្រមទទួលយក

ពិធីសារនេះ គឺជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រមទទួលយករបស់រដ្ឋាភិបាលនៃភាគីកិច្ចសន្យា ។ ការអនុវត្តន៍ដូចៗគ្នានេះ ត្រូវបានគេអនុវត្តចំពោះការធ្វើវិសោធនកម្មទៅលើពិធីសារ ប្រសិនបើមាន ។

មាត្រា ៥.- ការចូលជាធរមាន

ពិធីសារនឹងចូលជាធរមាននៅថ្ងៃដែលមានភាគីនៃកិច្ចសន្យាចំនួន២ យ៉ាងតិចបានផ្តល់សច្ចាប័ន ឬការយល់ព្រមទទួលយក ហើយនិងត្រូវមានប្រសិទ្ធិភាពនៅត្រឹមតែក្នុងចំណោមភាគីនៃកិច្ចសន្យាដែលបានផ្តល់សច្ចាប័ន ឬការយល់ព្រមទទួលយក ពិធីសារនេះប៉ុណ្ណោះ ។ ការអនុវត្តដូច១គ្នា ត្រូវបានគេអនុវត្តចំពោះការធ្វើវិសោធនកម្ម ទៅលើពិធីសារ ប្រសិនបើមាន។

មាត្រា ៦. ការកែសំរួលច្បាប់ជាតិ

នៅចំណុចណាដែលចាំបាច់ ភាគីចុះកិច្ចសន្យា ត្រូវធានាធ្វើការកែសំរួលច្បាប់ជាតិដែលពាក់ព័ន្ធ ឱ្យស្របទៅតាមខ្លឹមសារនៃពិធីសារ ។

មាត្រា ៧.- ការដាក់លក្ខខ័ណ្ឌ

ការដាក់លក្ខខ័ណ្ឌ ទៅលើឧបសម្ព័ន្ធ មិនត្រូវបានគេអនុញ្ញាតឡើយ ។

មាត្រា ៨.- ការព្យួរទុកនូវពិធីសារ

ភាគីចុះកិច្ចសន្យានិមួយ១អាចព្យួរទុក ជាបណ្តោះអាសន្ន នូវការអនុវត្តន៍ពិធីសារទាំងស្រុង ឬក៏មួយចំណែក ដែលមានប្រឈិទ្ធិភាពភ្លាម១ នៅក្នុងករណីមានការវិកវរជាអាសន្ន ដែលប៉ះពាល់ដល់សុវត្ថិភាព របស់ជាតិខ្លួន។ ភាគីចុះកិច្ចសន្យា នីងជូនពត៌មានទៅភាគីចុះកិច្ចសន្យាផ្សេងទៀតភ្លាម១ តាមតែអាចធ្វើទៅបាន អំពីការព្យួរទុក និងការបញ្ចប់ការព្យួរទុកនេះឱ្យបានឆាប់បំផុត នៅពេលណាដែលសភាពការណ៍វិលត្រឡប់ទៅរកស្ថានភាពជាធម្មតាឡើងវិញ។

មាត្រា ៩.- សម្ព័ន្ធភាពជាមួយនីតិកិច្ចព្រមព្រៀង

ដោយសារតែវាជាវិធានការមួយក្នុងការអនុវត្តន៍គោលការណ៍ទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ពិធីសារនេះមិនអាចផ្តាច់ចេញ ឬក៏ក្លាយជាផ្ទុយទៅនឹងគោលការណ៍ទាំងនេះបានទេ។ នៅក្នុងករណីដែលវិសមិត (មិនចុះសំរុងគ្នា-មិនត្រូវគ្នា) រវាងពិធីសារ និងកិច្ចព្រមព្រៀង នោះកិច្ចព្រមព្រៀងត្រូវយកជាបានការ-ជាគោល។ នៅក្នុងករណីដែលវិសមិត(មិនចុះសំរុងគ្នា-មិនស៊ីគ្នា)រវាងពិធីសារ និងឧបសម្ព័ន្ធ ឬពិធីសារផ្សេងទៀតនោះ វិសិមិតភាពនេះ ត្រូវយកទៅបកស្រាយជាមួយគ្នា នីងកិច្ចព្រមព្រៀង។

មាត្រា ១០.- ឯកសារភ្ជាប់ (ឬឯកសារគ្នាប់) ដែលចងភ្ជាប់ទៅនឹងពិធីសារ

ឯកសារភ្ជាប់ ត្រូវបង្កើតជាផ្នែកមួយបញ្ចូលគ្នាមួយ ជាមួយឧបសម្ព័ន្ធ និងត្រូវមានតំលៃចូលរួមស្មើៗគ្នា ។

មាត្រា ១១.- ការដោះស្រាយជំលោះ

ជំលោះណាមួយរវាងឬក្នុងភាគី0២ ឬច្រើននៃភាគីចុះកិច្ចសន្យា ទៅលើការបកស្រាយ ឬការអនុវត្តន៍ពិធីសារ ត្រូវស្រុះស្រួលគ្នា លើកយកមកដោះស្រាយដោយផ្ទាល់ ឬដោយការចរចារតាមគោលការណ៍សន្តិវិធី តាមរយៈ គណៈកម្មាធិការរួម។

មាត្រា ១២.- ការប្រកាសបដិសេធ

នៅពេលចូលជាធរមាន ពិធីសារមិនអាចត្រូវបានប្រកបកាសបដិសេធ ដាច់ដោយឡែកចេញពីកិច្ចព្រមព្រៀងទេ

ឯកសារភ្ជាប់ទៅនឹង ពិធីសារទី១ : បញ្ជីនៃផ្លូវរបៀង, ផ្លូវថ្នល់ និងច្រកឆ្លងកាត់ព្រំដែន និងផែនទីភ្ជាប់ ទំហំ A4 (A4-format)

ដើម្បីជាសក្ខីភាពនោទីនេះ ហត្ថលេខីខាងក្រោម ដោយមានការផ្តល់សិទ្ធិយ៉ាងពេញលេញពីអជ្ញាធររៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារនេះ ។

ធ្វើនៅ ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ ជា០៦ ច្បាប់ដើម ជាភាសាអង់គ្លេស ។

ហត្ថលេខា :

តំណាងរាជរដ្ឋាភិបាលកម្ពុជា
ឯកឧត្តម **ត្រាំ ស៊ុវតីក** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
ឯកឧត្តម **ហ៊ូ ស៊ុហ៊ុ** អនុរដ្ឋមន្ត្រី គមនាគមន៍

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
ឯកឧត្តម **សមាំដ ដុលសេនា** អនុរដ្ឋមន្ត្រីគមនាគមន៍ ដឹកជញ្ជូន ប៉ុស្តិ៍ និងសំណង់

តំណាងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា
ឯកឧត្តម **ចូ ម៉ា ថង់ឌីន** អនុរដ្ឋមន្ត្រី ដឹកជញ្ជូនផ្លូវដែក

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍
ឯកឧត្តម **និកន ចំណុច** អនុរដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
ឯកឧត្តម **ដាំ ថេមិញ** អនុរដ្ឋមន្ត្រីដឹកជញ្ជូន

ឯកសារភ្ជាប់ទី១ : តារាងបញ្ជីរ នៃការកំនត់ផ្លូវរបៀង, ផ្លូវថ្នល់ ហើយនិងច្រកឆ្លងកាត់ព្រំដែន

ចំណាំ : ផ្លូវ និងច្រកឆ្លងកាត់ព្រំដែនក្នុងវង់ដង្កៀប [ ]នៅរង់ចាំការបញ្ជាក់តាមក្រោយ

១-របៀងសេដ្ឋកិច្ច ខាងជើង — ខាងត្បូង

a) ច្រកផ្លូវ : គុនមិញ-យូស៊ី-យូនជាំង-មូហ៊ី-ស៊ីម៉ៅ-ស៊ីអូមីនយាង-មូហាន (ចិន) បូទិន-ហួយសាយ(ឡាវ) ឆ្យេងខុង-ឆ្យេងរ៉ៃ-តាក-បាងកក(ថៃ)

(I) ច្រកឆ្លងកាត់ព្រំដែន :មូហាន (ចិន) - បូទិន (ឡាវ)

(II) ច្រកឆ្លងកាត់ព្រំដែន : ហួយសាយ(ឡាវ) - ឆ្យេងខុង(ថៃ)

b) ច្រកផ្លូវ : គីងតុង តាជីលេក(មីយ៉ាន់មា) - មេសៃ - ឆ្យេងរ៉ៃ - តាក - បាងកក(ថៃ)

(I) ច្រកឆ្លងកាត់ព្រំដែន : តាជិលិក(មីយ៉ាន់មា) - មេសៃ(ថៃ)

c) ច្រកផ្លូវ : គុនមិញ-មៃលី-យីនសាវ - កៃយូន មេងស៊ី - ហេគូ(ចិន) - ឡាវកៃ-ហាណូយ-ហៃហ្វុង (វៀតណាម) ។

(I) ច្រកឆ្លងកាត់ព្រំដែន : ហេគូ(ចិន) -ឡាវកៃ(វៀតណាម)

២-របៀងសេដ្ឋកិច្ច ខាងកើត - ខាងលិច

a) ច្រកផ្លូវ ម៉ាវឡាម្យៀន-មីយ៉ាវ៉ាឌី(មីយ៉ាន់ម៉ា) -មេសត-ពិស្ណុលោក-ខនខ្យែន-កាឡាស៊ីន -មុកដា ហាន(ថៃ) -សាវ៉ាន់ណាខេត្ត-ដានសាវ៉ាញ់(ឡាវ) -ឡាវបៅ-ដុងហា-រ៉ៅ-ដាណាង(វៀតណាម)

(I) ច្រកឆ្លងកាត់ព្រំដែន : មីយ៉ាវ៉ាឌី(មីយ៉ាន់ម៉ា) -មេសត(ថៃ)

(II) ច្រកឆ្លងកាត់ព្រំដែន : ម៉ុកដាហាន(ថៃ) -សាវ៉ាន់ណាខេត្ត(ឡាវ)

(III) ច្រកឆ្លងកាត់ព្រំដែន : ដានសាវ៉ាញ់(ឡាវ) -ឡាវបៅ(វៀតណាម)

៣-របៀងសេដ្ឋកិច្ច ចែកខាងត្បូង

a) ច្រកផ្លូវ :<បាងកក-កាបីនបួរី-ស្រះកែវ-អារញ្ញប្រាថេទ ឬ បាងកក-លៀមចាបាង-ភ្នំសារាខាំ-កាបីនបួរី-ស្រះកែវ-អារញ្ញប្រាថេទ"(ថៃ)>-បោយប៉ែត-ស៊ីសុផុន ពោធិសាត់- ភ្នំពេញ-អ្នកលឿង-បាវិត(កម្ពុជា) -ម៉ុកបៃ-ទីក្រុងហូជីមិញ-វ៉ុងតាវ(វៀតណាម)

(I) ច្រកឆ្លងកាត់ព្រំដែន : អារញ្ញប្រាថេទ"(ថៃ) -បោយប៉ែត(កម្ពុជា)

(II) ច្រកឆ្លងកាត់ព្រំដែន :បាវិត(កម្ពុជា) -ម៉ុកបៃ(វៀតណាម)

b) [ច្រកផ្លូវ បាងកក-ត្រាត-ហាតលេក(ថៃ) -ចាំយាម-កោះកុង-ស្រែអំបិល-កំពត-លក(កម្ពុជា) ហាទៀន-កាមូ-ណាមខេន(វៀតណាម)]

(I) ច្រកឆ្លងកាត់ព្រំដែន : ហាតលេក(ថៃ) -ចាំយាម(កម្ពុជា)

(II) ច្រកឆ្លងកាត់ព្រំដែន : លក(កម្ពុជា)

៤-ផ្លូវរបៀងធំ, ផ្លូវថ្នល់, និងច្រកឆ្លងកាត់ព្រំដែនផ្សេងទៀត

a) ច្រកផ្លូវ : គុនមិញ-ចួសុង-ដាលី-បៅហ្សាន-រូលី(ចិន) -មូសេ-ឡាសៅ(មីយ៉ាន់ម៉ា)

(I) ច្រកកាត់ព្រំដែន : រូលី(ចិន) -មូសេ(មីយ៉ាន់ម៉ា)

b) ច្រកផ្លូវ : វៀងច័ន្ទ-បានឡាវ-ថាកហិក-សិនូ-ថាកសេ(ឡាវ) -ឡាវ/ព្រំដែនកម្ពុជា(វ៊ឺនខាំ) -ស្ទឹងត្រែង-ក្រចេះ-ភ្នំពេញ-ក្រុងព្រះសីហនុ(កម្ពុជា)

(I) ច្រកឆ្លងកាត់ព្រំដែន :វ៊ឺនខាំ(ឡាវ), ដុងក្រឡ(កម្ពុជា)

c) ច្រកផ្លូវ : ណាទើយ-ឧត្តមសៃ-ជាកមុង-លួងប្រាបាង-វៀងច័ន្ទ-ថាណាឡេង(ឡាវ)-នងខៃ-ឧដុនថានី-ខុនកែន-បាងកក(ថៃ)

(I) ច្រកឆ្លងកាត់ព្រំដែន : ថាណាឡេង(ឡាវ) - នងខៃ(ថៃ)

d) ច្រកផ្លូវ : វៀងច័ន្ទ-បូលីខាមសាយ(ឡាវ)-ហាទិញ(វៀតណាម)

(I) ច្រកឆ្លងកាត់ព្រំដែន : ណាម ផៅ(ឡាវ)-កៅត្រូ(វៀតណាម)

e) [ច្រកផ្លូវ :ចំប៉ាសាក់(ឡាវ)-ឧប្បលរាជធានី(ថៃ)]

(I) ច្រកឆ្លងកាត់ព្រំដែន : ភីងតៅ(ឡាវ)-ចុងមេក(ថៃ)

PROTOCOL 1: DESIGNATION OF CORRIDORS, ROUTES, AND POINTS OF ENTRY AND EXIT (BORDER CROSSINGS)

To the Agreement between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam

for the Facilitation of Cross-Border Transport of Goods and People

(hereinafter referred to as the "Protocol")

The Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam (hereinafter referred to as the "Contracting Parties"),

Referring to the Agreement between and among the Governments of the Lao People's Democratic Republic, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People, originally signed on 26 November 1999 at Vientiane, amended at Yangon on 29 November 2001, acceded to by the Kingdom of Cambodia at Yangon on 29 November 2001, acceded to by the People's Republic of China on 3 November 2002 at Phnom Penh, and acceded to by the Union of Myanmar on 19 September 2003 at Dali City (hereinafter referred to as "the Agreement"),

Referring to Articles 3(b) and (n) of the Agreement to the effect that Annexes and Protocols contain technical details or time- and/or site-specific variable elements and that they form an integral part of the Agreement and are equally binding,

Referring to Article 36 of the Agreement, as amended, per which the Agreement may be signed and ratified or accepted and enter into force separately from the Annexes and Protocols,

Referring to the Ninth GMS Ministerial Conference held in Manila in January 2000, the Seventh Meeting of the Subregional Transport Forum held in Ho Chi Minh City in August 2002, and the 11th GMS Ministerial Conference held in Phnom Penh in September 2002, where the Governments agreed to a work program to finalize the Agreement and its Annexes and Protocols by 2005, and

Referring to Articles 6, 20, and 25 of the Agreement, calling for this Protocol to provide variable elements,

HAVE AGREED AS FOLLOWS:

Article 1: Corridors, Routes and Border Crossings

The corridors/routes and border crossings to which the Agreement applies shall be as prescribed in the Attachment to this Protocol: "List of Corridors, Routes and Border Crossings", and Associated Map (A4-format).

Article 2: Opening of Additional Border Crossings and Routes

In addition to the border crossings and routes originally designated in this Protocol, groups of Contracting Parties are entitled to open additional border crossings and routes through a memorandum of understanding between or among them. Such additional border crossings or routes will enjoy the same status as the originally designated ones. Any such opening will be promptly notified to the Joint Committee and put forward for inclusion in Article 1 of this Protocol by amendment. However, such additional border crossings may be opened before ratification or acceptance of such an amendment, provided they satisfy the same requirements as the originally designated ones.

Article 3: Amendment

Any Contracting Party may propose amendments to the Protocol via the Joint Committee. Such amendments shall be subject to the unanimous consent of the Contracting Parties.

Article 4: Ratification or Acceptance

The Protocol is subject to ratification or acceptance of the Governments of the Contracting Parties. The same applies to an amendment to the Protocol, if any.

Article 5: Entry into Force

The Protocol will enter into force on the day that at least two Contracting Parties have ratified or accepted it, and will become effective only among the Contracting Parties that have ratified or accepted it. The same applies to an amendment to the Protocol, if any.

Article 6: Conforming National Law

Where necessary, the Contracting Parties undertake to conform their relevant national legislation with the contents of the Protocol.

Article 7: Reservations

No reservation to the Protocol shall be permitted.

Article 8: Suspension of the Protocol

Each Contracting Party may temporarily suspend wholly or partly the application of the Protocol with immediate effect in the case of emergencies affecting its national safety. The Contracting Party will inform the other Contracting Parties as soon as possible of such suspension, which will end as soon as the situation returns to normal.

Article 9: Relationship with the Agreement

As a measure to implement the principles laid down in the Agreement, the Protocol cannot depart from or be contrary to these principles. In case of incompatibility between the Protocol and the Agreement, the latter shall prevail. In case of incompatibility between the Protocol and an annex or another protocol, such incompatibility shall be interpreted in light of the Agreement.

Article 10: Relationship of the Attachments to the Protocol

The attachments shall form an integral part of the Protocol and shall be equally binding.

Article 11: Dispute Settlement

Any dispute between or among two or more Contracting Parties on the interpretation or application of the Protocol shall be settled directly or by amicable negotiation in the Joint Committee.

Article 12: Denunciation

Once entered into force, the Protocol cannot be denounced separately from the Agreement.

Attachment to Protocol 1: *List of Corridors, Routes and Border Crossings, and Associated Map (A4-format)*

In witness whereof, the undersigned, being duly authorized, have signed this Protocol.

Done at Phnom Penh on 30 April 2004 in six originals in the English language.

Signed:

For the Royal Government of Cambodia

(signed)

His Excellency Tram Iv Tek

Secretary of State, Ministry of Public Works and Transport

For the Government of the People's Republic of China

(signed)

His Excellency Hu Xijie

Vice Minister of Communications

For the Government of the Lao People's Democratic Republic

(signed)

His Excellency Sommad Pholsena

Vice Minister of Communication, Transport, Post and Construction

For the Government of the Union of Myanmar

(signed)

His Excellency Thura Thaung Lwin

Deputy Minister of Rail Transportation

For the Government of the Kingdom of Thailand

(signed)

His Excellency Nikorn Chamnong

Deputy Minister of Transport

For the Government of the Socialist Republic of Viet Nam

(signed)

His Excellency Pham The Minh

Vice Minister of Transport

Attachment 1: List of Corridors, Routes, and Border Crossings

1. North-South Economic Corridor:

   a) Route: Kunming-Yuxi-Yuanjiang-Mohei-Simao-Xiaomenyang-Mohan (CHN)-Boten-Houayxay (LAO)-Chiang Khong-Chiang Rai-Tak-Bangkok (T)

      (i) Border Crossing: Mohan (CHN) – Boten (LAO)

      (ii) Border Crossing: Houayxay (LAO) – Chiang Khong (T)

   b) Route: Kengtung-Tachilek (MYA)-Mae Sai-Chiang Rai-Tak-Bangkok (T)

      (i) Border Crossing: Tachilek (MYA) – Mae Sai (T)

   c) Route: Kunming-Mile-Yinshao-Kaiyuan-Mengzi-Hekou (CHN)-Lao Cai-Hanoi-Haiphong (VN)

      (i) Border Crossing: Hekou (CHN) – Lao Cai (VN)

2. East-West Economic Corridor:

   a) Route: Mawlamyine-Myawaddy (MYA)-Mae Sot-Phitsanulok-Khon Kaen-Kalasin-Mukdahan (T)-Savannakhet-Dansavanh (LAO)-Lao Bao-Dong Ha-Hue-Da Nang (VN)

      (i) Border Crossing: Myawaddy (MYA) – Mae Sot (T)

      (ii) Border Crossing: Mukdahan (T) – Savannakhet (LAO)

      (iii) Border Crossing: Dansavanh (LAO) – Lao Bao (VN)

3. Southern Economic Corridor:

   a) Route: <Bangkok-Kabin Buri-Sra Kaeo-Aranyaprathet OR Bangkok-Laem Chabang-Phanom Sarakham-Kabin Buri-Sra Kaeo-Aranyaprathet> (T)-Poipet-Sisophon-Pursat-Phnom Penh-Neak Loueng-Bavet (KH)-Moc Bai-Ho Chi Minh City-Vung Tau (VN)

      (i) Border Crossing: Aranyaprathet (T) – Poipet (KH)

      (ii) Border Crossing: Bavet (KH) – Moc Bai (VN)

   b) Route: Bangkok-Trat-Hat Lek (T)-Cham Yeam-Koh Kong-Sre Ambil-Kampot-Lork (KH)

      (i) Border Crossing: Hat Lek (T) – Cham Yeam (KH)

4. Other Corridors/Routes/Border Crossings:

a) Route: Kunming-Chuxiong-Dali-Baoshan-Ruili (CHN)-Muse-Lashio (MYA)

(i) Border Crossing: Ruili (CHN) – Muse (MYA)

b) Route: Vientiane-Ban Lao-Thakhek-Seno-Pakse (LAO)-LAO/KH border-Stung Treng-Kratie-Phnom Penh-Sihanoukville (KH)

(i) Border Crossing: Veunekham (LAO)/Dong Kralor (KH) border

c) Route: Nateuy-Oudomxai-Pakmong-Louang Phrabang-Vientiane-Thanaleng (LAO)-Nong Khai-Udon Thani-Khon Kaen-Bangkok (T)

(i) Border Crossing: Thanaleng (LAO)-Nong Khai (T)

d) Route: Vientiane-Bolikhamxay (LAO)-Ha Tinh (VN)

(i) Border Crossing: Nam Phao (LAO) – Cau Treo (VN)

e) Route: Champassak (LAO)-Ubon Ratchathani (T)

(i) Border Crossing: Wang Tao (LAO)-Chong Mek (T)


ASSOCIATED MAP FOR PROTOCOL 1
YUNNAN PROVINCE OF PRC
MYANMAR
LAO PDR
THAILAND
CAMBODIA
VIET NAM
HANOI
YANGON
BANGKOK
PHNOM PENH
Gulf of Tonkin
Gulf of Martaban
Gulf of Thailand
SOUTH CHINA SEA
Dali
Kunming
Chuxiong
Yuxi
Ruili
Muse
Lashio
Thibaw
Yuanjiang
Hekou
Lao Cai
Jinghong
Mandalay
Kengtung
Tachilek
Mae Sai
Houayxay
Pak Mong
Chiang Rai
Chiang Khong
Luang Prabang
Chiang Mai
Vang Vieng
Pakkading
VIENTIANE
Ha Tinh
Nong Khai
Thakhek
Udon Thani
Muang Phin
Dansavanh
Lao Bao
Dong Ha
Hue
Tak
Phitsanulok
Mukdahan
Savannakhet
Da Nang
Myawaddy
Mawlamyine
Mae Sot
Khon Kaen
Chongmek
Pakse
Kabin Buri
Aranyaprathet
Sisophon
Siem Reap
Dong Kralor
Poipet
Laem Chabang
Petchaburi
Hat Lek
Chan Yoam
Neak Loung
Bavet
Moc Bai
Ho Chi Minh City
Sihanoukville
Vung Tau
Phuket
Songkhla
0 50 100 200 300
Kilometers
National Capital
City/Town
Agreed Routes
River
Provincial Boundary
International Boundary
Boundaries are not necessarily authoritative

ទិសោធនកម្មនៃមាត្រាទី១៧ នៃ
កិច្ចព្រមព្រៀងរវាង នឹងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន
សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់
និងសាធារណរដ្ឋសង្គមនិយមវៀតណាម
ស្តីអំពីការសំរួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ និងសាធារណរដ្ឋសង្គមនិយមវៀតណាម (តទៅហៅកាត់ថា "ភាគីចុះកិច្ចសន្យា")

យោងទៅលើកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាតំបូងនៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ នៅវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០១ នៅយ៉ាងហ្គុន ដែលបានយល់ព្រមចូលដោយ ព្រះរាជាណាចក្រកម្ពុជា នៅយ៉ាងហ្គុន នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០១ បានយល់ព្រមចូលដោយសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូលដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី (តទៅហៅកាត់ថា "កិច្ចព្រមព្រៀង")។

ដោយយោងទៅលើមាត្រាទី២ នៃអនុស្សារណៈនៃកិច្ចព្រមព្រៀង រវាង និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រ ថៃឡង់ និងសាធារណរដ្ឋ សង្គមនិយមវៀតណាម ដែលបានចុះហត្ថលេខានៅភ្នំពេញ នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ ដែលមានសន្យាពីភាគីចុះហត្ថលេខា ក្នុងការធ្វើវិសោធនកម្ម មាត្រាទី៧ (ប័ណ្ណបើកបរ) នៃកិច្ចព្រមព្រៀង និង

យោងទៅលើមាត្រាទី ៤៣ នៃកិច្ចព្រមព្រៀង ស្តីអំពីការធ្វើវិសោធនកម្ម នៃកិច្ចព្រមព្រៀង

បានព្រមព្រៀងគ្នាដូចខាងក្រោម :

មាត្រា ១ ..

ចំណងជើងនៃមាត្រា១៧ នៃកិច្ចព្រមព្រៀង ត្រូវបានកែប្រែដូចតទៅ :

" **មាត្រា ១៧ .. ចំណុះបើកបរ** "

ភាគីចុះកិច្ចសន្យា ត្រូវទទួលស្គាល់ទៅវិញទៅមក នូវប័ណ្ណបើកបរ ដែលចេញឱ្យដោយអជ្ញាធរមានសមត្ថកិច្ច ពាក់ព័ន្ធ ដោយអនុលោមទៅតាម" ឧបសម្ព័ន្ធទី១៦" ។

មាត្រា ២ ..

ត្រូវបញ្ចូលនៅក្នុងតារាងឧបសម្ព័ន្ធ និងពិធីសារ ដែលភ្ជាប់ជាមួយកិច្ចព្រមព្រៀង នូវពាក្យថ្មី

" **ឧបសម្ព័ន្ធទី១៦ : លក្ខណៈវិនិច្ឆ័យ សំរាប់ការផ្តល់ចំណុះបើកបរ** " ។

មាត្រា ៣ ..

វិសោធនកម្មនៃកិច្ចព្រមព្រៀងនេះ គឺជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រមពីគ្រប់ ភាគីចុះកិច្ចសន្យា ។

មាត្រា ៤ ..

វិសោធនកម្មនៃកិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាន នៅថ្ងៃដែល គ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ បានផ្តល់សច្ចាប័ន ឬការយល់ព្រម ទៅលើវិសោធនកម្ម នៃកិច្ចព្រមព្រៀងនេះ ។

ដើម្បីជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដែលបានទទួលការអនុញ្ញាតពីអជ្ញាធរៗខ្លួន បានចុះហត្ថលេខាលើឧបសម្ព័ន្ធនេះ ។

ធ្វើនៅ **ភ្នំពេញ** ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ ជា០៦ ច្បាប់ដើម ជាភាសាអង់គ្លេស ។

ហត្ថលេខា :

តំណាងរាជរដ្ឋាភិបាលកម្ពុជា
ឯកឧត្តម **ត្រាំ អ៊ុតតឹក** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
ឯកឧត្តម **ហ៊ូ ស៊ីហ៊ុ** អនុរដ្ឋមន្ត្រី គមនាគមន៍

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ
ឯកឧត្តម **សមាំដ ផុលសេនា** អនុរដ្ឋមន្ត្រីគមនាគមន៍ ដឹកជញ្ជូន ប៉ុស្តិ៍ និងសំណង់

តំណាងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា
ឯកឧត្តម **ចូ ម៉ា ថង់ឌីន** អនុរដ្ឋមន្ត្រី ដឹកជញ្ជូនផ្លូវដែក

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍
ឯកឧត្តម **ឌីកន ចំណុច** អនុរដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
ឯកឧត្តម **ដាំ ថេមិញ** អនុរដ្ឋមន្ត្រីដឹកជញ្ជូន

Amendment to Article 17
of the

Agreement between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam

for the Facilitation of Cross-Border Transport of Goods and People

The Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam (hereinafter referred to as "the Contracting Parties"),

Referring to the Agreement between and among the Governments of the Lao People's Democratic Republic, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People, originally signed on 26 November 1999 at Vientiane, amended at Yangon on 29 November 2001, acceded to by the Kingdom of Cambodia at Yangon on 29 November 2001, acceded to by the People's Republic of China on 3 November 2002 at Phnom Penh, and acceded to by the Union of Myanmar on 19 September 2003 at Dali City (hereinafter referred to as "the Agreement"),

Referring to Article 2 of the Memorandum of Understanding between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam, signed at 17 (Driving Permits) of the Agreement, and

Referring to Article 43 of the Agreement on amendment of the Agreement,

HAVE AGREED AS FOLLOWS:

Article 1

The wording of Article 17 of the Agreement is amended to read as follows:

"Article 17: Driving Permits

The Contracting Partics shall mutually recognize the driving licenses issued by their respective competent authorities in accordance with Annex 16."

Article 2

In the list of Annexes and Protocols attached to the Agreement the words "Annex 16: Criteria for Driving Licenses" will be inserted.

Article 3

This amendment to the Agreement is subject to the ratification or acceptance by all the Contracting Parties.

Article 4

This amendment to the Agreement will come into force on the day that all the Contracting Parties have ratified or accepted it.

Amendment to Article 17

In witness whereof, the undersigned, being duly authorized, have signed this Annex.

Done at Phnom Penh on 30 April 2004 in six originals in the English language.

Signed:

For the Royal Government of Cambodia

His Excellency Tram Iv Tek
Secretary of State, Ministry of Public Works and Transport

For the Government of the People's Republic of China

His Excellency Hu Xijie
Vice Minister of Communications

For the Government of the Lao People's Democratic Republic

His Excellency Sommad Pholsena
Vice Minister of Communication, Transport, Post and Construction

For the Government of the Union of Myanmar

His Excellency Thura Thaung Lwin
Deputy Minister of Rail Transportation

For the Government of the Kingdom of Thailand

His Excellency Nikorn Chamnong
Deputy Minister of Transport

For the Government of the Socialist Republic of Viet Nam

His Excellency Pham The Minh
Vice Minister of Transport

In witness whereof, the undersigned, being duly authorized, have signed this Annex.

Done at Phnom Penh on 30 April 2004 in six originals in the English language.

Signed:

For the Royal Government of Cambodia

His Excellency Tram Iv Tek
Secretary of State, Ministry of Public Works and Transport

For the Government of the People's Republic of China

His Excellency Hu Xijie
Vice Minister of Communications

For the Government of the Lao People's Democratic Republic

His Excellency Sommad Pholsena
Vice Minister of Communication, Transport, Post and Construction

For the Government of the Union of Myanmar

His Excellency Thura Thaung Lwin
Deputy Minister of Rail Transportation

For the Government of the Kingdom of Thailand

His Excellency Nikorn Chamnong
Deputy Minister of Transport

For the Government of the Socialist Republic of Viet Nam

His Excellency Pham The Minh
Vice Minister of Transport

(ត មកពីរាជកិច្ចលេខ ៩១-៩២-៩៣)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងសាធារណការ និងដឹកជញ្ជូន

កិច្ចព្រមព្រៀង

រវាង និងក្នុងចន្លោះ

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា
ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនអន្តរជាតិ និងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន

នាយកដ្ឋានផែនការ

ឆ្នាំ ២០០៦

ព្រះរាជក្រម

នស/រកម/០១០៣/០០៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ខ្ញុតតោសុជាត ទិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅច្រ្គងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាង និងក្នុងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយម វៀតណាមស្តីពីការសម្រួលនៃការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាបនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គ លើកទី ៨ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាង
និងក្នុងនោះនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិត
ប្រជាធិបតេយ្យឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយម
វៀតណាម ស្តីពីការសម្រួលនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

មាត្រា ១. -

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងនិងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះ-រាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដែលធ្វើនៅទីក្រុងយ៉ាងហ្គូន ប្រទេសមីយ៉ាន់ម៉ា នាថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២. -

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០៣

ព្រះហស្តលេខា និង ព្រះរាជលញ្ជីតរ

នរោត្តម សីហនុ

៣រស.០៣.០១.០៤០

ចាន់ យ៉ាក លេខាធិការរដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន ចាន់ជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី លេខ: ២៦ ចល

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីចាត់ដំណើរ

ហត្ថលេខា រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៣ ឆ្នាំ ២០០៣

ឃី តាំងលីម អគ្គលេខាធិការរដ្ឋាភិបាល



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាភិបាលកម្ពុជា
លេខ :១៥..ស.ជ.ល/.កប៨

សេចក្តីថ្លែងហេតុ
នៃសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាង និងក្នុងនៅនាមរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពី ការសម្រួលនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងពាណិជ្ជ ឆ្លងកាត់ព្រំដែន

ក- ដើមឡើយកិច្ចព្រមព្រៀងនេះ មាន ១០ ផ្នែក ៤៥ មាត្រា និងមានឧបសម្ព័ន្ធ ១៦ និងពិធីសារ (០៣) ត្រូវបានចុះហត្ថលេខាថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដោយសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម។ ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា ចូលក្នុងកិច្ចព្រមព្រៀងនេះ នៅពេលដែលកិច្ចព្រមព្រៀងនេះ ត្រូវបានគេធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅទីក្រុង យ៉ាងហ្គុន ប្រទេសមីយ៉ាន់ម៉ា ដើម្បីឱ្យប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ អាចចូលបាន ។ កិច្ចព្រមព្រៀងនឹងត្រូវប្តូរឈ្មោះជាស័ុយប្រវត្តិ ដោយរួមបញ្ចូលភាគីចុះហត្ថលេខាថ្មីក្នុងការសម្រួលដឹកជញ្ជូនពលរដ្ឋ និងទំនិញ ឆ្លងកាត់ព្រំដែន ។ ឧបសម្ព័ន្ធ និងពិធីសារទាំងអស់ ដែលលំអិតបច្ចេកទេសសម្រាប់អនុវត្តការសម្រួលដឹកជញ្ជូន ឆ្លងកាត់ព្រំដែន ត្រូវរៀបចំឡើងធ្វើការជជែកពិភាក្សា និងចុះហត្ថលេខាជាបន្តបន្ទាប់ ។

ខ- *គោលបំណងនៃកិច្ចព្រមព្រៀង:*

- សម្រួលការដឹកជញ្ជូន កាត់បន្ថយ និងធ្វើឱ្យស៊ីសង្វាក់គ្នាខាងផ្លូវច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងល័ក្ខខ័ណ្ឌនានាទាក់ទងទៅនឹង ការដឹកជញ្ជូនទំនិញ និងប្រជាពលរដ្ឋឆ្លងកាត់ព្រំដែន និងជំរុញការដឹកជញ្ជូន ពហុរូបភាព ។ អភិវឌ្ឍ និងថែរក្សា ប្រព័ន្ធដឹកជញ្ជូន និងគមនាគមន៍មួយ ដែលមានជលប្រយោជន៍ទៅវិញទៅមកសម្រួន រហ័ស សមហេតុសមផលត្រឹមត្រូវ និងមានប្រសិទ្ធភាព បង្កើនការរួមសហការគ្នា លើវិស័យដឹកជញ្ជូនតាមផ្លូវគោក ការសម្រួលចរាចរ ទំនិញ និងពលរដ្ឋក្នុងជលប្រយោជន៍រួមគ្នា ។

គ- *ខ្លឹមសារ និងចំណុចសំខាន់ៗ :*

វិសាលភាពនៃកិច្ចព្រមព្រៀងអនុវត្តចំពោះការដឹកជញ្ជូនទំនិញ និងពលរដ្ឋ :

- ចូល ចេញ ឆ្លងកាត់ព្រំដែន ឬឆ្លងកាត់ទឹកដី នៃភាគីចុះកិច្ចសន្យាណាមួយ
- មានការដឹកជញ្ជូនតាមរថយន្តមួយត្រឿងឬច្រើនត្រឿង តាមផ្លូវថ្នល់ (រាប់បញ្ចូលទាំងការឆ្លងកាត់ទន្លេតាមសាឡាងចម្លងនៅទីណា ដែលពុំមានស្ពានឆ្លង)
- ដឹកជញ្ជូនពាណិជ្ជកម្ម ដោយអាជីវករដឹកជញ្ជូនសាធារណៈ ឬជាឯកជនដឹកជញ្ជូនថ្នាល់ខ្លួន ឬសម្រាប់ជួល ។

ចំណុចសំខាន់ពិសេសសម្រាប់កិច្ចព្រមព្រៀងគឺ ការសម្រួលបែបបទឆ្លងកាត់ព្រំដែន ដែលត្រូវកាត់បន្ថយ និងធ្វើឱ្យបានឆាប់រហ័ស នូវបែបបទតាមព្រំដែនដូចជា:

ក- ការត្រួតពិនិត្យរួមគ្នាតែមួយលើក: (Single Window Inspection or One Window Inspection)

ការត្រួតពិនិត្យផ្សេងៗ ត្រូវអនុវត្តរួមគ្នា និងព្រមពេលជាមួយគ្នា ដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធរៀងៗខ្លួន (គយ-ប៉ូលីសអន្តោប្រវេសន៍-ពាណិជ្ជកម្ម-សុខាភិបាល ។ល។) ទៅលើពលរដ្ឋ យានយន្ត និងទំនិញរួមគ្នា (លិខិតឆ្លងដែន ទិដ្ឋាការ ប័ណ្ណ បើកបរ សុខភាព និងការពិនិត្យរោគរាតត្បាត ការចុះបញ្ជី លក្ខណបច្ចេកទេសយានយន្ត ការធានារ៉ាប់រង គយរដ្ឋាករ គុណភាព ភូតគាមអនាម័យ ការការពារវុក្ខជាតិ បសុពេទ្យ) ។ល។

ខ- ការត្រួតពិនិត្យស្របគ្នាពេលតែមួយ: (Single Stop Inspection or One Stop Inspection)

អាជ្ញាធរជាតិដែលស្ថិតនៅជាប់គ្នាទាំងពីរ ទឹងត្រូវអនុវត្តការត្រួតពិនិត្យរួមគ្នា និងព្រមពេលជាមួយគ្នា ត្រូវជួយគ្នាទៅវិញទៅមកតាមលទ្ធភាព។ នៅកន្លែងណាដែលពុំអាចឱ្យសាងសង់បានទ្វេប៉ុស្តិ៍ត្រួតពិនិត្យ ដែលស្ថិតនៅជាប់រួមជាមួយគ្នានៅតាមព្រំដែនរោន មន្ត្រីត្រួតពិនិត្យនៃភាគីកិច្ចសន្យាមួយ ត្រូវបានអនុញ្ញាតធ្វើសកម្មភាពការងារត្រួតពិនិត្យរបស់ខ្លួនទៅលើទឹកដីនៃភាគីចុះកិច្ចសន្យាមួយផ្សេងទៀត ។

គ- ការសម្របសម្រួលពេលម៉ោងធ្វើការងារ: របស់អាជ្ញាធរត្រួតពិនិត្យការឆ្លងកាត់ព្រំដែន ដែលនៅជាប់គ្នា ។

ឃ- ការប្តូរគ្នាជាមួន ទ្វរពត៌មាន និងការជម្រះបែបបទ: នៃទំនិញ និងពលរដ្ឋ ។

កិច្ចព្រមព្រៀងបានកំណត់លក្ខខ័ណ្ឌ និងបែបបទនៃការចេញទិដ្ឋាការ ក្នុងការដឹកជញ្ជូនប្រជាពលរដ្ឋឆ្លងកាត់ព្រំដែនទាំងឡាយ ដែលធ្វើអាជីវកម្មដឹកជញ្ជូន បែបបទ តម្រូវការ និងការស្នើសុំទិដ្ឋាការឆ្លងកាត់ ចេញ ចូល ច្រើនដង រយៈពេលវែង ។ល។ ចំពោះការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន ត្រូវលើកលែងចេញពីការត្រួតពិនិត្យជាក់ស្តែងរបស់គយ ការតម្កល់ប្រាក់ធានា និងការអមដំណើរទឹងត្រូវរៀបចំឡើងទ្វរបបជម្រះបែបបទគយខាងក្នុងប្រទេស និងឆ្លងកាត់តាមបែបបទថ្មីថ្មី ។ល។

កិច្ចព្រមព្រៀងកំណត់ការផ្តល់ឱ្យដោយសេរី សម្រាប់ការដឹកជញ្ជូនឆ្លងកាត់ (ចេញ) ឆ្ពោះទៅ ឬត្រឡប់ (ចូល) ទឹកដីនៃភាគីចុះកិច្ចសន្យានីមួយៗ និងត្រូវលើកលែងមិនឱ្យមានជាប់ពន្ធគយ ពន្ធដារផ្សេងៗ និងការចំណាយមិនចាំបាច់នានា។ ការបង់ថ្លៃសេវាឆ្លងកាត់ត្រូវចរចា និងអនុវត្តបណ្តើរៗ ជាពីរជំហាន ហើយចុងក្រោយគឺឆ្លងកាត់ដោយមិនមានការបង់ថ្លៃ។

ភាគីចុះកិច្ចសន្យានីងត្រូវគោរពតាម កិច្ចព្រមព្រៀងអន្តរជាតិ ដែលស្របទៅនឹងបទប្បញ្ញត្តិ នៃអង្គការសុខភាពពិភពលោកអង្គការម្ហូបអាហារ និងកសិកម្ម និងការិយាល័យអន្តរជាតិនៃរោគរាតត្បាតរបស់សត្វ ក្នុងការអនុវត្តការត្រួតពិនិត្យទំនិញឆ្លងកាត់ព្រំដែន និងការត្រួតពិនិត្យភូតគាមអនាម័យ និងបសុពេទ្យ ។

កិច្ចព្រមព្រៀង មិនអនុវត្តទៅលើការដឹកជញ្ជូន ទំនិញគ្រោះថ្នាក់ ទឹងផ្តល់អាទិភាពពិសេសក្នុងការដឹកជញ្ជូនទំនិញងាយខូចគុណភាព ទឹងត្រូវរៀបចំបំពេញ និងជម្រះបែបបទគយឆ្លងកាត់ព្រំដែនឱ្យបានរហ័ស ដើម្បីឱ្យទំនិញទាំងនេះចៀសជុតពីការយឺតយ៉ាវ ។

ត្រូវអនុញ្ញាតឱ្យយកចូលមកក្នុងទឹកដីរបស់ខ្លួន ទាំងរថយន្តចង្កូតឆ្វេង ឬចង្កូតស្តាំ (ឬរថយន្តធ្វើពាណិជ្ជកម្ម រថយន្តជ្លាល់ខ្លួន ឬឯកជន) ដែលចុះបានបញ្ជីដោយភាគីដទៃផ្សេងទៀត ។ យានយន្តទាំងឡាយ ដែលធ្វើចរាចរឆ្លងកាត់ព្រំដែន ត្រូវចុះបញ្ជីនៅក្នុងប្រទេសដើមរបស់ខ្លួន ទឹងត្រូវមានបញ្ជាក់សញ្ញាសម្គាល់គ្រប់គ្រាន់ (សញ្ញាពាណិជ្ជកម្មនៃរោងចក្រជលិតលេខតួ និងលេខម៉ាស៊ីន) មានវិញ្ញាបនបត្រចុះបញ្ជី មានបំពាក់លេខចុះបញ្ជីនៅលើផ្ទាំកលេខមួយ ពាក់នៅខាងក្រោយ និងខាងមុខ ទឹងបំពាក់នូវសញ្ញាសម្គាល់ប្រទេសដែលយានយន្តបានចុះបញ្ជីត្រឹមត្រូវ។

យានយន្ត និងកុងធឺន័រ ក៏ត្រូវបំពាក់គ្រប់គ្រាន់នូវសម្ភារៈសុវត្ថិភាព ទីងមានកម្រិតការបញ្ចេញផ្សែងឱ្យត្រឹមត្រូវតាមស្តង់ដារ ដែលមានជាធរមាននៅក្នុងប្រទេសដើមរបស់គេ។ យានយន្តដែលធ្វើដំណើរទៅកាន់ទឹកដីនៃភាគីដទៃ ក៏ត្រូវតែគោរពជងដែរតាមស្តង់ដារបច្ចេកទេសនៃប្រទេសសាមី ដែលទាក់ទងទៅនឹងទម្ងន់សរុប បន្ទុកភ្លៅ និងទំហំ ខ្ពាតនៃយាន ។ល។

យានយន្តរួងកាត់ត្រូវមានដំណើរការខាងបច្ចេកទេស ។ ប្រទេសដើមជាអ្នកទទួលបន្ទុក ក្នុងការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរបស់យានយន្ត ដែលចុះបញ្ជីទៅក្នុងទឹកដីរបស់ខ្លួន ទីងត្រូវចេញវិញ្ញាបនបត្រត្រួតពិនិត្យ លក្ខណៈបច្ចេកទេសយានយន្ត។ ភាគីដទៃទៀត ត្រូវទទួលស្គាល់នូវវិញ្ញាបនបត្រនេះ ។ ជ្ជាកសញ្ជា បទប្បញ្ញត្តិចរាចរផ្លូវគោក និងស្តង់ដារត្រូវអនុម័ត និងអនុវត្តជាជំហានៗឱ្យឯកភាពគ្នា។

រថយន្ត ដែលធ្វើដំណើរឆ្លងទៅកាន់ដែនដីនៃភាគីផ្សែងទៀត ត្រូវអនុវត្តទៅតាមកាតព្វកិច្ច ទីងមានប័ណ្ណធានារ៉ាប់រងទៅលើភាគីទី ៣ ជាដាច់ខាត។

ត្រូវទទួលស្គាល់ប័ណ្ណបើកបរ ដែលចេញឱ្យដោយភាគីផ្សែងៗទៀត ស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ប័ណ្ណបើកបរក្នុងស្រុក ចេញដោយបណ្តាប្រទេសអាស៊ាន ។

ត្រូវផ្តល់ឱ្យនូវការយកចូលជាបណ្តោះអាសន្ន នូវរថយន្ត (ទីងប្រេងឥន្ធនៈ ដែលមានក្នុងធុងប្រេងផ្តត់ផ្តង់របស់វា ប្រេងរំអិល សម្ភារៈសម្រាប់ជួសជុល ទីងគ្រឿងបន្លាស់ ទៅតាមចំនួនមួយដំសមរម្យ) ដែលបានចុះបញ្ជីទៅភាគីដទៃទៀត ដោយពុំចាំបាច់បង់ពន្ធគយ ទីងពន្ធនាំចូល ដោយពុំមានការតម្កល់ទុកប្រាក់សម្រាប់ធានាក្នុងការបង់ពន្ធគយ ទីងអាចចេញចូលដោយសេរីរួចពីបំរាម ទីងលិក្ខខ័ណ្ឌសម្រាប់ការនាំចេញជាថ្មី ។ល។

សិទ្ធិនៃការធ្វើចរាចរឆ្លងកាត់ ទីងត្រូវធ្វើឡើងជាបន្តបន្ទាប់ ជាពីរជំហាន :

ជំហានទី ១ : ភាគីចុះកិច្ចសន្យាមួយ អាចធានាឱ្យមានការដឹកជញ្ជូន ដូចខាងក្រោម :

(ក) ការដឹកជញ្ជូនឆ្លងកាត់ កាត់តាមទឹកដីភាគីចុះកិច្ចសន្យាដទៃទៀត

(ខ) ការឆ្លងព្រំដែន ចូលទៅក្នុងទឹកដីភាគីចុះកិច្ចសន្យាដទៃទៀត

(គ) ការឆ្លងព្រំដែន ចេញពីទឹកដីភាគីចុះកិច្ចសន្យាដទៃទៀត

ជំហានទី ២ : អាជីវការដឹកជញ្ជូនដែលបានបង្កើតឡើង នៅក្នុងភាគីចុះកិច្ចសន្យាមួយ អាចទទួលខុសត្រូវក្នុងការធ្វើអាជីវកម្មដឹកជញ្ជូន ចូលទៅក្នុង ចេញពី ឬកំឆ្លងកាត់ទឹកដីនៃភាគីចុះកិច្ចសន្យាដទៃទៀត។

ប៉ុន្តែ ការដឹកជញ្ជូនផ្ទៃក្នុង អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពិសេសណាមួយពីប្រទេសសាមី ។

អាជីវការដឹកជញ្ជូន ត្រូវមានអាជ្ញាប័ណ្ណសម្រាប់ការធ្វើអាជីវកម្មដឹកជញ្ជូនឆ្លងកាត់ ដែលចេញឱ្យដោយប្រទេសដើមរបស់ខ្លួន។ ប្រទេសសាមី ត្រូវទទួលស្គាល់អាជ្ញាប័ណ្ណអាជីវកម្ម ដែលចេញឱ្យដោយប្រទេសដើម ។

អាជីវការដឹកជញ្ជូន ដែលបានទទួលអាជ្ញាប័ណ្ណយ៉ាងត្រឹមត្រូវ សម្រាប់ធ្វើអាជីវកម្មដឹកជញ្ជូនឆ្លងកាត់ព្រំដែន នៅឯប្រទេសដើមរបស់ខ្លួន ទីងត្រូវទទួលសិទ្ធិធ្វើអាជីវកម្មដឹកជញ្ជូនឆ្លងកាត់ព្រំដែន។ ប្រទេសសាមី ត្រូវជួយផ្តល់ការអនុញ្ញាតទៅអាជីវការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដើម្បីបង្កើតការិយាល័យតំណាង ក្នុងគោលបំណងសម្រួលការធ្វើអាជីវកម្មដឹកជញ្ជូនរបស់ខ្លួន ។

ប្រតិបត្តិការដឹកជញ្ជូន ត្រូវបានអនុញ្ញាតជាបន្តបន្ទាប់ ជាពីរជំហាន :

ជំហានទី ១ : បរិមាណដឹកជញ្ជូន អាចត្រូវគេកំណត់ឡើងក្នុងពិធីសារទី ៣។ រយៈពេលនៃការអនុវត្តជំហានទី ១ ទីងត្រូវគេកំណត់ក្នុងពិធីសារទី ៣ គណៈកម្មាធិការជាតិសម្រាប់សម្រួលការដឹកជញ្ជូន នៃភាគីចុះ

កិច្ចសន្យានីមួយៗត្រូវប្តូរគ្នា និងចេញឱ្យនូវបរិមាណដែលអនុញ្ញាត ហើយដែលមានការព្រមព្រៀងគ្នាប្រៀងរាល់ឆ្នាំ ។

ជំហានទី ២ : បរិមាណ និងសមត្ថភាពនៃការធ្វើអាជីវកម្មដឹកជញ្ជូន ស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ និងមិនត្រូវឱ្យមានការតឹងរឹង ជាជាងខ្លឹមសារដែលមានចែងក្នុងកិច្ចព្រមព្រៀងឡើយ ។

ល័ក្ខខ័ណ្ឌនៃការដឹកជញ្ជូន និងត្រូវប្រៀបធៀបទៅតាមបទប្បញ្ញត្តិ ដែលកំណត់ទៅក្នុងឧបសម្ពន្ធទី ១០ ។ ការកំណត់តម្លៃសម្រាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ត្រូវអនុវត្តដោយសេរី និងតាមកម្លាំងទីផ្សារ ប៉ុន្តែត្រូវដាក់កម្រិតក្នុងការប្រមូលផ្តុំសហគ្រាស និងមានការពិនិត្យពិច័យពីគណៈកម្មការរួម ដើម្បីចៀសវាងការដាក់ថ្លៃឈ្នួលខ្ពស់ខ្លាំងពេក ឬទាបខ្លាំងពេក ។

ផ្លូវដឹកជញ្ជូន និងចំណុចនានា សម្រាប់ការចូល និងការចេញ ត្រូវកំណត់ក្នុងពិធីសារទី ១ ។ ការស្ថាបនា ឬការស្ថាបនាជាថ្មីឡើងវិញនូវផ្លូវថ្នល់ (គិតទាំងស្ពាន) ដែលតភ្ជាប់ប្រទេសទាំងឡាយ និងដែលបង្ហាញទៅក្នុងពិធីសារទី ១ ត្រូវធ្វើទៅតាមស្តង់ដារគំនូសបួងនៃផ្លូវ និងស្ពាន ក្នុងក្របខ័ណ្ឌនៃកម្មវិធីសាធារណការរបស់ជាតិ ឬកំទៅតាមការផ្តល់ថវិកាជាអន្តរជាតិ ។ ការស្ថាបនា ឬការស្ថាបនាឡើងវិញនឹងត្រូវធ្វើឡើង ដោយអនុលោមទៅតាមលក្ខណៈអប្បបរមា ដូចកំណត់ក្នុងឧបសម្ពន្ធ ទី ១១ ទៅតាមកម្រិតអនុញ្ញាត និងស្របទៅតាមប្រភពថវិកាដែលមាន។

ត្រូវធានាថាផ្លូវថ្នល់ដែលបានឯកភាពគ្នា ត្រូវមានសុវត្ថិភាព សន្តិសុខ និងស្ថិតក្នុងល័ក្ខខ័ណ្ឌ និងត្រូវរ៉ាប់រងក្នុងការអនុវត្ត ការជួសជុលនានាដែលចាំបាច់ ការដាក់ផ្ទាំកសញ្ញា និងភ្លើងសញ្ញានានា ស្របទៅតាមស្តង់ដារជាធំហាន១ ដូចបានកំណត់ក្នុងឧបសម្ពន្ធទី ៧ ។

ត្រូវទទួលរ៉ាប់រង ក្នុងការស្ថាបនា ឬធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ពន្ធ ដែលត្រូវការនៅចំណុចឆ្លងកាត់ព្រំដែន និងក្នុងការប្រៀបចំចាត់តាំងមន្ត្រីរបស់ខ្លួនឱ្យបម្រើការនៅទីនោះ ដើម្បីធានាការបំពេញបែបបទឆ្លងកាត់ព្រំដែនឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព ដូចមានចែងក្នុងឧបសម្ពន្ធទី ១២ ។

ត្រូវបង្កើតឡើងនូវគណៈកម្មាធិការជាតិអចិន្ត្រៃយ៍សម្រួលការដឹកជញ្ជូន ដែលត្រូវដឹកនាំដោយរដ្ឋមន្ត្រី ឬអនុរដ្ឋមន្ត្រីមួយរូប ឬមន្ត្រីដែលមានឋានៈស្មើ ដែលមានតំណាងគ្រប់ផ្នែករបស់ក្រសួង-ស្ថាប័នជាប់ពាក់ព័ន្ធ ក្នុងការអនុវត្តកិច្ចព្រមព្រៀងឱ្យចូលរួមជាសមាជិក ។ តំណាងទាំងឡាយ នៃគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូននឹងរួមគ្នាបង្កើតឡើងជាគណៈកម្មាធិការតំបន់មួយ។

គណៈកម្មាធិការរួមនេះនឹងតាមដានត្រួតពិនិត្យ និងវាយតម្លៃ នូវការប្រព្រឹត្តទៅនៃកិច្ចព្រមព្រៀង និងប្រើប្រាស់ជាវេទិកាសម្រាប់ជជែក ពិភាក្សា និងដោះស្រាយទំនាស់តាមគោលការណ៍សន្តិវិធី និងជាវេទិកាផ្តល់ដំបូន្មានទៅកាន់កាតីចុះកិច្ចសន្យា ព្រមទាំងប្រៀបចំសំណើធ្វើវិសោធនកម្មកិច្ចព្រមព្រៀង។

ប្រជាពលរដ្ឋ អាជីវករដឹកជញ្ជូន និងរថយន្ត ត្រូវអនុវត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ដែលនៅជាធរមានក្នុងទឹកដីនៃប្រទេសសាមី ។ ទៅពេលដែលមានការរំលោភច្បាប់ ត្រូវអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាមូលដ្ឋានរបស់អាជ្ញាធរប្រទេសជាសាមី ។ ប្រទេសសាមី អាចបដិសេធជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍នូវការចូលទៅក្នុងដែនដីរបស់ខ្លួន ចំពោះជនណាមួយ អ្នកបើកបរណាមួយ អាជីវករដឹកជញ្ជូនណាមួយ ឬកំរថយន្តមួយ ដែលបានរំលោភបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ឬក៏ច្បាប់ និងបទប្បញ្ញត្តិជាតិរបស់ប្រទេសខ្លួន ។

ត្រូវបង្កើតឱ្យមានស្បៀវរំភៅកម្រងច្បាប់ជាតិ បទប្បញ្ញត្តិ នីតិវិធី និងពាក្យមានបច្ចេកទេសជាភាសាអង់គ្លេស អំពីការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ។

ត្រូវធានាផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះបំផុត ចំពោះយានយន្ត ទំនិញ និងពលរដ្ឋ នៃកាតីផ្សេងទៀតដោយស្មើភាព និងមិនតិចជាងការផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះបំផុតទៅលើប្រទេសទី ៣ ណាមួយ ក្នុងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន។

ប្រទេសសាមី ត្រូវចាត់វិធានការជួយសង្គ្រោះគ្រប់បែបយ៉ាង និងត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសដើមឱ្យបានឆាប់រហ័សបំផុត ក្នុងករណីមានគ្រោះថ្នាក់ចរាចរ ដែលពាក់ព័ន្ធដល់ប្រជាពលរដ្ឋ អាជីវករដឹកជញ្ជូនយានយន្ត ឬទំនិញពីភាគីផ្សេងទៀត។

ត្រូវទទួលរ៉ាប់រងក្នុងការជុំវិញប្រតិបត្តិការពហុដឹកជញ្ជូន តាមរយៈការអនុវត្តរបបទទួលខុសត្រូវពហុដឹកជញ្ជូន មានសញ្ញានតែមួយ និងកំណត់បរិមាណជាអប្បបរមានូវលក្ខណសម្បត្តិ ដែលតម្រូវឱ្យមានសម្រាប់អាជីវកម្មពហុដឹកជញ្ជូន ដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី ១៣ អា-បេ។

ត្រូវរៀបចំរបបគយក្នុងធីន័រពិសេសមួយ និងឯកភាពគ្នារក្សាទុកការចំណាយ និងពេលវេលាយឺតយ៉ាវឱ្យដល់កម្រិតជាអប្បបរមា។

ភាគីនីមួយ១ ត្រូវទទួលរ៉ាប់រងបន្ថែមទៀតក្នុងការ :

១-កំណត់ចំនួនឯកសារ និងកាត់បន្ថយនូវនីតិវិធី និងសំណុំបែបបទ ដែលត្រូវការបំពេញសម្រាប់ការដឹកជញ្ជូន ឆ្លងកាត់ព្រំដែន

២-ធ្វើការបកប្រែជាភាសាអង់គ្លេស នូវរាល់ឯកសារទាំងអស់ដែលប្រើប្រាស់សម្រាប់ចរាចរឆ្លងកាត់ព្រំដែន

៣-សម្របសម្រួលលក្ខសារបស់ខ្លួន ទៅតាមឯកសារគន្លឹះរបស់អង្គការសហប្រជាជាតិ សម្រាប់ឯកសារពាណិជ្ជកម្ម

4-ធ្វើឱ្យស៊ីសង្វាក់គ្នា តាមតែអាចធ្វើទៅបាន កូដទំនិញ ជលិតជល និងការបរិយាយទាំងឡាយ។ដែលគេនិយមប្រើប្រាស់ជារួម ក្នុងពាណិជ្ជកម្មឆ្លងដែន ដូចដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី ៥ ។

5-ពិនិត្យឡើងវិញនូវរាល់ឯកសារ និងនីតិវិធីទាំងអស់ ដែលត្រូវការចាំបាច់ និងមានសារៈសំខាន់សម្រាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។

6-លុបបំបាត់ចោលនូវឯកសារ និងការទាមទារជាជ្រួវការទាំងឡាយណា ដែលលើសពីសេចក្តីត្រូវការ

7-ធានាអនុវត្ត តាមគ្រប់វង្វាស់វង្វាល់ SI Units (ប្រព័ន្ធអន្តរជាតិនៃឯកតាខាន់តោន ឬប្រព័ន្ធអន្តរជាតិនៃឯកតាមេទ្រិកម៉ូដឹម (Modem Metric Units) នៅឆ្នាំ ២០០៥

8-ជូនដំណឹងជាមុនទៅភាគីផ្សេងទៀត អំពីតម្រូវការបន្ថែម ឬការផ្ទាស់ប្តូរឯកសារ និងនីតិវិធីការណែនាំទាំងឡាយ ដើម្បីផ្តល់ជាសញ្ញាណ និងប្រើប្រាស់ក្នុងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។

កិច្ចព្រមព្រៀងនេះ ជាកម្មវត្ថុក្នុងការផ្តល់សច្ចាប័ន ឬការទទួលយល់ព្រមចូលពីភាគីចុះកិច្ចសន្យា ។

ត្រូវធានា សម្រួលខ្លឹមសារបទប្បញ្ញត្តិជាតិ ដែលពាក់ព័ន្ធឱ្យមានខ្លឹមសារដូច ឬស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនៅចំណុចណាដែលចាំបាច់ ។ ការដាក់លក្ខខ័ណ្ឌនៅលើកិច្ចព្រមព្រៀង ពុំត្រូវបានគេអនុញ្ញាតឡើយ ។

កិច្ចព្រមព្រៀងនឹងចូលជាធរមាននៅថ្ងៃ ដែលភាគីចុះកិច្ចសន្យាទាំងអស់ បានផ្តល់សច្ចាប័ន ឬការឯកភាពលើកិច្ចព្រមព្រៀង។ ភាគីនីមួយ១អាចព្យួរទុកនូវការអនុវត្តកិច្ចព្រមព្រៀងជាបណ្តោះអាសន្ន ដែលមានជម្ងឺពលភាព១ ក្នុងករណីមានការពឹករអាសន្នជាបន្ទាន់ ដែលបះពាល់ដល់សន្តិសុខជាតិរបស់ខ្លួន នឹងត្រូវជូនពតិមានទៅភាគីផ្សេងទៀត អំពីការព្យួរទុក និងអំពីការបញ្ចប់ការព្យួរទុកនេះឱ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន នៅពេលណាដែលសភាពការណ៍វិលត្រឡប់ទៅស្ថានភាពជាធម្មតាវិញ ។

កិច្ចព្រមព្រៀង ឬក៏សកម្មភាពណាមួយក្នុងកិច្ចព្រមព្រៀងនេះ នឹងមិនមានប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយ១នៅក្រោមកិច្ចព្រមព្រៀង ឬអនុសញ្ញាអន្តរជាតិផ្សេងទៀតដែលមានស្រាប់ដែលភាគីទាំងនេះ ជាសមាជិកដែរនោះទេ ។

ទំនាស់រវាងភាគី ២ ឬភាគីច្រើននៅលើការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងត្រូវស្រុះស្រួលដោះស្រាយដោយថ្នាល់ ឬដោយការចរចាតាមគោលការណ៍សន្តិវិធី តាមរយៈគណៈកម្មាធិការរួម ។ ភាគីនីមួយ១ អាចស្នើធ្វើវិសោធនកម្ម កិច្ចព្រមព្រៀងនេះដោយឆ្លងកាត់គណៈកម្មាធិការរួម។ ការចូលជាធរមាន នៃវិសោធនកម្មលើកិច្ចព្រមព្រៀងនេះត្រូវមានការយល់ព្រមជាឯកច្ឆន្ទ នៃភាគីទាំងអស់ ។

កិច្ចព្រមព្រៀងនេះ អាចប្រកាសបដិសេធដោយភាគីណាមួយ បន្ទាប់ពីការជុតចំនួនកំហេត់ឆ្នាំ គិតចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងចូលជាធរមាន និងត្រូវធ្វើសេចក្តីប្រកាសជូនដំណឹង ផ្ញើជូនទៅភាគីផ្សេងទៀត ។ ការប្រកាសបដិសេធត្រូវមានប្រសិទ្ធភាពមួយឆ្នាំ បន្ទាប់ពីការធ្វើសេចក្តីជូនដំណឹងរបស់ខ្លួន ។

សេចក្តីដូចបានទូលថ្វាយ និងជម្រាបជូនខាងលើនេះ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់នេះដោយអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ១២ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

Tril-agee-landtranspt220102 01/21/02 .

បកប្រែក្រៅផ្លូវការ

កិច្ចព្រមព្រៀងស្តីពីការដាក់ អនុវត្តជាសាកល្បង នៃប្រព័ន្ធដឹកជញ្ជូនឆ្លងកាត់ព្រំដែន រវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ហៅកាត់ថា " ភាគីចុះកិច្ចសន្យា " ។

ដោយចាប់ឆន្ទៈយ៉ាងមុតមាំ ដើម្បីថែរក្សា អភិវឌ្ឍន៍ និងពង្រឹងបន្ថែម ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងភាគីចុះកិច្ចសន្យា រួមទាំងណែនាំយ៉ាងមុតមាំ ដើម្បីជួយអភិវឌ្ឍន៍ ន្ទទំនាក់ទំនងពាណិជ្ជកម្មរបស់គេ នៅក្នុងក្របខ័ណ្ឌនៃការឆ្លងកាត់គ្នាខាងសេដ្ឋកិច្ច នៅក្នុងអនុតំបន់

